៩

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៤១ ខែ កញ្ញា

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-



សម្ដេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ

ជួន-ណាត ព្រះសង្ឃរាជថ្នាក់ទី១

ទ្រង់បានយាងចូលទីវង្គតពីថ្ងៃ ព្រហស្បតិ៍ ទី ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី នៅព្រះមហាកុដិ វត្តឧណ្ណាលោម ។

ទស្សនាវដ្ដីកម្ពុជសុរិយា និង វិជ្ជាប៉ានពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងបុគ្គលិកទាំងអស់ សូមឱនកាយសម្ដែងសេចក្ដីសោកវិយោគដ៏ក្រៀមក្រំបំផុត ចំពោះព្រះរាជទីវង្គតនេះ ។

៩

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

| អត្ថបទ | ផ្នែកសាសនា | ទំព័រ |
|---|---|---|


១— ទស្សនវិជ្ជាក្នុងសាសនា ព្រះមហាវីរយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង ៩០៣

២ [illegible] ភិក្ខុ [illegible]-សារុន [illegible] រៀបរៀង . . . ៩១៦


## ផ្នែកអក្សរសាស្ត្រ


៣— [illegible] លោក [illegible]-ស៊ុំ រៀបរៀង . . . . ៩២៦

៤— [illegible]ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . ៩៣៣

៥— [illegible] (៥) [illegible]-កន ប្រែរៀបរៀង . . . . ៩៣[illegible]

៦— រឿង[illegible] [illegible] ពេជ-សុខ ប្រែរៀបរៀង ៩៤៥

៧— ចំនុកបុរាណខ្មែរ សហ. លី-ធាមតេង ប្រមូលក្រង . . . ៩៦៣

៨— សៀវភៅ[illegible] សហ. លី-ធាមតេង ស្រាវជ្រាវ . . . . ៩៧១

៩— វប្បធម៌[illegible] ព្រះមហាវីរយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង . . ៩៨៧

១០— [illegible] . . ១០០២


## ផ្នែកកំណត់-ប្រវត្តិការណ៍


១១— [illegible]

[illegible] . . . ១០[illegible]

ក្បួនទាំងមាន ១២ សៀវភៅ តម្លៃជា ២៣០៛០០ ។

## ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យជុំសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា ។ |

ប ព

# ទស្សនវិជ្ជាពុទ្ធសាសនា

ព្រះមហាវីរិយបណ្ឌិតោ ម៉ាង-ខាត់ រៀបរៀង

## (តពីលេខមុន)

ថ្ងៃមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថ អស់រាត្រីមួយ ក្នុងរោងកុម្ភការ ទ្រង់បានជួបបុរសក្មេងម្នាក់ ដែលចូលមកនៅក្នុងរោងនោះមុនព្រះអង្គ ។ ព្រះអង្គក្តី បុរសក្មេងក្តី ទាំងពីរនាក់នេះ មិនបានស្គាល់គ្នាទេ ។ លុះទតព្រះនេត្រឃើញបុរសក្មេងនោះហើយ ព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះថា : "បរិយាបុរសនេះ ស្រគត់ស្រគមសមរម្យល្អណាស់ មើលទៅមុខគួរឲ្យជ្រះថ្លា គួរនឹងបានផលល្អ ប្រសិនបើតថាគតសាកសួរមើល „ ។ ទ្រង់ព្រះតម្រិះហើយទ្រង់ត្រាស់ក្សាន្តសួរថា :

„ម្នាលបុរស ! អ្នកចេញចាកផ្ទះហើយមកបួសនេះ តើអ្នកបួសចំពោះលោកណា? លោកណាជាសាស្តារបស់អ្នក? តើធម៌លោកនោះដូចម្តេច?

បានឮពុទ្ធដីកាហើយ ឫសីក្មេងនោះ ឆ្លើយតបពុទ្ធដីកាដោយអាការជា គ្នាន៍រធម្មតា ថា :

"ឱសម្លាញ់អើយ ! មានបួសមួយអង្គនាមថា គោតម ជាសាក្យដោយជាតិ ព្រះអង្គចេញចាកសាក្យត្រកូល ហើយមកបួសកាន់យកភេទជាបួស ព្រះអង្គមានកិត្តិនាមល្បីខ្ចរខ្ចាយទៅថា ជាព្រះអរហន្ត បានត្រាស់ដឹងធម៌ ជាសម្មាសម្ពុទ្ធ ខ្ញុំឮហើយជ្រះថ្លា ខ្ញុំចេញចាកផ្ទះមកបួសកាន់យកភេទជាបួសចំពោះព្រះអង្គ ព្រះអង្គជាសាស្តាខ្ញុំ ខ្ញុំពេញចិត្តចំពោះភេទៈរបស់ព្រះអង្គនោះ" ។

"ចុះព្រះអង្គ, ទ្រង់ត្រាស់សួរទៀត, ជាអរហន្ត ជាសម្មា-សម្ពុទ្ធ ដែលអ្នកយកធ្វើជាសាស្តាខ្លួនអ្នកនោះ ឥឡូវនេះទ្រង់គង់នៅទីណា ?

"ឱសម្លាញ់អើយ !, ឫសីក្មេងឆ្លើយតបវិញ, បានឮថាមានអា-រាមមួយនៅឯឧត្តរប្រទេស ជិតក្រុង សាវត្ថី ព្រះអង្គជា អរហន្ត ជាសម្មាសម្ពុទ្ធ ជាសាស្តារបស់ខ្ញុំ ព្រះអង្គប្រថាប់នៅទីនោះ ។

"នែឫសីក្មេង !, ទ្រង់ត្រាស់បញ្ជាក់, ចុះអ្នកដែលបានឃើញសាស្តារបស់អ្នកនោះដែរឬទេ ?

"ទេសម្លាញ់ !, ឫសីក្មេងបញ្ជាក់ទូល ខ្ញុំមិនដែលបានឃើញ ឬបាន

ជួបព្រះអង្គទេ កុំថាឡើយឃើញ គ្រាន់តែស្គាល់ព្រះអង្គខ្ញុំក៏មិនដែលទាំងបានស្គាល់ព្រះអង្គផង " ។

ពេលនោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ឫសីក្មេងនេះបួសកាន់យកភេទជាតាបសចំពោះធម្មវិន័យព្រះអង្គ ទើបទ្រង់ត្រាស់ថា ៖

" ខៃកិក្ខុ ! តថាគតនឹងទេសនា អ្នកប្រុងស្តាប់ចុះ ! " ។ តទៅទ្រង់សំដែង អរិយសច្ច ព្រោសប្រទាន ចប់ ធម្មកថា ហើយឫសីក្មេងនោះបានលុះអរហត្តផល ។ ទីបំផុត ទាំងអស់គ្នាបានស្គាល់ថាឫសីក្មេងនោះគឺ បុក្កុសាតិភិក្ខុ អ្នកប្រទានធម្មទេសនានោះ គឺអង្គព្រះសម្ពុទ្ធ ។ ពេលនោះ បុក្កុសាតិភិក្ខុ ឱនក្រាបទៀបបាទាអង្គព្រះសម្ពុទ្ធ ហើយលើកកម្ពង់អញ្ជលីក្រាបទូលសូមខមាទោស ដោយខ្ញុំពុំបានដឹងថាជាអង្គព្រះសម្ពុទ្ធ បានក្ញាត់ពោលពាក្យហៅព្រះអង្គថា " សម្លាញ់ " ។ តទៅ បុក្កុសាតិ ក្រាបទូលអង្គព្រះសម្ពុទ្ធ សុំបព្វជាជាភិក្ខុកង់សំណាក់ពុទ្ធសាសនា តែពេលនោះ បុក្កុសាតិ មិនមានត្រៃចីវរ មិនមានបាត្រ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់បង្គាប់ឲ្យរកត្រៃចីវររកបាត្រ តាមប្រពៃណីពុទ្ធសាសនា ។ បុក្កុសាតិ ក្រាបថ្វាយបង្គំលាព្រះសម្ពុទ្ធ ហើយដើរទៅស្វែងរកត្រៃចីវរនិងបាត្រ កំពុងតែដើរស្វែងរក មានគោញីមួយអកដល់លោក ហើយលោកធ្វើមរណកាលទៅ ។

តមកថ្ងៃក្រោយទៀត ព្រះសម្ពុទ្ធទ្រង់បានជ្រាបថា បុក្កុសាតិភិក្ខុ នោះគោជល់ហើយ ធ្វើមរណកាលទៅហើយ ទើបទ្រង់ត្រាស់ថា: “ បុក្កុសាតិភិក្ខុ នេះជាអ្នកប្រាជ្ញ បានឃើញអរិយសច្ចធម៌ហើយ បានដល់ឈានថ្នាក់ខ្ពស់ផុត ដែលត្រូវសម្រេចនិព្វានជាអរហន្ត និព្វានហើយមិនត្រឡប់មកកាន់ភពនេះទៀតទេ ,, ។

និទាននេះ បញ្ជាក់សេចក្តីច្បាស់លាស់អស់ដើងហើយថា បុក្កុសាតិភិក្ខុ បានស្តាប់ធម៌អង្គព្រះសម្ពុទ្ធ ហើយបានត្រាស់ដឹងធម៌ព្រះអង្គហើយ ។ ភិក្ខុ បុក្កុសាតិ នេះ មិនបានស្គាល់ថាអ្នកណាជាអ្នកសម្តែងធម៌ដល់ខ្លួនទេ តែលោកស្តាប់ហើយមានក្តុក ឃើញសច្ចធម៌ពិតប្រាកដ ។ បុក្កុសាតិភិក្ខុ បានឃើញធម៌ ហើយបានលុះអរហត្តផល ចូលនិព្វានទៀតតើបានដោយមានស្វាក ឬ យ៉ះហោ ? បើថ្នាំសក្តិសិទ្ធិហើយ ជម្ងឺមុខតែជាសះស្បើយពិតប្រាកដពុំខាន មិនបាច់ដឹងថាពេទ្យណាជាអ្នកផ្សំថ្នាំ ឬ ថ្នាំនោះបានមកពីលោកណាទេ ។ ដូច្នេះសច្ចធម៌ មិនពឹងផ្អែកទៅលើស្វាក ឬ យ៉ះហោឡើង ។

លទ្ធិសាសនាស្ទើរតែទាំងអស់ សុទ្ធតែកើតឡើងដោយជំនឿ-(Foi, croyance) យកជំនឿ ឬ “ជំនឿខ្វាក់” ទុកជាបានលទ្ធិសាសនាហើយពឹងផ្អែកទៅលើព្រះអាទិទេព ព្រមទាំងលាក់ព្រះអាទិទេពនៅឯឋានសួគ៌ ហើយផ្សាយជំនឿឲ្យគេជឿតាម ។ ជំនឿបែបនេះ ជាជំនឿ

ឥតហេតុផល ជាជំនឿឥតបើគិត ។ ឯជំនឿក្នុងពុទ្ធសាសនា ផ្ទុយគ្នាស្រឡះជាជំនឿប្រកបដោយហេតុផល (Cause et effet) ជាជំនឿប្រកបទៅដោយវិចារណញ្ញាណ (Raisonnement) ពោលគឺសទ្ធា =ជំនឿដែលប្រកបដោយបញ្ញា Confiance= Confidence et sagesse = winsdom) ។ ជំនឿពុទ្ធសាសនានេះ សំដៅយក ៖ ការឃើញច្បាស់ ការដឹងច្បាស់, ការយល់ជាក់ច្បាស់ "មិនមែនសំដៅយកជំនឿបែប "Foi, Croyance; Faith, Belief " ដូចពាហិរសាសនាទាំងអស់នោះទេ ។ សព្វថ្ងៃនេះ យើងប្រើពាក្យច្រឡូកច្របល់គ្នាណាស់ ដូចពាក្យថា " Religion " យើងប្រែថា "សាសនា" ឬពាក្យថា „ Foi, Croyance ជាបារាំង, Faith, Belief ជាអង់គ្លេស យើងប្រែថា „ជំនឿ ពោលគឺ សទ្ធា" តែសេចក្ដីពិត ពាក្យថា "សទ្ធា= ជំនឿ" ក្នុងពុទ្ធសាសនា មិនមែនមានអត្ថន័យដូចពាក្យ " Foi, Croyance; Faith, Belief " ក្នុងសទ្ធិសាសនាគ្រិស្ត ឥស្លាម ព្រាហ្មណ៍ នោះទេ ។ សទ្ធា = ជំនឿក្នុងពុទ្ធសាសនា ជាជំនឿបែប „ Confiance, Confidence " = ជំនឿដែលកើតចេញពីការជឿជាក់ (Conviction) ការជ្រះថ្លា (Joi ou sereine) ទុកជាសរណៈ ការទីពឹងប្រសើរ (Refuge ) ដូចសទ្ធា ជឿជាក់ ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដើម ។ ការជឿជាក់ច្បាស់មិនកម្រើក, សេចក្ដីជ្រះ

ថ្វាចំពោះកុសលធម៌,   ការទុកចិត្តដោយយល់ច្បាស់ថានឹងបានសម្រេចដូចបំណង  ក៏លោកទុកថាជា សទ្ធា=ជំនឿដែរ ។  ធម៌ ២ ប្រការ គឺ សទ្ធា និង បញ្ញា ជាធម៌គូគ្នា គឺបើមានសទ្ធា ត្រូវមានបញ្ញា ។ អ្នកជឿ មិនមានបញ្ញានឹងដើរវង្វេងផ្លូវ ។ អ្នកមានសទ្ធា មិនប្រើបញ្ញាពិចារណារកខុសត្រូវ គិតតែពីជឿ នឹងធ្លាក់ទៅជាមនុស្សល្ងង់ ។ រីអ្នកមិនមានសទ្ធា មិនមានជំនឿទេ ធ្វើអ្វី ។ អាងបញ្ញាគិតពិចារណា បើបញ្ញាខ្លួនគិតតាក់មិនធ្លុះ នឹងធ្លាក់ខ្លួនទៅជាអ្នកយល់ខុស គឺទៅជាអ្នកមិច្ឆាទិដ្ឋិ ។ អ្នកដើរក្នុងលោកងងឹតនេះ ត្រូវប្រើធម៌ ២ ប្រការគឺ សទ្ធា និង បញ្ញានេះ នឹងខានពុំបានឡើយ ទើបដើរទៅមិនវង្វេងកណ្ដាលអន្ធា ។

សទ្ធា = ជំនឿ ដែលប្រកបដោយបញ្ញា ពិចារណាឃើញពិតដឹងពិត យល់ពិត នូវកិច្ចការអ្វីមួយដែលបុគ្គលត្រូវការធ្វើ ជាពលៈ = មានសទ្ធាពល មានកម្លាំងខ្លាំងបំផុត ជាហេតុនាំឲ្យសម្រេចសេចក្ដីប្រាថ្នាពិតប្រាកដ ។ បុគ្គលដែលធ្វើកិច្ចការអ្វីមួយ ហើយមិនបានសម្រេចសមតាមក្ដីប្រាថ្នា មិនមែនដោយខ្វះអ្វីទេ គឺខ្វះធម៌ ២ ប្រការនេះឯង ។

ព្រះបរមពោធិសត្វ ដែលបានសម្រេចភាវៈជាព្រះសម្ពុទ្ធ ក៏ដោយសទ្ធា ដែលប្រកបដោយបញ្ញា ចាប់ដើមតាំងពីទ្រង់តាំងព្រះទ័យកសាងបារមីធម៌ ឲ្យបានសម្រេចសម្មាសម្ពោធិញាណ ។ សទ្ធានេះហៅថា

អាគមសទ្ធា ។

ព្រះអរហន្តគ្រប់អង្គ ក៏មានសទ្ធាដែលប្រកបដោយបញ្ញា ទើបបាន លុះធម៌ដែលព្រះសម្ពុទ្ធទ្រង់សម្ដែងទុកមក ។ សទ្ធានេះ ហៅថា អធិគមសទ្ធា ។

ឯការជឿជាក់ច្បាស់ មិនករម្រើកចំពោះគុណព្រះរត្នត្រ័យ ក៏ដោយសទ្ធាដែលប្រកបដោយបញ្ញាដែរ ។ សទ្ធានេះ ហៅថា ឱកប្បនសទ្ធា ។

ចិត្តដែលជ្រះថ្លាចំពោះអំពើជាកុសល ដោយបានយកបញ្ញាពិចារណាឃើញពិត ដឹងពិត យល់ពិត ថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ នេះហៅថា បសាទសទ្ធា ។

សទ្ធាដែលប្រកបដោយបញ្ញានេះ ជាទ្រព្យដ៏ប្រសើររបស់មនុស្សក្នុងលោក សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ ជំនឿនេះ មានតម្លៃណាស់ស្មើជីវិត មិនគួរនឹងជឿអ៊ីៗ ឥតបើគិតទេ ។ បុគ្គលជឿឥតបើគិតនេះ មានទោសដល់ស្លាប់ ។ ដូច្នេះ ជំនឿផ្សេងៗ បែប Foi, Croyance; Faith, Belief តែងកើតឡើងតែក្នុងពេលណា ដែលគេមិនទាន់ឃើញពិត ដឹងពិត យល់ពិត , ក្នុងពេលណាដែលគេបានឃើញពិតបានដឹងពិតបានយល់ពិតហើយ ប្រស្នាជំនឿនេះនឹងលេចបាត់ទៅឯង ឧបមាថា មានមនុស្សម្នាក់មកនិយាយប្រាប់ថា "ខ្ញុំមានពេជ្រមួយគ្រាប់នៅក្នុងកាប់

ដៃខ្ញុំនេះក្នុងពេលដែលឮពាក្យនេះ” ប្រស្នាជំនឿទើបកើតឡើង ព្រោះមិនទាន់បានឃើញពេជ្រនោះ ដោយភ្នែកខ្លួនឯងនៅឡើយ គ្រាន់តែឮគេនិយាយប្រាប់ ។ កាលបើអ្នកនិយាយនោះលាក្តាប់ដៃបង្ហាញពេជ្រនោះហើយ យើងឃើញពេជ្រនោះដោយភ្នែក នឹងថាជាពេជ្រពិតមែនយល់ច្បាស់ថាជាពេជ្រពិតមែន ពេលនោះប្រស្នាជំនឿបែប Foi, Croyance; Faith, Belief រលត់បាត់ឯងលែងកើតមានទៀតហើយ ។ សេចក្តីនេះដូចជារឿងដែលយើងធ្លាប់បានឮមកថា ” បានសម្រេច ដូចជាគេបានឃើញពេជ្រនៅលើបាតដៃ ,, ។ ដូច្នេះ គួរគប្បីយល់ថា ជំនឿដែលកើតមានឡើង កើតមានតែក្នុងពេលណា ដែលយើងមិនទាន់ឃើញ មិនទាន់ដឹង មិនទាន់យល់ បើឃើញហើយដឹងហើយ យល់ច្បាស់ហើយ ប្រស្នាជំនឿនេះនឹងបាត់ទៅឯងវិញ មិនមានជាប្រស្នាចោទឡើងទៀតទេ ក្នុងគម្ពីរបាលីពុទ្ធសាសនា មាននិទានជាឧទាហរណ៍ច្រើនអន្លើណាស់ សម្រាប់បញ្ជាក់សេចក្តីខាងលើនេះ ដូចនិទានតទៅនេះ (១) ។

សម័យមួយ ព្រះ មុសិលត្ថេរ គង់នៅវត្ត ឃោសិតារាម ជិតក្រុង កោសម្ពី មានថេរដីកាចំពោះព្រះបវិដ្ឋត្ថេរ ថា :

“ អាវុសោ បវិដ្ឋ ! បើបុគ្គលណាមួយមិនមានធម៌ ៥ ប្រការ:

-សទ្ធា = ជំនឿ គឺជំនឿទូទៅតាមធម្មតា តាមអត្តានុរូបរបស់

១- សំយុត្តនិកាយ និទានវគ្គ សៀវភៅទី ៣១ ទំព័រ ២៥៧ ។

សព្ទថា "សទ្ធា,, មានអត្ថន័យដូច Dévotion, Foi, Croyance; Faith, Belief

- រុចិ = ការពេញចិត្ត (Penchant ou inclination= Liking or inclination)

- អនុស្សវ = ការឮតៗគ្នា (Oui-dire ou tradition= Hear-say or tradition)

- អាការបរិវិតក្កា = ការត្រិះរិះដោយអាការ (Considérer les raisons apparentes= Considering apparent reason)

- ទិដ្ឋិនិជ្ឈានក្ខន្តិ= ការចូលចិត្តតាមការយល់ឃើញ (Se complaire dans les spéculations des opinions= Delight in the speculations of opinions)

ខ្ញុំដឹងថា ខ្ញុំឃើញថា ជរា ព្យាធិ មរណា រលត់ព្រោះជាតិរលត់, ជាតិរលត់ ព្រោះ ភព រលត់, ភព រលត់ ព្រោះ ឧបាទាន រលត់, ឧបាទាន រលត់ ព្រោះ តណ្ហា រលត់, តណ្ហា រលត់ ព្រោះ វេទនា រលត់, វេទនា រលត់ ព្រោះ ផស្ស រលត់, ផស្ស រលត់ ព្រោះសឡាយតនរលត់, សឡាយតនរលត់ ព្រោះ នាមរូបរលត់, នាមរូបរលត់ ព្រោះ វិញ្ញាណរលត់, វិញ្ញាណ រលត់, ព្រោះ សង្ខារ រលត់, សង្ខារ រលត់ ព្រោះ អវិជ្ជា រលត់ ។

"អាវុសោ មុសិល! ព្រះបវិដ្ឋត្រូវសួរបញ្ជាក់, បើមិនមានធម៌ ៥ ប្រការខាងលើនេះ តើ មុសិលមានអាយុ មានញាណឃើញច្បាស់ក្នុងខ្លួនថា ភពរលត់ ភវនិរោធ គឺនិព្វាន ដូច្នេះឬ ?

"អាវុសោ បវិដ្ឋ, ព្រះមុសិលត្រូវតប, បើមិនមានធម៌ ៥ ប្រការនេះទេខ្ញុំដឹង ខ្ញុំឃើញថា "ភពរលត់ ជានិព្វាន = ភវនិរោធោ និព្វានំ,, ។

"អាវុសោ មុសិល! ព្រះបវិដ្ឋត្រូវ បញ្ជាក់ថែមទៀត, បើដូច្នោះមានតែ មុសិល ជាមានអាយុ ជាព្រះអរហន្តខីណាស្រពឬ?

កាលព្រះ បវិដ្ឋត្រូវ សួរបញ្ជាក់ថែមទៀតយ៉ាងនេះហើយ ព្រះមុសិលត្រូវ គង់នៅស្ងៀម មិនទាំតតទៅទៀត ។

សទ្ធានេះ មិនមាននៅសន្តានចិត្តព្រះអរហន្តទេ ដូចសេចក្តីតទៅនេះ (១) ។

សម័យមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចឥរិយាបថ នៅវត្តជេតវនារាម ជាអារាមអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ជិតក្រុងសាវត្ថី ។ កាលនោះ ព្រះសម្ពុទ្ធរមិលមើលឃើញឧបនិស្ស័យភិក្ខុ ៣០ រូប ទ្រង់ប្រារព្ធបញ្ញិន្ទ្រិយ ហើយត្រាស់ចំពោះព្រះ សារីបុត្ត ថា :

"សារីបុត្ត! អ្នកមាន សទ្ធា = ជំនឿចំពោះសទ្ធិន្ទ្រិយ ដែល

---

១- [illegible] ។

តថាគតបានការនាហើយ ចុះសិប៉ុន្តែ អមតនិញ្វាន មានអមតនិញ្វាន ជាបរិយោសានដែរឬទេ ? ។

"សូមទ្រង់ព្រះមេត្តាប្រោស! ព្រះសារីបុត្តត្ថេរ ទូលតបព្រះពុទ្ធដីកា ខ្ញុំព្រះអង្គមិនលុះដោយសទ្ធាអង្គព្រះមានព្រះភាគថា "សទ្ធិន្ទ្រិយ ។ល។មាន អមតនិញ្វាន ជាបរិយោសាន,, ដូច្នេះទេ ។

"សូមទ្រង់ព្រះមេត្តាប្រោសបុគ្គលណា មិនបានដឹង មិនបានសិក្សា មិនបានឃើញ មិនបានត្រាស់ដឹង មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់សេចក្តីនេះដោយបញ្ញាខ្លួនឯងទេ បុគ្គលនោះតែងលុះដោយសទ្ធានៃបុគ្គលដទៃថា សទ្ធិន្ទ្រិយ ដែលបុគ្គលដទៃបានការនាហើយ ។ល។ មាន អមតនិញ្វាន,, ជាបរិយោសាន ដូច្នោះឯង ។

កាលនោះ ភិក្ខុទាំងឡាយបបួលគ្នានិយាយអឺងកង់ឡើងថា ព្រះសារីបុត្តត្ថេរ ក្រាបទូលតបស្នងព្រះពុទ្ធដីកាអំបាញ់មិញនេះ ដោយការយល់ឃើញខុសទេ ។ ថ្ងៃនេះ ព្រះសារីបុត្តត្ថេរ មិនមានសទ្ធាជឿអង្គព្រះសម្ពុទ្ធឡើយ ។ សេចក្តីនេះបានជ្រាបដល់ព្រះកាណ៌អង្គព្រះមានបុណ្យទើបទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា :

"ភិក្ខុទាំងឡាយ! តថាគតសួរ សារីបុត្ត ថាបុគ្គលដែលមិនបានការនាបញ្ចិន្ទ្រិយ មិនបានចម្រើន សមថវិបស្សនា តើអាចធ្វើឲ្យជាក់ច្បាស់នូវមគ្គផលបានឬទេ ដូច្នេះទេតើ ។ ពេលនោះព្រះសារី-

បុត្ត ឆ្លើយតប មកតថាគតវិញថា :

“សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គមិនមានសទ្ធាជឿថា “បុគ្គលនេះអាចធ្វើឲ្យជាក់ច្បាស់បាន, សារីបុត្ត មិនមានសទ្ធាជឿផលវិបាកដែលគេឲ្យ ឬ ផលវិបាកដែលគេធ្វើ, មិនមានសទ្ធាជឿគុណព្រះអរិយបុគ្គល មានអង្គព្រះសម្ពុទ្ធជាដើមដូច្នេះទេ ,, ។ សារីបុត្ត មិនមានសទ្ធាយ៉ាងនេះព្រោះ សារីបុត្ត បានឈាន វិបស្សនា មគ្គផលខ្លួនឯងហើយ មិនលុះដោយសទ្ធានៃអ្នកដទៃទៀតទេ ។ ដូច្នេះអ្នកទាំងឡាយ មិនគួរលើកទោស សារីបុត្តឡើយ មានពុទ្ធដីកាហើយទ្រង់ត្រាស់ថា :

អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ ។

លោកណាអស់សទ្ធា បានលុះនិព្វាន អស់កំណើត អស់ពូជបុណ្យបាប
មានករណីយកិច្ចធ្វើហើយ លោកនោះ ជាឧត្តមបុរស

សេចក្តីនេះ បញ្ជាក់យ៉ាងច្បាស់លាស់ថា: “ព្រះអរហន្ត មិនមានសទ្ធាទេ ព្រះអរហន្តលះបង់ចោលសទ្ធាអស់ហើយ” ។ មួយទៀត សេចក្តីនេះ បញ្ជាក់ច្បាស់លាស់ថា: “ព្រះសម្ពុទ្ធមានព្រះទ័យទូលំទូលាយណាស់ទ្រង់ប្រទានសេរីភាពដ៏បរិបូណ៌ដល់សាវកព្រះអង្គ សាវកព្រះអង្គអាចពោល

ដោយសេរីចំពោះព្រះភក្ត្រព្រះសាស្តារបស់ខ្លួន តាមសេចក្តីពិតដែលខ្លួនបានឃើញពិត ,, ។ ព្រះសម្ពុទ្ធតែងទ្រង់ត្រាស់ថា(១) :

ភិក្ខុទាំងឡាយ ! បុគ្គលណាបានកំចាត់បង់នូវឆន្ទរាគ និង ឧបកិលេសអស់រលីងហើយ បុគ្គលនោះ បានឃើញ មិនបានដឹង មិនបានយល់ច្បាស់ នោះឥតអត្ថិមានឡើយ ។

ប្រសាទសទ្ធា=ជំនឿ នេះ និយាយចំពោះតែការឃើញច្បាស់ដឹងច្បាស់តែប៉ុណ្ណោះទេ មិនមែននិយាយពីជំនឿតាមធម្មតានោះទេ ។ សេចក្តីនេះ ព្រះសម្ពុទ្ធបានថ្លែងបញ្ជាក់ដោយពុទ្ធវចនៈថា "ឯហិ បស្សិកោ" បានសេចក្តីថា ចូរអ្នកចូលមក ! ហើយមើលដោយខ្លួនឯងចុះ" មិនមែនហៅឲ្យចូលមក ហើយឲ្យជឿដូចពាហិរសាសនាទាំងឡាយទេ ។

(នៅមានត)

---

១-សំយុត្តនិកាយ កិលេសសំយុត្ត សៀវភៅទី ៣៤, ទំព័រ ១៧៥ ។

# អដ្ឋង្គិកមគ្គកថា

ភិក្ខុ លាម - សារុន ហៅ ឋាន និស្សិតពុទ្ធិកសកល-
វិទ្យាល័យព្រះសីហនុរាជ រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*វេលានេះ សូមសម្តែងអំពី អដ្ឋង្គិកមគ្គ ដោយសង្ខិត-ន័យ ដូចតទៅនេះ ៖*

*ពាក្យថា អដ្ឋង្គិកមគ្គ ប្រែថា មគ្គប្រកបដោយអង្គប្រាំបី បានសេចក្តីថា ធម៌ ៨ យ៉ាង សម្រាប់ពួកសត្វប្រតិបត្តិ ដើម្បីឆ្ពោះទៅរកព្រះនិព្វាន ។*

*មគ្គ ៨ យ៉ាងនោះគឺ ៖*

| | |
|---|---|
| ១- សម្មាទិដ្ឋិ | ការយល់ឃើញត្រូវ |
| ២- សម្មាសង្កប្បៈ | សេចក្តីត្រិះរិះត្រូវ |
| ៣- សម្មាវាចា | វាចាត្រូវ |
| ៤- សម្មាកម្មន្តៈ | ការងារត្រូវ |
| ៥- សម្មាអាជីវៈ | ការចិញ្ចឹមជីវិតត្រូវ |
| ៦- សម្មាវាយាមៈ | ការព្យាយាមត្រូវ |
| ៧- សម្មាសតិ | សេចក្តីរលឹកត្រូវ |
| ៨- សម្មាសមាធិ | ការតម្កល់ចិត្តត្រូវ |

បណ្ដាមគ្គទាំង៨នេះ, មគ្គ ទី១គឺ, សម្មាទិដ្ឋិ ជាប្រធានលើ មគ្គ ទាំងអស់ ព្រោះថា បើបុគ្គលមាន សម្មាទិដ្ឋិហើយ, មគ្គ ដទៃទៀតទើបកើតឡើងជាលំដាប់លំដោយ, សមដូចព្រះពុទ្ធដីកាថា តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ម្នាលភិក្ខុទាំងឡាយ បណ្ដាមគ្គទាំង ៨នោះ សម្មាទិដ្ឋិ ជាធម្មជាតិដល់មុន (ជាប្រធាន) ។

តើសម្មាទិដ្ឋិជាប្រធានដូចម្ដេច ?

មុនដំបូង ត្រូវស្គាល់ឲ្យច្បាស់នូវពាក្យថា សម្មាទិដ្ឋិសិន សម្មាទិដ្ឋិ ប្រែថា ទិដ្ឋិត្រូវ, ការយល់ឃើញត្រូវ

គម្ពីរមហាចត្តារីសកសូត្រ លោកសម្ដែងថា មិច្ឆាទិដ្ឋិំ មិច្ឆាទិដ្ឋីតិ បជានាតិ សម្មាទិដ្ឋិំ សម្មាទិដ្ឋីតិ បជានាតិ អយំ សម្មាទិដ្ឋិ ហោតិ ។ ប្រែថា បុគ្គលដឹងច្បាស់នូវមិច្ឆាទិដ្ឋិ ថាជា មិច្ឆាទិដ្ឋិ, ដឹងច្បាស់នូវសម្មាទិដ្ឋិ ថាជាសម្មាទិដ្ឋិ, ការដឹងនេះ ឈ្មោះថាសម្មាទិដ្ឋិ ។ ន័យនេះ សមនឹងពាក្យខ្មែរថា ដឹងខុស ថាខុស ដឹងត្រូវ ថាត្រូវ, ការដឹងបែបនេះ ឈ្មោះថាយល់ត្រូវ ។

តើដឹងនូវមិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិដូចម្ដេច ?

មិច្ឆាទិដ្ឋិ គឺទិដ្ឋិខុស គឺការយល់ឃើញខុស សំដៅយក នត្ថិកទិដ្ឋិ ឬ មិច្ឆត្តវត្ថុ ១០ យ៉ាងគឺ

១- នត្ថិ ទិន្នំ ទានដែលបុគ្គលឲ្យហើយមិនមានផល

២- នត្ថិ យិដ្ឋំ ការបូជាតូច មិនមានផល

៣- នត្ថិ ហុតំ ការបូជាធំ មិនមានផល

៤- នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ មិនមានផលវិបាករបស់កម្មដែលសត្វធ្វើហើយល្អ និង អាក្រក់ទេ

៥ នត្ថិ អយំ លោកោ លោកនេះ មិនមាន

៦- នត្ថិ បរោ លោកោ លោកដទៃ មិនមាន

៧- នត្ថិ មាតា មាតា មិនមានគុណ

៨ នត្ថិ បិតា បិតា មិនមានគុណ

៩- នត្ថិ សត្តា ឱបបាតិកា សត្វជាឱបបាតិកៈ កំណើត មិនមាន

១០- នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ មិនមានពួកសមណ-ព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិ ត្រូវជឹងយ៉ាងចម្លែកហើយ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយខ្លួនឯង ហើយត្រាស់ដឹងនូវលោកនេះ និងលោកដទៃទេ ។

ការដឹងច្បាស់ថា ការយល់បែបនេះ ជាការយល់ឃើញខុស

ហៅថា ការដឹងនូវមិច្ឆាទិដ្ឋិ ថាជា មិច្ឆាទិដ្ឋិ ។

ការដឹងនូវសម្មាទិដ្ឋិ ថាជា សម្មាទិដ្ឋិ តើដូចម្តេច ?

សម្មាទិដ្ឋិ មាន ២ យ៉ាងគឺ លោកិយសម្មាទិដ្ឋិ ១ លោកុត្តរសម្មាទិដ្ឋិ ១

១- លោកិយសម្មាទិដ្ឋិ គឺការយល់ឃើញរបស់បុថុជ្ជននិងសេខបុគ្គល សំដៅយកសម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកបុណ្យ ឲ្យផលជាឧបធិកិលេស គឺយល់ច្បាស់ក្នុងរឿង ១០ យ៉ាង គឺ

១- អត្ថិ ទិន្នំ ទានដែលបុគ្គលឲ្យហើយ មានផល

២- អត្ថិ យិដ្ឋំ ការបូជាតូច មានផល

៣- អត្ថិ ហុតំ ការបូជាធំ មានផល

៤- អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ ផលវិបាករបស់កម្ម ដែលសត្វធ្វើហើយ ល្អនិងអាក្រក់មាន

៥- អត្ថិ អយំ លោកោ លោកនេះ មាន

៦- អត្ថិ បរោ លោកោ លោកដទៃ មាន

៧- អត្ថិ មាតា មាតាមានគុណ

៨- អត្ថិ បិតា បិតាមានគុណ

៩- អត្ថិ សត្តា ឱបបាតិកា សត្វជាឧបបាតិកៈកំណើតមាន

១០ អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិត្រូវ ដឹងយ៉ាងចម្លែកហើយ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ហើយត្រាស់ដឹងនូវលោកនេះនិងលោកដទៃមាន ។ ការដឹងច្បាស់ថា ការយល់បែបនេះ ជាការយល់ឃើញត្រូវ ហៅថា ដឹងនូវសម្មាទិដ្ឋិ ថាជាសម្មាទិដ្ឋិ ។

២– លោកុត្តរសម្មាទិដ្ឋិ សំដៅយកទិដ្ឋិរបស់ព្រះអរិយបុគ្គល ដែលមិនមានអាសវៈ, ជាលោកុត្តរៈ មានពុទ្ធដីកាក្នុងមហាចត្តារីសកសូត្រថា យា ខោ ភិក្ខវេ អរិយចិត្តស្ស អនាសវចិត្តស្ស អរិយមគ្គង្គិនោ អរិយមគ្គំ ភាវយតោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ សម្មាទិដ្ឋិ មគ្គង្គំ អយំ ភិក្ខវេ សម្មាទិដ្ឋិ អរិយា អនាសវា លោកុត្តរា មគ្គង្គា ម្នាលភិក្ខុទាំងឡាយ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ សម្មាទិដ្ឋិ អង្គនៃមគ្គរបស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ, អ្នកបរិបូណ៌ដោយអរិយមគ្គ, ម្នាលភិក្ខុទាំងឡាយ នេះ ឈ្មោះថា សម្មាទិដ្ឋិដ៏ប្រសើរមិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ ។

កាលដែលបុគ្គលមានសម្មាទិដ្ឋិហើយ រមែងមានចិត្តជាកុសល ជឿបុណ្យ បាប គុណ ទោស ល្អ អាក្រក់ ហេតុផល របស់ខ្លួនឲ្យតាំងនៅក្នុងសុចរិត មានទានសីលភាវនាជាដើម ហើយប្រឹងលះបង់អកុសលកម្ម ។ សម្មាទិដ្ឋិនេះហើយដែលអាចបំភ្លឺសត្វលោក ឲ្យឃើញពន្លឺអរិយសច្ច ៤ គឺ

១- ទុក្ខៈ សេចក្ដីទុក្ខលំបាក គឺអត់ទ្រាំទ័រក្នុងទុក្ខ ក្នុងកិលេស មានជាតិ ជរា មរណៈ ជាដើម

២- ទុក្ខសមុទយៈ តណ្ហាជាមេបណ្ដាលឲ្យកើតទុក្ខ

៣- ទុក្ខនិរោធៈ សេចក្ដីរលត់ទុក្ខ គឺព្រះនិព្វាន

៤- ទុក្ខនិរោធគាមិនីបដិបទា មជ្ឈិមបដិបទា (ផ្លូវកណ្ដាល) នាំឲ្យទៅកាន់រំលត់ទុក្ខ ។

បើមានសម្មាទិដ្ឋិហើយ សម្មាទិដ្ឋិអាចបំភ្លឺក្នុងសម្មាសង្កប្បៈ គឺការត្រិះរិះត្រូវ មាន ៣ យ៉ាងគឺ ៖

១- នេក្ខម្មសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការចេញចាកកាម គឺការចេញបួស

២- អព្យាបាទសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការមិនព្យាបាទ គំគុំគួន

៣- អវិហឹសាសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការមិនបៀតបៀនគេ

សម្មាសង្កប្បៈ ជាពន្ទឹកនៃ សម្មាវាចា គឺ ការពោលពាក្យត្រូវ មាន ៤ យ៉ាងគឺ

១- មុសាវាទា វេរមណី ការវៀរចាកពាក្យកុហក

២- បិសុណាយ វាចាយ វេរមណី ការវៀរចាកពាក្យញុះញង់

៣- ផរុសាយ វាចាយ វេរមណី ការវៀរចាកពាក្យទ្រគោះបោះបោកគគ្រោះគគ្រើយ

៤- សម្ផប្បលាបា វេរមណី ការវៀរចាកពាក្យពេលរាយឥតប្រយោជន៍ ។

សម្មាវាចា ជាពន្ទឹកនៃសម្មាកម្មន្តៈ គឺការងារត្រូវ មាន ៣ យ៉ាង គឺ

១- បាណាតិបាតា វេរមណី ការវៀរចាកការសម្លាប់សត្វ

២- អទិន្នាទានា វេរមណី ការវៀរចាក ការកាន់យកវត្ថុដែលគេមិនបានឲ្យ

៣- កាមេសុ មិច្ឆាចារា វេរមណី ការវៀរចាក ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

សម្មាកម្មន្តៈ ជាពន្ទឹកនៃសម្មាអាជីវៈ គឺការចិញ្ចឹមជីវិតត្រូវ បើជាគ្រហស្ថ បានខាងការៈវៀរចាកជំនួញខុស ៥ យ៉ាង ការកែបំបាត់,

ការលះអៀនអគតិ, ហើយចិញ្ចឹមជីវិតដោយសុចរិត យុត្តិធម៌, បើជាបព្វជិត បានខាងការលះបង់ មិច្ឆាជីវ: គឺការចិញ្ចឹមជីវិតខុស ដោយអនេសនបាបធម៌ មានខ្ជូតកម្ម វេជ្ជកម្មជាដើម ហើយចិញ្ចឹមជីវិត ដោយបច្ច័យដែលកើតដោយធម៌ ។

សម្មាអាជីវ: ជាភ្ទឹផល់ សម្មាវាយាម: គឺការព្យាយាមត្រូវ មាន ៤ យ៉ាងគឺ

១- សំវរប្បធាន ព្យាយាមរាំង មិនឲ្យអកុសលធម៌កើតឡើងបាន

២- បហានប្បធាន ព្យាយាមលះអកុសលធម៌ដែលមាននៅក្នុងខន្ធសន្តានហើយ ឲ្យសាបសូន្យទៅ

៣- ភាវនាប្បធាន ព្យាយាមបំពេញកុសលធម៌ ឲ្យចម្រើនរឹងប៉ឹងក្នុងខន្ធសន្តាន

៤- អនុរក្ខនាប្បធាន ព្យាយាមរក្សាឃុំគ្រង កុសលធម៌ដែលបានធ្វើហើយ ឲ្យបានគង់វង់ ។

សម្មាវាយាម: ជាព្ទឹក្នង សម្មាសតិ គឺការរលឹកត្រូវ មាន ៤ យ៉ាងគឺ

១- កាយានុបស្សនាសតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយ ៗ ក្នុងកាយ

២- វេទនានុបស្សនា សតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយ ៗ ក្នុងវេទនា

៣- ចិត្តានុបស្សនាសតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយ ៗ ក្នុងចិត្ត

៤- ធម្មានុបស្សនាសតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយ ៗ ក្នុងធម៌ ។

សម្មាសតិ ជាពន្លឺក្នុង សម្មាសមាធិ គឺ ការតម្កល់ចិត្តត្រូវ ក្នុងឈាន ៤ ដែលស្ងប់ស្ងាត់ចាកកាមទាំងឡាយ, ចាកអកុសលធម៌ ហើយលះនូវអង្គ តាមលំដាប់លំដោយគឺ

១- បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតពីវិវេក ។

២- ទុតិយជ្ឈាន រម្ងាប់វិតក្កៈ វិចារៈថ្លាល្អ មានបីតិនិងសុខ ដែលកើតពីវិវេក ។

៣- តតិយជ្ឈាន ប្រាសចាក បីតិ ប្រកបដោយសុខៈនិងឧបេក្ខា ។

៤ ចតុត្ថជ្ឈាន លះបង់សុខទុក្ខ មិនមានសោមនស្សទោមនស្ស មានសតិប្រកបដោយឧបេក្ខាដ៏បរិសុទ្ធ ។

សម្មាសមាធិ ជាពន្លឺ ដល់សម្មាញាណៈ គឺការដឹងត្រូវ ។

សម្មាញាណៈ ជាពន្លឺដល់សម្មាវិមុត្តិ ការរួចស្រឡះគឺព្រះនិព្វាន ។

ការសម្តែងអំពី អដ្ឋង្គិកមគ្គ ដោយសង្ខេបចប់ត្រឹមតែប៉ុណ្ណោះ ។

(ស្រង់ពីសៀវភៅធម្មទាន បោះពុម្ពចែក ក្នុងការរំលាយសព
ព្រះសុមេធវង្ស ប្រាជ្ញ ប៉ុល វត្តឧណ្ណាលោម)

# វិចារណកថា

## រឿងអាប៉ូឡូទី ១១ របស់អាមេរិកាំង

សតវត្សទី ២០នេះ ពិសេសគឺផ្នែកអន្លសតវត្សទី ២ បានត្រូវគេកំណត់ទុកជាសតវត្សប្រកបដោយវឌ្ឍនភាព ខាងវិទ្យាសាស្ត្រនិងខាងបច្ចេកទេសថ្នាក់កម្រិតកំពូល ដែលមនុស្សលោកមិនធ្លាប់បានស្គាល់ម្តងណាសោះចាប់តាំងពីសម័យ មុនមានប្រវត្តិសាស្ត្រ និងមានប្រវត្តិសាស្ត្រមកម៉្លេះ ដោយតែវឌ្ឍនភាពខាងវិទ្យាសាស្ត្រនិងខាងបច្ចេកទេសផ្សេងៗ មានអវកាសយានប្រកបដោយល្បឿនលឿនជាងសម្លេង វិទ្យុ ទូរទស្សន៍ គ្រាប់បែកបរមាណូ ។ល។ ចេញ មានសមិទ្ធិមួយដ៏អស្ចារ្យបំផុតនៃមនុស្សលោក គឺយានអវកាសដែលអាចបង្ហោះឲ្យទៅចុះចតនៅលើឋានព្រះចន្ទបាន ជាឋានដែលមនុស្សលោកមិនដែលយល់សប្តិ មិនដែលនឹកស្មានថានឹងមានមនុស្សអាចនឹងបានទៅដល់ម្តងណាសោះឡើយ ។ យានអវកាសនេះជារបស់ជនជាតិអាមេរិកាំង ឈ្មោះអាប៉ូឡូទី ១១ ដែលមានមនុស្ស បីនាក់ជិះក្នុងនោះគឺឈ្មោះអាំស្ត្រុង១ អេដវិនអាល់ឌ្រិន ១ មិកាអែលខុល្លីន ១ ។

ជនក្លាហានទាំងបីរូបនេះ បានជិះអាប៉ូឡូទី ១១ ដែលមានអ្នកប្រាជ្ញម្នាក់ជាជនជាតិអល្លឺម៉ង់ ហើយដែលត្រូវអាមេរិកាំងចាប់យកមកឲ្យនៅក្នុងប្រទេសរបស់ខ្លួន ខាងក្រោយសង្គ្រាមលោកលើកទី ២ ជាអ្នកធ្វើ

ហោះទៅកាន់ឋានព្រះចន្ទនៅថ្ងៃទី ១៦ កក្កដា ១៩៦៩ ហើយបានទៅចុះចតលើឋានព្រះចន្ទមុនគេបង្អស់នៅថ្ងៃចន្ទ ទី ២១-៧-៦៩ ពេលម៉ោង ៣ ព្រឹកទៀបភ្លឺ ។ ចម្ងាយពីផែនដីទៅព្រះចន្ទ មានចំនួន ៣៨៤.៤០០ គីឡូម៉ែត្រ សូមបញ្ជាក់ថា អ្នកទាំងបីនាក់នេះពុំបានចុះទាំងអស់គ្នាទៅលើព្រះចន្ទទេ គឺមានតែពីរនាក់ប៉ុណ្ណោះដែលបានចុះទៅលើព្រះចន្ទ គឺអាំស្ត្រង និង អេដវិនអាល់ឌ្រិន តាមចន្ទយានអវកាសមួយឈ្មោះ "ឡេម" ផ្ដាច់ចេញពីយានអវកាសធំចំណែកឯមិកាអែលខុលិន នៅហោះវិលចាំពីខាងលើជាមួយយានអវកាស ។ ឯជនទាំងពីរនាក់នោះចុះនៅលើឋានព្រះចន្ទក្នុងរយៈពេលតែជាងពីរម៉ោងប៉ុណ្ណោះដោយការប្រុងប្រយ័ត្នជាទីបំផុត រួចនាំគ្នាប្រមូលយកវត្ថុផ្សេង ៗ ពីឋានព្រះចន្ទបានចំនួន ៥០០ មុខ មានទម្ងន់ទាំងអស់ ៣១ គីឡូក្រាម ហើយក៏ប្រញាប់តឡើងជិះយានពិសេសឈ្មោះ "ឡេម" ក៏ហោះឆ្ពោះទៅរកយានអវកាសធំ ដែលមានឈ្មោះខុលុំប កំពុងបង្ហោះវិលចាំនៅពីខាងលើនោះ ។ លុះនាំគ្នាឡើងទៅជិះក្នុងយានអវកាសធំអស់ហើយ គេក៏ផ្ដាច់ម្ញាក់ចន្ទឡេមនៅលើឋានព្រះចន្ទទុកចោលនៅទីនោះ មិនតែប៉ុណ្ណោះ មុននឹងថយចេញពីព្រះចន្ទ គេបានទាំងដោតទុកនៅទីនោះ នូវទង់ជាតិអាមេរិកាំង ១ នូវប្រដាប់ផ្សេងដទៃទៀតពីរគ្រឿង (ប្រដាប់ថតសំឡេង ប្រដាប់វិទ្យុទូរទស្សន៍) ជានិមិត្ត-រូបនៃជោគជ័យមនុស្សជាតិជាលើកដំបូងបំផុត (ក្នុងកប្បនេះ) ។ រួច

គេនាំគ្នាបង្ហោះយានអវកាសវិលត្រឡប់មកវិញ បានមកចុះក្នុងមហាសាគរប៉ាស៊ីហ្វិក ក្បែរកោះមួយឈ្មោះហាវ៉ៃ នៅថ្ងៃព្រហស្បតិ៍ ២៤-៧-៦៩ ពេលម៉ោង១១ ប៉ាយ តាមរយៈវេលាដែលគេបានកំណត់ទុកពីមុននោះៗ

រឿងនេះ មានការសង្កេតពិនិត្យ ឃើញថាមានពិតប្រាកដអ៊ុំចឹងមែន ព្រោះមុនបង្ហោះអាប៉ូឡូទី ១១ ឲ្យទៅកាន់ឋានព្រះច័ន្ទ គេបានបង្កើតស្ថានីយ ៧ កន្លែងសម្រាប់ចុះពិនិត្យតាមមើលថាទៅដល់មែនមិនមែន ៗ ឯស្ថានីយទាំងប្រាំពីរនោះ គឺ ពីរនៅប្រទេសអាមេរិក ពីរនៅប្រទេសជប៉ុន ពីរនៅប្រទេសអូស្ត្រាលី និងមួយនៅក្នុងទ្វីបអឺរ៉ុប ៗ ដូច្នេះមិនគប្បីសង្ស័យចំពោះរឿងនេះឡើយ ៗ បានជាថាមិនគប្បីឲ្យសង្ស័យ ព្រោះសហភាពសូវៀតក៏ត្រូវការប្រជែងប្រណាំង ក្នុងដំណើរទៅកាន់ឋានព្រះច័ន្ទនេះដែរ ធ្វើម្តេចនឹងបណ្តោយឲ្យសហរដ្ឋអាមេរិកលេងល្បែងបួនសន្លឹកជាមួយខ្លួនបាន ៗ ឥឡូវសហភាពសូវៀតក៏បានទទួលស្គាល់ថាអ៊ុំចឹងមែន ព្រមទាំងបានថ្លែងសេចក្តីសរសើរ ចំពោះសហរដ្ឋអាមេរិកផងដែរទៀត ។

ចំពោះវឌ្ឍនភាពខាងវិទ្យាសាស្ត្រ និងខាងបច្ចេកទេស ត្រូវតែសរសើរទទួលស្គាល់ថាយ៉ាងដូច្នេះមែន តែចំពោះសីលធម៌ សន្តិភាព និងសន្តិមកិច្ចវិញ មិនត្រូវសរសើរទាល់តែសោះ ៗ ពួកអាមេរិកាំងពូកែខាងវិទ្យាសាស្ត្រ និងខាងបច្ចេកទេសពិតប្រាកដមែនតែបែរជាទ្រាយ

ខាងសីលធម៌ ខាងសន្តិភាព និងខាងសង្គមកិច្ច ណាស់ដែរ ។ ព្រោះថា ការរៀបចំធ្វើយានអវកាស សម្រាប់បង្ហោះឲ្យទៅកាន់ឋានព្រះច័ន្ទនេះ ត្រូវចាយប្រាក់អស់ចំនួន២០ ពាន់លានដុល្លារ បើគិតមកជាប្រាក់យើងត្រូវជា ៧០០ ពាន់លានរៀល ។ បើតាមការសង្កេតទៅ ឃើញថាចំណាយប្រាក់អស់ដ៏យ៉ាងសម្បើមប៉ុណ្ណោះ នេះបានតែត្រឹមទៅដល់ឋានព្រះច័ន្ទប៉ុណ្ណោះ ក្រៅពីនេះគឺសូន្យ ។ ដូច្នេះ សីលធម៌នៃជនជាតិអាមេរិកាំងចំពោះមនុស្សជាតិ ពិសេសចំពោះជនជាតិអាមេរិកាំងស្បែកខ្មៅ ដែលអាស្រ័យនៅក្នុងប្រទេសជាមួយ គឺផុតទទេស្អាត បានសេចក្តីថា អាមេរិកាំងស្បែកសនៅតែនិយមប្រមាថមើលងាយ បណ្តោយទុកឲ្យគ្នារងទុក្ខវេទនា ជារៀងរាល់ថ្ងៃ ពោះបីគ្នាខ្វះខាតខាងសម្ភារៈ ដូចម្តេចក្តី ខ្លួនគិតតែពីចាយប្រាក់ពាន់លានៗ សម្រាប់ស្វែងរកកិត្យានុភាព ស្វែងរកការកោតសរសើរ ស្វែងរកមហិទ្ធិឫទ្ធិ ដើម្បីតាំងខ្លួនជាម្ចាស់ពិភពលោក ។ សព្វថ្ងៃមានតែប្រទេសដែលមានសីលធម៌ ខ្សោយបំផុតដូចជាខ្លួនទេ ដែលនិយមសរសើរជោគជ័យ ប្រាសចាកហេតុផលនៃ អាមេរិកាំងនេះ ដ្បិតថាប្រសិនបើគេយកប្រាក់ចំនួនដ៏សម្បើមនេះ មកចាយប្រើប្រាស់ សម្រាប់កសាងមន្ទីរពេទ្យ សម្រាប់ជួយដោះទុក្ខ នៃជនក្រីក្រ សម្រាប់ស្ថាបនាសាលារៀន ។ល។ មិនដឹងជាបានប៉ុន្មានឡើយ ។ ដូច្នេះ យើងអាចជឿបានថាជនជាតិអាមេរិកាំង ជាមនុស្សខ្លាំងពូកែបានដែរឬទេ?

ខ្លាំងពូកែមែន ខ្លាំងពូកែចំពោះតែទៅលើអំពើទុច្ចរិត ទៅលើអំពើកាម សាហាវទៅលើអំពើឈ្លានពាននិងជិះជាន់អ្នកដទៃ ។ ប្រសិនបើយើងសរសើរអាមេរិកាំង គប្បីតែសរសើរមនុស្សប្រព្រឹត្តចោរកម្មផងទើបត្រូវ គប្បីតែគប់រកមនុស្សកំណាចឃោរឃៅផងទើបសម ។

ព្រះពុទ្ធបរមគ្រូទ្រង់សម្តែងថា អ្នកមានបញ្ញាគឺសំដៅទៅលើបុគ្គលណាដែលចេះធ្វើខ្លួនឯងឲ្យបានសុខផង និងធ្វើអ្នកដទៃឲ្យបានសុខផង ។ រីឯអ្នកដែលចេះតែធ្វើខ្លួនឲ្យបានសុខ ហើយដែលធ្វើអ្នកដទៃឲ្យបានទុក្ខ នោះពុំមែនមានឈ្មោះថា អ្នកមានបញ្ញាឡើយ ។ បើដូច្នេះ ចំពោះអាមេ-រិកាំងតើត្រូវថាដូចម្តេចទៅវិញ ? ត្រូវហៅថា អ្នកទុប្បញ្ញា ប្រែថាអ្នកមានបញ្ញាអាក្រក់ គឺថាអ្នកខ្វះបញ្ញាតែម្តង ។ សត្វតិរច្ឆានដែលខាងកាចសាហាវមានខ្លា ពស់ក្រពើជាដើម តើយើងនិយមទុកពួកវាថាជាសត្វមានបញ្ញាដែរឬទេ ? ឆ្លើយថា ជាសត្វឥតមានបញ្ញាទាល់តែសោះ ព្រោះបើវានៅទីណា វាតែងសាបព្រោះមហន្តរាយគ្រប់បែបយ៉ាងនៅទីនោះ ។ ហេតុអ្វីបានជាវាគិតតែពីសាបព្រោះនូវសេចក្តីទុក្ខព្រួយ នៅលើអ្នកដទៃ? ថាព្រោះវាមិនដឹង វាគ្មានបញ្ញាសម្រាប់ជាគ្រឿងត្រិះរិះ បានជាវាធ្វើដូច្នេះទៅកើត ដោយអាងតែទៅលើពលានុភាព របស់វាប៉ុណ្ណោះ ។ សេចក្តីនេះឧបមាយ៉ាងណា រឿងអាមេរិកាំងក៏មានឧបមេយ្យដូច្នោះ ។

ស្មៅផុះច្រុលគ្របនៅក្បែរដើមសសរផ្ទះរបស់ខ្លួន មិនគិតជម្រះឲ្យ

ស្អាត ប៉ែរជាទៅគិតសំអាតស្មៅឯឋានព្រះចន្ទទៅវិញ ។ តើមនុស្សប្រភេទនេះត្រូវគេចាត់ទុកជាពពួកមនុស្សបែបណា?

ឥឡូវឮដំណឹងថាមិនទាន់អស់ចិត្តទេ ដែលគ្រាន់តែទៅដល់ឋានព្រះចន្ទប៉ុណ្ណោះ ពួកអាមេរិកាំងបំរុងធ្វើយានអវកាសឲ្យហោះចូលទៅរកផ្កាយទាំងឡាយផងទៀត មានផ្កាយព្រះអង្គារ ផ្កាយព្រះសុក្រជាដើម ព្រោះតាមការពិនិត្យរបស់គេទៅ ឃើញថាផ្កាយប្រហែលអាចឲ្យមនុស្សរស់នៅបានមិនដូចជាឋានព្រះចន្ទដែលមានសុទ្ធតែថ្មនោះទេ ។

សូមអ្នកអានជាទីមេត្រីទាំងឡាយ មេត្តាពិចារណាឲ្យហ្មត់ចត់បន្តិចល្បងមើលថា តើពួកចក្រពត្តិនិយម ដែលអួតអាងព្រមទាំងតាំងខ្លួនជាមេលទ្ធិប្រជាធិបតេយ្យជាមេលទ្ធិសេរីភាពនោះ និយមប្រកាន់យកនូវគំនិតអ្វីនិយមប្រាថ្នាអ្វី និយមប្រកាន់យកយ៉ាងជាប់ខាត នូវចំណូលអ្វី?

បើតាមយោបល់ខ្ញុំ គ្មានអ្វីក្រៅពីមហិច្ឆតា របស់គេតែប៉ុណ្ណោះ ។ ដទៃពីនេះ គេគ្មានគិតរវីរវល់ គ្មានឈឺក្បាលនឹងអ្នកណាឡើយ ទោះបីខ្លួនរងទុក្ខវេទនា លំបាកគោកយ៉ាក ទោះបីខ្លួនស្លាប់ព្រាត់ប្រាសគ្រួសារដូចម្តេចក្តីគេធ្វើយ៉ាងណាឲ្យតែមហិច្ឆតារបស់គេ បានសម្រេច ។

រួមសេចក្តីទៅ យើងមិនត្រូវអើពើនឹងសមិទ្ធិដ៏ចម្លែកនៃចក្រពត្តិនិយមទេ ជាសមិទ្ធិដែលគ្មានផ្តល់លទ្ធផលដ៏ប្រសើរដល់មនុស្សលោកនោះ ។ សូមឲ្យចក្រពត្តិនិយមបន្តពង្រីកសមិទ្ធិចម្លែកនេះតទៅទៀតចុះ យើងជាជន

ជាតិអាស៊ី ពិសេសជនជាតិខ្មែរ ត្រូវតែចំប្រឹងស្ថាបនាជាតិខ្លួន តាមព្រះមាគ៌ានយោបាយនៃសម្តេចឪយើងតទៅទៀត ទើបបានប្រសើរ ទើបបានសេចក្តីសុខសេចក្តីចំរើន ។ ព្រោះនៅឯផែនដីយើង ក៏មិនខ្វះកិច្ចការប្រកបដោយប្រយោជន៍នឹងបំពេញឡើយ ។

ឈេង-ជ្រីវ

## ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង-ខាត់ រៀបរៀង*

អភិឝៅរិ ក្រ.វិ. ដោយប្រឆាំងចំពោះព្រះក្រឹស្ណ ។

អភិឝ្រិ ធាតុ ពឹងពាក់ ។

អភិឝ្រុ ធាតុ ស្តាប់ក្រៃលែង ស្តាប់ដោយយកចិត្តទុកដាក់។

អភិឝ្វស៑ ធាតុ ហូត ថ្ងូរឈឺចាប់ ។

អភិឞង្គ បុំ. កិរិយាលំអៀង, អភ័ព្វ ។ ឞង្គិន៑

គុ. ដែលធ្វើឲ្យអាមាសមុខ ។

អភិឞញ្ជ៑ (សញ្ជ៑) ធាតុ ពោលពាក្យអសុរោះ ។

អភិឞវ បុំ. ឞវណ នបុំ. កិរិយាមុចទឹក ។

អភិឞហ៑ ធាតុ បៀតបៀន ប្រយុទ្ធ ។

អភិឞិច៑ ធាតុ ស្រោចទឹក អភិសេក ។ ឞិក្ត គុ. ដែល

ស្រោះព្រំ ។

| | | |
|---|---|---|
| អភិបិញ្ជន | នបុំ. | កិរិយាប្រោះព្រំ ។ |
| អភិបិមេណាយិមុ | គុ. | ដែលរៀបចំតទល់ ។ |
| អភិមុ (សុ) | ធាតុ | គាបក្រៃលែង សង្កត់ ។ |
| អភិមូទ (សូទ) | ធាតុ | សម្លាប់ ។ |
| អភិមេក | បុំ. | អភិសេក ។ |
| អភិមេចន | នបុំ. | កិរិយាស្រោច កិរិយាប្រោះព្រំ ។ |
| អភិមេចនីយ | គុ. | ដែលគប្បីអភិសេក ។ |
| អភិមុតិ | បុំ. | អភិស្ដុប កិរិយាសរសើរ កិរិយាបញ្ចោរ ។ |
| អភិមុ (ស្ដុ) | ធាតុ | សរសើរ ពោលពាក្យសរសើរ ។ |
| អភិប្ឋា (ស្ឋា) | ធាតុ | ឈរ តាំងនៅ រស់នៅ ។ |
| អភិម្យន្ទ (ស្យន្ទ) | ធាតុ | រត់តម្រង់ ភ្លៀង ដោរ ។ |
| អភិម្យន្ទ | បុំ. | ភាវហួសប្រមាណ ភាពសម្បូណ៌ហួរហៀរ ។ |
| អភិមង្គ | បុំ. | កិរិយាជាប់ជំពាក់ក្រៃលែង ។ |
| អភិបូញ្ជ ស្វញ្ជ | ធាតុ | ពទ្ធ,ឱប ។ |
| អភិសំយត្ត | គុ. | ដែលទាំងដោយ (ស៊េះ)ដែលនាំដោយ ។ |
| អភិសំយា | ធាតុ | រំចាណរុកជំ, ដែលធ្វើអុកឡុក ។ |

អសំយុត្ត គុ. ដែលប្រកប ។

អភិសំរត្ត គុ. ដែលជាប់ដោយ ។

អភិសំរទ្ធ គុ. ដែលនាំឲ្យកើត, បេហរយៅ ។

អភិសំរភ (សំរភ) គុ. កំពេល ។ ចុំ. មនុស្សកំរោល។

អភិសំរាធន នបុំ. កិរិយាធ្វើឲ្យពេញចិត្ត ឬ ធ្វើឲ្យធូរស្រាល។

អភិសំរុធ ធាតុ បញ្ឈប់ ។ រុទ្ធ គុ.ដែលបិទបាំង។

អភិសំភិញ្ញ ធាតុ ប៉ិន, ប្រាជ្ញា ។

អភិសំរិគ៌ ធាតុ រំលាយធ្វើ ។ រួបរួម ។

អភិសំរិក្ខ ធាតុ ក្រឡេកមើល ។

អភិសំរុប ធាតុ បំបាំង។ រុប្ត គុ. ដែលបំបាំង ដែល
លាក់ ។

អភិសំរុគ្គ គុ. ដែលទទួលធ្វើ។

អភិសំរុឌ្ឍ គុ. ចាស់ទ្រុល ចាស់ណាស់។

អភិសំគ្រយ បុំ. អភិសំស្រ័យ,ផ្គួក កិរិយាភាពទងចំពាក់

អភិសំគ្រិ ធាតុ អភិដ្ឋានខ្លួន ពឹងពាក់ ។ គ្រិត គុ.
ដែលរត់ទៅជ្រក ដែលទៅជួប ។

អភិសំគ្រ ធាតុ ស្ដាប់និយាយ ។

អភិសំគ្លប៊ ធាតុ ផ្គាប ចង់ផ្គាបគ្នា ។

អភិសំស្ឫ ធាតុ ឈោតស្ទុះទៅ។ ស្ឫត គុ. ដែលមកជិត។

អភិសំស្កឫត គុ. ដែលលំអក្រៃលែង ។

អភិសំស្តម្ភ ធាតុ ធ្វើឲ្យជួបសសរ ពង្រឹង ។

អភិសំស្ដីណ៌ គុ. ដែលពាសពេញសព្វ ដែលតោរដាស ។

(នៅមានតទៅ)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ឆូ-កាង

ប្រែ-រៀបរៀង

(៣)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ    អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន    ទាំងមានសន្តានស្នេហាជាតិ
>
> យូរ-អ៊ុន

ជូឡុងក៏និយាយនឹងអ៊ុយអៀនថា តាំងពីយើងធ្លាប់ធ្វើសង្គ្រាមរៀងមក ក៏មិនដែលបានឃើញក្បួនទ័ពជាចំឡែកយ៉ាងនេះសោះ, ឥឡូវ យើងគិតយ៉ាងម្ដេចទើបនឹងមានជ័យជម្នះ, ទទួលឮសំឡេងគោង, ក្រឡេកទៅឃើញបុកឡុកតែអងកយមន្តលើខ្នងដំរី ១ ស្របក់ ក៏កើតជាព្យុះខ្យល់បក់បោកអណ្ដែតដុំធ្លាក់ចុះមក បីដូចគ្រាប់ភ្លៀង ហើយបានឮសំឡេងបុកឡុកតែអងផ្លុំត្រែស្នែងក្របី, សត្វកាចក៏រត់ចេញពីក្នុងព្រៃជាច្រើន សម្ដែងរិទ្ធិតេជះបោលចូលមកក្នុងកងទ័ពជូឡុង ។ ឃើញដូច្នោះ ក៏ថយទ័ពត្រឡប់ចូលបន្ទាយ និយាយរឿងរ៉ាវជម្រាបខុងបេងគ្រប់ប្រការ ហើយក៏អង្វរសុំទោសដែលទៅធ្វើការបរាជ័យនឹងខ្មាំងសត្រូវ ។

ខុងបេងបានស្ដាប់ក៏អស់សំណើច ហើយថា អ្នកកុំព្រួយជាទុក្ខឡើយ

ព្រោះសត្រូវនោះ ក៏មានសិល្បវិជ្ជាលើសប្រាជ្ញអ្នក ៗ មិនមានទោសទេ, ដែលបុកឡុកតែអង់មានវិជ្ជាយ៉ាងនេះ យើងក៏អាចទឹងជឹងដល់ តាំងបាន បម្រុងទឹងធ្វើកលខល់ប្រាជ្ញាសព្វគ្រប់ហើយ, ខុងបេងក៏ឲ្យទាហានទៅយក រទេះដែលត្រៀមទុកតាំង១១រទេះនោះមកបើកគម្របដែលគ្របចេញ, ក្នុង រទេះនោះមិញ មានសឹងរូបសត្វកាចផ្សេង ៗ ចំនួន ១០០ ធ្វើដោយឈើ លាបថ្នាំធ្វើឲ្យដូចរូបសត្វ ហើយលុងខាងក្នុងពោះរូបនោះ ដាក់រំសេវនិង គ្រាប់, មានយន្តសម្រាប់ទាញវង្វិលឲ្យវើរបានគ្រប់រូប; ខុងបេងក៏ជ្រើស រើសទាហានដែលមានកម្លាំងចំនួន ១.០០០ នាក់ សម្រាប់អមនាំរូបសត្វ ១ មនុស្ស ១០ នាក់, លុះដល់ពេលព្រឹក ក៏ឲ្យលើកទាហានតម្រង់ចូលទៅ ក្នុងស្រុកងិនខែ, ឯខ្លួនខុងបេង ក៏លើកពលតាមទៅជាក្រោយ ៗ

ឯបុកឡុកតែអង់បានជ័យជម្នះហើយ ក៏លើកទ័ពត្រឡប់ចូលស្រុក, បេងហោក ក៏តែងតុលៀងគោជនាហារ, ខ្លួលមានបម្រើចូលទៅប្រាប់ថា ខុងបេងលើកទ័ពអកញ្ញាំង; បុកឡុកតែអង បានឮដូច្នោះ ក៏ថា ខុងបេង នៅមិនទាន់ញញើតច្ចីដៃយើងទេឬ បានជាហ៊ានលើកទ័ពចូលមកទៀត ? ហើយក៏ចាត់ចែងទាហានទិងបេងហោកចេញចាកស្រុក, ខ្លួលខុងបេង លើកទ័ពមកដល់, បេងហោកក៏លើកដៃទ្វើងចង្អុលបង្ហាញបុកឡុកតែអង ថា ដែលពាក់មួកក្រហម នៃងគួជាមហាឧបរាជ កាន់ផ្ចិតអង្គុយលើរទេះ តូចនោះ គឺខុងបេង, បើប្រសិនយើងចាប់ខ្លួនបានហើយ ផែនដីរបស់

យើង ក៏នឹងបានសេចក្តីសម្រាន្តសុខ; បុកឡុកគៃគង បានឮដូច្នោះ ក៏គោះគាំងកាយមន្ត ហៅឲ្យកើតខ្យល់ព្យុះបក់បោកអណ្តែតដុំថ្មធ្លាក់ចុះមកបីដូចគ្រាប់ភ្លៀង ហើយផ្ទុំត្រៃហៅសត្វកាចឲ្យចេញមកច្រើនណាស់ ។

ខុនបេងឃើញដូច្នោះ ក៏កាយមន្ត បោកផ្លិតឲ្យខ្យល់បក់ត្រឡប់ទៅវិញ, សត្វកាចទាំងប៉ុន្មានក៏ឈប់នៅភាំងអស់, រួចខុនបេងក៏ឲ្យយកភ្លើងរុជលម្ពសត្វ ដែលធ្លាក់លនោះ ឲ្យបោលចូលទៅក្នុងកងទ័ពបេងហោក, ហើយឲ្យកាយឃ្មោះគោះគងខុនកេវលើកទាហានទ័ពចូលទៅ, បណ្តាសត្វកាចដែលបុកឡុកគៃគងហៅមកនោះ សឹងតែត្រូវគ្រាប់ និងរបួសពិការជាសាហ័ស ក៏បោលប្រាសត្រឡប់ប្រទាក់ប្រទុន, ទាហានទាំងពួង ក៏បែកបាក់ទ័ពត្រឡប់តេចេញទៅ; ខុនបេងក៏បរពលចូលប្រកាប់ សម្លាប់បុកឡុកគៃគងស្លាប់ក្នុងទ័ពម្យាំង, បេងហោកលើកទ័ពលេះលាំងចូលទៅក្នុងស្រុកវិញ ហើយនាំកវីបោទិនស្ល័គ្រប័ក្ខពួកតែដោះខ្លួន, ខុនបេងក៏លើកទ័ពទាំងក្បួន ចូលទៅតាំងក្នុងស្រុកនិនវៃ ហើយឲ្យបំណាច់ផ្ទាន់ទាហានតាមសមគួរ រួចហើយចាត់ទាហានឲ្យលើកស្រួតទៅតាមចាប់ខ្លួនបេងហោកទៀត ។

ឯបេងហោកតេទៅនោះ ត្រូវវៃជាប្អូនប្រពន្ធ ក៏និយាយថា យើងនឹងតេទៅគ្រានេះ ក៏ឃើញថាមិនផុតពីដៃខុនបេងទេ, ខ្ញុំនឹងគិតកលឧបាយឲ្យ

ទាហាន១០០តែងខ្លួនបង្កប់អាវុធលាក់ក្នុងអាវ ហើយធ្វើជាចាប់ខ្លួនលោក
ទាំង២នាក់និងបងស្រីខ្ញុំចងនាំទៅឲ្យខុងបេង ។ គង់នឹងពេញចិត្ត ហៅខ្លួន
ខ្ញុំនិងទាហាន១០០ ដែលមានសេចក្ដីគាប់ប្រសើរ ឲ្យចូលទៅក្នុងបន្ទាយ,
ខ្ញុំនិងចាប់ខុងបេងសម្លាប់ចេញ, បេងហោក បានឮដូច្នោះ ក៏យល់ឃើញ
ត្រូវនឹងចិត្ត; គួឡៃក៏ចាប់ខ្លួនបេងហោក-បេងហ៊ី និងនាងចុកយ៉ុង ហើយ
ឲ្យទាហាន១០០នាក់ឃុំនាំទៅជាមួយនឹងខ្លួន លុះទៅដល់បន្ទាយខុងបេង
ក៏ប្រទះនឹងពួកល្បាត, គួឡៃក៏និយាយប្រាប់ពួកល្បាតថា ខ្ញុំបាននិយាយ
ហាមប្រាមបេងហោកថា ឲ្យមកសុំចំណុះចុះចូលមហាឧបរាជចុះ ក៏វាមានះ
ពុំព្រមស្ដាប់ រឹតតែចេះមកធ្វើចម្បាំងតនឹងមហាឧបរាជ ទាល់តែពល
ទាហានបានសេចក្ដីក្ដៅក្រហាយជាច្រើន, ខ្ញុំនឹកនឹងក៏ចាប់ខ្លួនបេងហោក-
បេងហ៊ីនិងភរិយាមកជូនមហាឧបរាជ, ពួកល្បាត ក៏ចូលទៅជម្រាបខុង-
បេង ។ បានឮដូច្នោះ ក៏បង្គាប់ទៀវង៉ីនិងម៉ាតង់ថា អ្នកឯង ទាំងពីរនាក់
ចូរចាត់ទាហានម្នាក់ ១.០០០ ឲ្យឈរតម្រៀបគ្នាតាមសង្កាត់ទ្វារបន្ទាយ បើ
ឃើញគួឡៃនាំបេងហោក-បេងហ៊ីចូលមក ឲ្យនាំគ្នាព្រួតចាប់ខ្លួនគួឡៃចង
ព្រមទាំងទាហានដែលមកជាមួយ នាំមកឲ្យយើង ។

ទៀវង៉ីនិងម៉ាតង់ ក៏ចេញទៅចាត់ការជាស្រេចតាមខុងបេងបង្គាប់; គួ-
ឡៃក៏នាំខ្លួនបេងហោក-បេងហ៊ីនិងបងស្រី ចូលទៅដល់ទ្វារបន្ទាយ; ខណៈ
នោះ ម៉ាតង់និងទៀវង៉ី ក៏នាំទាហានព្រួតចាប់ខ្លួនគួឡៃ និងទាហាន

១០០ នាក់បាន នាំចូលទៅ, ខុងបេងក៏ឲ្យទាហានចេញទៅបង្គាប់ថា ដែលតូឡៃនិងអស់ទាហាន បានចាប់ខ្លួនបេងហោកមកនោះ ឲ្យនាំចូលទៅចុះ, ទៀងជី និង ម៉ាតង ក៏នាំខ្លួនបេងហោក បេងហ៊ុរ តូឡៃ នាងបុកយ៉ុង និងទាហាន ១០០ នាក់ ចូលទៅគំនាប់ខុងបេង ។ ក្រឡេកឃើញតូឡៃ និងទាហានចូលទៅគំនាប់ ក៏អស់សំណើចហើយថា ដែលបេង-ហោកបានប្រព្រឹត្តល្មើសនឹងយើង ៗ ចាប់បានខ្លួនហើយលែង ៗ ហើយចាប់បានខ្លួនទៀត, តួជាទមុននេះ អៀវហងជាកៀនសំឡាញ់ខ្លួន ឃើញថាខ្លួនធ្វើខុស ក៏ចាប់ខ្លួនមកឲ្យយើង, យើងក៏បានទុកអាយុជីវិត បើកលែងទៅវិញមិនសម្លាប់, ឥឡូវនេះ តូឡៃជាប្អូនថ្លៃខ្លួនចាប់ខ្លួនមកឲ្យយើង ប្រាថ្នានឹងក្លងឧបាយធ្វើអន្ទាក់យើង ៗ ក៏អាចដឹងដល់, ហើយខុងបេង ក៏ឲ្យទាហានរើមើលក្នុងខ្លួនតូឡៃ នូវអស់ទាហាន ក៏បានឃើញអាវុធដែលសៀតបង្កប់នៅក្នុងអាវ ១ ម្នាក់ គ្រប់ៗគ្នា ។

ខុងបេង ក៏ចំអកបញ្ឈឺចិត្តឲ្យបេងហោកថា ឯកលឧបាយដែលខ្លួនគិតធ្វើនេះ សូម្បីគ្រាន់តែយើងគិតលេង ហើយបំភ្លេចទៅវិញ ក៏ល្អជាជាង, គ្រានេះ យើងមើលទៅឃើញថា ខ្លួនទាល់ផុតអស់គំនិតគិតហើយ តើខ្លួននឹងជាដូចម្ដេចទៅទៀត ។

បេងហោកឆ្លើយថា យើងមិនបានចាញ់ដោយកម្លាំងថ្វីដៃលោកសោះ, ចាញ់នេះ ព្រោះគំនិតគិតខុសចូលមកកេទស្លាប់ឯង ៗ បានជា

លោកចាប់យើងបាន, បើលោកនឹងសម្លាប់យើងមិនបន្ទន់ខាន, យើងក៏មិនត្រូវការទឹងអង្វរករទេ តាមចិត្តចុះ ។

ខុនបេងថា យើងចាប់អ្នកឯងបានដល់ ៦ គ្រាហើយ អ្នកឯងនៅតែនិយាយកោងព្រហើនដដែល តើគំនិតអ្នកឯងនឹងចង់ឲ្យយើងទៅតាមចាប់ប៉ុន្មានដងទៀត ទើបអ្នកឯងទទួលខ្លាចយើងជាប្រាកដ ? ។

បេងហោកឆ្លើយថា បើលោកបើកលែងយើងទៅម្តងទៀតឲ្យយើងបានធ្វើការគ្រាតែអស់គំនិតគិតទងអស់ថ្វីដៃហើយ ទើបបានយើងព្រមចំ-ណុះចុះចាញ់លោក, បើលោកមិនជឿ យើងនឹងធ្វើសត្យសញ្ញាទុកជូនលោក, ហើយបេងហោកក៏ធ្វើសញ្ញា នៅចំពោះមុខខុនបេង ។ បានស្តាប់ទើបគិតថា បេងហោកនេះ វាចាញ់ប្រៀបយើងណាស់ទៅហើយ, ពលទាហាន ក៏កាន់តែនៅស្តើងស្តួច មុខជានឹងធ្វើការធំតទៅទៀតពុំបាន, យើងនឹងលែងវាទៅទៀតចុះ, តែម្តងនេះ វាក៏អស់តម្រិះប្រាជ្ញាហើយ, ខុនបេងឲ្យទាហានស្រាយចំណងបេងហោក-បេងហាវ គួឡៃ និងនាងចុក-យ៉ុងនូវអស់ពលទាំង ១០០ នាក់ ចេញទៅ, ហើយថា យើងឲ្យអាយុជីវិតអ្នកឯងម្តងនេះទៀត បើគ្រាក្រោយយើងចាប់បានហើយ អ្នកឯង នៅតែនិយាយកោងដូចមុនៗទៀត, យើងនឹងសម្លាប់ឲ្យអស់មួយជួរគោត្រ ។

បេងហោកទទួលពាក្យខុនបេងហើយ, ក៏ឱនថ្ពាក់មុខដើរទាំងទុក្ខចេញទៅពីទីនោះ លុះទៅដល់ទឹកន្លែង ក៏ចាត់ចែងបញ្ចុះបញ្ចូលទាហាន

បានប្រមាណ ៨០០ នាក់, ចេងហោកក៏និយាយនឹងតួឡៃថា វេលានេះ ខុងចេងក៏ចូលទៅតាំងនៅក្នុងស្រុកយើងហើយ, យើងក៏គ្មានទីអាស្រ័យសោះ, បើដូច្នោះយើងនឹងគិតប្រការម្ដេចទើបនឹងបានតាំងខ្លួនធ្វើការតទៅ? តួឡៃថា លុតត័តកុត ដែលជាចៅហ្វាយស្រុក អក្ខុកុក ខាងទិសឯកើត ចម្ងាយពីនេះទៅ ៧.០០០ សិន (២៨០ គីឡូម៉ែត្រ) មានទាហានច្រើនណាស់, បើប្រសិនយើងរិះគិតនឹងទៅពឹងប្រាស្រ័យ ឲ្យលុតត័តកុតលើកទ័ពមកជួយ មុខជាយើងនឹងធ្វើការបានជ័យជម្នះជាប្រាកដ ព្រោះលុត-ត័តកុតនោះមានកម្លាំងពលច្រើនណាស់ ខ្ពស់១ព្យាម ៣ ហត្ថ ស៊ីតែសាច់សត្វរស់ និងផ្លែឈើជាងអាហារ ហើយក៏មានវិជ្ជាគង់អាវុធកាប់មិនមុត, ពលដែលចូលតយុទ្ធក្នុងវេលាណាដ៏សង្គ្រាម ក៏ស្លៀកក្រាខ្លាំងពូកែ យកផ្ដៅត្រាំប្រេង ៦ ខែ យកមកចាក់ធ្វើជាក្រោះ ទោះទៅដល់ផ្លូវជាចស្រយាលនឹងឆ្លងទឹក ក៏អាណែកខ្លួនស្រាលឡើងហែលឆ្លងទៅត្រើយម្ខាងបាន, បើត្រូវអាវុធព្រួញធ្នូ ក៏មិនបានមុតចូលទៅក្នុងសាច់, ទើបហៅពលទាំងអស់នោះឈ្មោះថា ទីនកៈបេង, សូមឲ្យលោកទៅអង្វរលន់តួលុតត័តកុតឲ្យលើកទាហានមកជួយធ្វើការសង្គ្រោះនឹងខុងចេង ។ ចេងហោកបានស្ដាប់មានសេចក្ដីត្រេកអរណាស់, តួឡៃក៏នាំចេងហោកទៅរកលុតត័តកុត ឯស្រុកអក្ខុកុក គំនាប់គោរពទំនៀមហើយ ចេងហោក ក៏ពណ៌នាសេចក្ដីឲ្យស្ដាប់គ្រប់ប្រការ, លុតត័តកុតថា ដែលខុងចេងលើកពលទ័ពចូលកាន់

ទន្ទ្រានចូលមកញាំញីក្នុងដែនយើង ឲ្យអ្នកបានសេចក្ដីក្ដៅក្រហាយនោះ អ្នកកុំព្រួយចិត្តគិតពេកឡើយ, យើងនឹងទទួលរ៉ាប់រងជាធុរៈឯង ដើម្បីឲ្យខុងបេងដឹងសំណាក់ដៃឲ្យបាន, លុតត័តកុត ក៏បង្គាប់ទៅអ៊ុន និងគេហ្វ៊ី ឲ្យលើកទាហានទ័ពនគៈប៉េង ៣០.០០០ ជាកងមុខ ទៅតាំងចាំទទួលកងទ័ពខុងបេង នៅក្បែរស្ទឹងតោហ្វយស៊ុយ ក្រៅស្រុកអក្កូកុក ខាងទិសឯកើតជាមុន ហើយលុតត័តកុត ក៏នាំបេងហោកទិងស៊ុគ្រប៉ក្ខពួកទាំងពួង ចេញទៅប្រចាំជូនជាក្រោយ ។

(នៅមានត)

# រឿង
# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២៧

កាលនាងដឹងខ្លួនឡើង ហើយស្ទុះរកមើលជុំវិញខ្លួននាង ទើបនាងដឹងថា នាងគេងតែឯងទេនោះ រាត្រីកាលមិនទាន់ស៊ើយផុតនៅឡើយទេ នាងនឹកមួយសន្ទុះ ទើបនាងដឹងថានាងគេងនៅទីណា , នាងចុះពីលើគ្រែ ហើយស្ទុះទៅបើកទ្វារ នៅលើផ្ទៃទឹកនឹងថ្កល់នោះ មានអ័កពណ៌សប្រផេះអណ្តែតខ្ទាប់ នៅលើមាត់ច្រាំង ឯទាយដើមឈើដុះច្រង់ច្រាងដូចវាំងសំពត់, រស្មីព្រះអាទិត្យពេលព្រហាម មានពណ៌ក្រហមព្រឿងបញ្ចេញរះអាទិតែធំបន្តិចម្តង ៗ នៅលើផ្ទៃទឹកទន្លេ, ក្តោងទូកអ្នកនេសាទចេញបន្ត ៗ គ្នា បីដូចគេបន្តក់ផ្កាសលើផ្ទៃសំពត់ពណ៌ស្រគាំ ៗ

ទេសភាពវេលាព្រឹកនោះ មិនដឹងដូចម្តេចទេ ក៏ទៅជាគួរអាប់ បណ្តាលឲ្យនាងកាមលាតប់ប្រមល់ក្នុងចិត្ត នឹកអាណិតខ្លួនតាំងពីធំដឹងក្តីមក ស្គាល់តែវេទនា នឹកដល់រឿងនេះ នាងស្អួលដើមក ៗ ទើបតែពីល្ងាចមិញនេះសោះ នាងគិតខ្លួនថានាងជាកូនកំព្រា ហើយមានតែប្តី

មួយជាបង្គោលប៉ុណ្ណោះ ចុះហេតុម្តេចបានជានាងត្រឡប់ជាទឹកឃើញថានាងកំព្រាទៀតហើយ ។ ការមេស្រុកគ្រប់គ្រងនាងមិនបានគ្រប់គ្រាន់ទេឬ ? អ្វីអេះដែលបណ្តាលឲ្យនាងទឹកឃើញតាំងក្រៀមក្រំអំពីអមិត្តភាពរវាងរូបនាងនិងទីកន្លែងដែលនាងរស់នៅ ។

ពេលដែលនាងកំពុងតែបណ្តែតអារម្មណ៍នោះ រស្មីព្រះអាទិត្យចាំងទៅលើផ្ទៃទឹក ភ្លឺប្រាលបីដូចទឹកមាសលាយកំពុងហូរក្រាលពាសលើផ្ទៃទន្លេ ។ ពួកកម្មករ នាំគ្នាចាប់ការងាររៀង ៗ ខ្លួន ម៉ាស៊ីនកប៉ាល់ចាប់ធ្វើចលនាគគ្រឹក សូរគ្រឿងចក្រឮសូរបេសធ្ងន់ ផ្សែងប្រពក់ ធ្វើឲ្យក្មេងតូច ៗ កន្ទ្រូមភ្ញាក់មុនពេលធម្មតា ហើយនាំគ្នាមកលោតលេងពេញលើមាត់ច្រាំង ។

ពេលនោះ, ការមេស្រុកក៏ភ្ញាក់ ក្រោកដើរចេញមកមាត់ទ្វារសំលឹកមើលនាងកាមាលា ឃើញហើយនិយាយថា ៗ

- នាងលុបមុខលុបមាត់ហើយឬនៅ ? គេក្រោកគ្រប់គ្នាហើយណា៎

ពាក្យនិយាយជាសំនៀងប៉ុណ្ណេះមិនសមនឹងទីនោះ តែនាងកាមាលាទោជាអន់ចិត្ត ព្រោះនាងទឹកឃើញថា ការមេស្រុកដែលក្រោកពីព្រលឹមហើយគៀននាងឲ្យលុបមុខមាត់មិនមែនគ្រាន់តែជាការគ្មានអត្ថប្រយោជន៍ប៉ុណ្ណោះទេ ថែមទាំងមិនសមរម្យទៀតផង ។ នាងយល់ទៀតថា ព្រោះបានដាក់សម្រេះជាប្រពន្ធជាស្រេច កន្លែងការពារនាងទៅនិងខ្លួននាងមិនគេ

ហើយគេនឹងមិនទន្ទ្រានមកកាន់គេកាពប្អូនស្វាលវិញទេ ៗ ចុះបើឃើញគេប្រកាន់ឥរិយាបថបែបនោះហើយ ហេតុម្តេចបានជានារីនៅតែមានការទើយទាម កាលណានាងនៅចំពោះមុខគេ ?

កាលបើឮយុវជនប្រើនាងឲ្យទៅលុបលាងកាយ នារីមិនឆ្លើយតបទេ នាងក៏ក្រោកយកសំពត់អាវ ប្ដូរដើរតម្រង់ទៅបន្ទប់ទឹក ។ ចេញពីងូតទឹកមកវិញ នាងដើរចូលទៅក្នុងបន្ទប់ ហើយទាញសោពីចង្កេះដាក់បើកហិបសំពត់អាវ, បើកភ្លាមក៏ឃើញប្រអប់ក្រោក ដែលកមេស្រ្តប្រគល់ឲ្យនាងពីថ្ងៃមុន ៗ កាលដែលនារីយកប្រអប់នេះមកទុកក្នុងហិប នាងមានសេចក្ដីតក់យេកអ្នកផ្ដឹមគ្មាន តែឥឡូវនេះ សេចក្ដីបង្សៀម ការសប្បាយទាំងប៉ុន្មាន រលាយអស់ហើយ . . . . ព្រោះរបស់នេះ មិនមែនជារបស់នាងទេ គឺជាសម្បត្តិកមេស្រ្ត, នាងមិនអាចយកប្រើការបានដោយមិនបាច់សួរម្ចាស់គេទេ, នាងគ្រាន់តែជាអ្នករក្សាទ្រព្យឲ្យគេប៉ុណ្ណោះ

— នាងនៅទ្រឹងអស់ប្រមេះ ឃើញអ្វីនៅក្នុងហិបនោះ ឡោចលងឬ ? (កមេស្រ្តដើរចូលមកបណ្ដើរនិយាយបណ្ដើរ )

— ចាះ! បង ខ្ញុំឃើញប្រអប់នេះដែលជារបស់បង (នាងហុចប្រអប់ឲ្យទៅកមេស្រ្ត )

— ឲ្យបងយកទៅធ្វើអី ?

— អ៊ីចឹង បើកាលណាបងត្រូវការ, គួរបងប្រាប់ខ្ញុំមក សុំ

ខ្ញុំប្រើក្មេងទៅទិញជូន ។

– ចុះកាមាលាឯង មិនត្រូវការជួបបងដែរទេឬ ?

– ខ្ញុំឥតត្រូវការប្រាក់ទេ (នាងឆ្លើយយ៉ាងខ្លី )

ភមេស្ហឬហើយញញឹម ។

– គិតមានមនុស្សណានិយាយដូចកាមាលាឯងណាស់ ។

នារីមិនឆ្លើយតបថែមទៀតទេ តែនាងដាក់ប្រអប់ប្រាក់នោះទៅលើក្តារ ។

– អាងខឹងនឹងបង ព្រោះបងមិនបញ្ចប់រឿងឲ្យ ឬ អី ?

– ខ្ញុំគ្មានខឹងអ្វីនឹងបងទេ (អាងប្រកែក) តែនាងមិនលើកភ្នែកពីក្តារក្រាលសោះ ។

– ខ្ញុំមិនជឿទេ ដកបណា នាងមិនព្រមទទួលយកប្រអប់នេះ ។

– ខ្ញុំមិនយល់សោះ ប្រអប់នេះជារបស់បង បងត្រូវតែរក្សា ។

– វាមានជារបស់បងឯណា គូនដឹងទេលោកថា តែអ្នកណាឲ្យអ្វីគេហើយយកមកវិញ ស្លាប់ទៅជាខ្មោចហើយ ក៏នៅតែវិលមករក្សារបស់នោះដែរណា៎ ហើយនាងស្មានថា ខ្ញុំចង់ដូចអីចឹងឬ ? ។

– ឬកមេស្ហ និយាយលេងបែបនេះ នាងទ្រាំសើចមិនបាន ផ្ទុះសំណើចហើយឆ្លើយតប ៖

– មែនហើយ ប៉ុន្តែពាក្យដែលបងនិយាយអម្បាញមិញនេះ ជាការ

ពិតឬកុហក ? ខ្ញុំមិនដែលឮអ្នកណានិយាយដូច្នេះសោះ . . .

បន្ទាប់ពីនោះមក ភាពតានតឹងរវាងនារី និងបុរសក៏ធូរស្រាលទៅវិញ ។

—មានផ្លូវតែម្យ៉ាងទេ បើអូនចង់ដឹងថាពាក្យនោះ ពិតឬមិនពិត គឺថា បើកាលណាអូនឃើញខ្មោចកលង អូនសួរវាទៅ ។

នាងកាមាលា មានវ័យក្មេង តែឮគេនិយាយអ៊ីចឹង ចូលចិត្តជឿណាស់ នារីខំសួរបុរសថា :

—បងនិយាយឲ្យត្រឹមត្រូវទៅមើល បងដែលឃើញខ្មោចលងឬទេ ?

—ខ្មោចមែនទែន បងមិនដែលឃើញទេ ឃើញតែគេធ្វើ ។

—ចុះ អុយមេស្ហាថា . . .

នៅពេលនោះ ពួកនាវិកបានដោះរលៀកកប៉ាល់រួចពីជាប់គៀង ក៏បើកចេញទៅ ចេញទើបនឹងផុតពីច្រាំង ស្រាប់តែគេក្រឡេកឃើញក្មេងម្នាក់ចូលអ៊ីវ៉ាន់ពេញកញ្ច្រែង រត់បណ្តើរស្រែកបណ្តើរ ឲ្យកប៉ាល់ឈប់, លុះវាមើលឃើញកមេស្ហាឈរនៅក្នាក់ដៃ វាស្រែកថា :

— ប៉ាប៉ូ ! ប៉ាប៉ូ !

នាយកប៉ាល់ គ្មានរវល់យកចិត្តទុកដាក់នឹងសម្រែកក្មេងបន្តិចសោះ :

— យី ! អាក្មេងនេះ វាធ្វើមើលតែខ្ញុំជាអ្នកឆែកសំបុត្រកប៉ាល់

( ភមេស្ហៃវៃតបទៅវិញ ) តែនាងគាមាឈាមិនព្រម

— អ៊ុយមេស្ហទេតើ បង, ហៅលគ្នាម្ដេចកើត ?

– ឲ្យបងធ្វើម្ដេច គេមិនមែនឈប់ឲ្យយើងទេណា

– ទេបង ! . . . បងត្រូវតែធ្វើម្ដេចឲ្យគេឈប់ទៅយើងនៅជិតប្រាំងទៅទៀយទេតើ . . . .

នាងលំអុកខ្លាំងពេក ភមេស្ហក៏ទៅនិយាយនឹងនាយកប៉ាល់ ៗ មុនដំបូងគេមិនព្រមទេ ទាល់តែឲ្យប្រាក់ខ្លះទៅ ទើបគេព្រមឈប់ឲ្យ ៗ កប៉ាល់ឈប់ហើយ នាវិកជួយអូសកូមារឲ្យឡើងដុតមក ៗ ឡើងរួចមកកាលណា កុមារដាក់ទំនូលនៅក្បែរជើងម្ចាស់ស្រីក ហើយស៊ើចកាច់កដូចជាគ្មានភ័យនឹងកប៉ាល់ចេញហោលសោះ . . . .

— ឪ ! ប៉ុណ្ណឹងហើយ នៅសើចទៀត ? (នាងនិយាយដោយធ្វើមុខស៊ើ ) កុះបើកប៉ាល់ចេញហោល ឯងធ្វើម្ដេចទៅ ?

កុមារមិនឆ្លើយតបទេ រហោលក្អែក ទៅលើកព្រែង បន្ទនាងដាក់ក្អែកតាមឃើញ មានពេក ផ្ទៃ រនោង ៗ ល ៗ

— ឯងបានរបស់ទាំងនេះមកពីណា ?

— មែ៉ ពីថ្ងៃមុន ពេលដែលកប៉ាល់ចៀង ខ្ញុំដើរទៅក្បែរមាត់ប្រាំង ឃើញបន្ទទាំងនេះ របស់អ្នកស្រុក តែខ្ញុំមានលួចគេឯណា

ខ្ញុំគ្រាន់តែបេះនេះបន្តិចនោះបន្តិច មិនបានសុំម្ចាស់គេទេតើ . . .

– ឯងគិតយ៉ាងម៉េចហ្នឹង ! បន្តិច ៗ ហ្នឹង មិនហៅថាលួចទេឬ? (កាមេស្ហនិយាយបែបខឹង) ទៅ ! យកចេញពីមុខអញឲ្យឆាប់ ឯងយកទៅណាទៅ ៗ ។

អ៊ុយមេស្ហ ខំសំឡឹងមុខនាងកាមាលា ហាក់ដូចជាខំអង្វរឲ្យនាងជួយទាំងកំហឹងកាមេស្ហ ក៏ខំនិយាយបន្ទន់ឲ្យនាងបាត់ខឹង

– នែម៉ែ ! អាផ្លែនេះ ស្រុកខ្ញុំគេយកទៅធ្វើម្ហូបឆ្ងាញ់ណាស់ឯះនោងនោះ . . . .

– យកចេញឲ្យឆាប់ (កាមេស្ហស្រែក បែបខឹងសម្បើម )គេមិនចេញអញគ្រាន់តែក្លិនទឹកទាំងរស់ ទាំងអាឯងផងឥឡូវ . . . .

អ៊ុយមេស្ហ ខំងើបមើលមុខនាងកាមាលាម្ដងទៀតដូចជាចង់ឲ្យនាងជួយ តែនាងធ្វើកាយវិការ បញ្ជាឲ្យចេញឆាប់ទៅ កុំចាំ ៗ កុមារប្រមូលអីវ៉ាន់ដាក់កញ្ច្រែងហើយ រត់ចុះទៅក្រោម តែរាយល់ទឹកមុខនាងថា នាងនៅតែការណីតក់ដែរ ។

កាមេស្ហដើរចូលបន្ទប់ទាំងមុខក្រញូវ ទៅសម្ងំសរសេរសំបុត្រមួយបន្ទើយ . . . នាងកាមាលា [illegible] មើលមុខតាកំព្រា ឃើញក៏ទៅអង្គុយលើគែមកប៉ាល់ ក្បែរបន្ទប់ធ្វើការ ។ នាងយកក្រមាខ្ទប់ក្បាល រួចដើរចូលទៅជិតក្មេង . . . ។

– ឯងគ្រវាត់ចោលអស់ទៅហើយឬ ?

– ទេម៉ែ ? ខ្ញុំលាក់នៅក្រោមនោះទ៍ ?

– អំពើដែលឯងបានធ្វើហ្នឹង មិនល្អទេណា៎ ?

– (នាងធ្វើជាបន្ទោស) កុំធ្វើដូច្នេះទៀតឮទេ ? ចុះបើលោកប្រុសឯង ចោលឯងនៅទីនោះ គេយ៉ាន់ម៉េចទៅ តឲ្យឯងត្រូវទៅរកកាំបិតឲ្យម៉ែមួយមក ៗ

កុមារកំព្រាតែបញ្ញោត នារីរើសយកបន្ទុះប៉ះមុខ ដើម្បីធ្វើអាហារ ៗ ឱ ! ពុទ្ធោអើយ ទោះជាកូនកំព្រាបានធ្វើកំហុសប៉ុណ្ណោះក៏ដោយ នាងក៏នៅតែខំគ្រប់ដណ្ដប់ដែរ ព្រោះគ្នាគ្មានទីពឹង ហើយបើធៀបរឿងលួចទិងរឿងដែលគ្នាកំព្រាគ្មានទីពឹងវិញនោះ ឃើញថារឿងកំព្រាឯការនេះរាជធ្ងន់ជាង ៗ ម្យ៉ាងទៀត កុមារដែលបានទៅលួចបន្ទប់ទុកគេនោះ ក៏ពីព្រោះតែគ្មានគេយកផ្គាប់ចិត្តនឹងគេ ក៏ទៅជាយល់ខុស ៗ

– ទ៍! នៅសល់ទឹកដោះគោខ្លះដែរ ឯងយកទៅផឹកទៅ ហើយកុំទៅដើរប្រាប់អាប៉ែដណាអ្នកស្រុកដូចមុនទៀត ៗ

– ម៉ែ ពីសាទេ ? (កុមារមហ្សូវសួរយកចិត្តនាង) ៗ

– គិតតែមាត់ឯងឲ្យផ្អែមទៅ ម៉ែមិនលោភដូចឯងទេ ៗ ឯងគិតធ្វើម្ដេចបានត្រី ដើម្បីធ្វើម្ហូបឲ្យលោកប្រុសឯង ?

– ខ្ញុំរកបាននម៉ែ ! តែចេះតែទិញគេ ៗ

— មិនដែលឃើញក្មេងណាឆ្កួតដូចឯងសោះ, អ្នកណាគេឲ្យឯងទៅយកអីវ៉ាន់គេហើយ មិនឲ្យលុយ ។

តែនឹកដល់រឿងលុយ កុមារក៏ព្រានឹកឃើញដល់កមេស្វាម ពីព្រោះនាងកាមាលាមិនមែនយកលុយពីកមេស្វាបានងាយទេ ហេតុនេះទើបគុំយមេស្ហទឹកស្អប់ទៅហ្វាយប្រុសក់ ដែលចេះតែត្រូវការឃ្លានហើយទុកម្ចាស់ស្រីទិញខ្លួន ឲ្យរកមធ្យោបាយតែពីរនាក់ ឯគាត់នៅព្រងើយ គ្មានខ្វល់គិតគូរអ្វីទាំងអស់ ។ បើបន្តិចបន្តួចមិនថ្វីទេ សុំគេបានចុះបើត្រីសាច់តើសុំអ្នកណាបាន ដើម្បីនឹងយកមកធ្វើអាហារផ្គាប់ចិត្តគេ?

– ម៉ែ! បើបានលុយតែ ៤ អាណា[១]មក ខ្ញុំនឹងទៅរកទិញឲ្យបានត្រីមួយយ៉ាងគួរសម ។

— ទេ ម៉ែ! មិនឲ្យឯងចុះពីកប៉ាល់នេះជាដាច់ខាត តែឯងចុះហើយមកមិនទាន់ កប៉ាល់ចេញចោលដូចមុន មុខជាគេទៅចោលឯងហើយ !

— ទេ, ម៉ែ! ខ្ញុំទិញនៅខាងក្រោមទេតើ ខ្ញុំមិនចុះពីកប៉ាល់ទេ ។ ពីព្រឹកមិញខ្ញុំឃើញពួកកម្មករបង់បានត្រីធំ ៗ បើខ្ញុំសុំបែក ច្បាស់ជាគេលក់មិនខាន ។

នាងកាមាលា ចូលទៅយកលុយមកហុចឲ្យកុមារ : ។

-- នែ! យកទៅទិញទៅ សល់លុយយកមកវិញ ។

---

១- ប្រាក់នៅប្រទេសឥណ្ឌា ។

បន្តិចក្រោយមក កុយមេស្ហត្រឡប់មកវិញ កាន់ត្រីមួយយ៉ាងធាត់ល្អមកផង ។

— ម៉ែអើយ ? គេឥតថែមលុយឲ្យទេ, គេបកទាំងអស់ទៅហើយ !

(នាងកាមាលាញញឹម នាងដឹងថាពកឹបហើយ ។ )

— បើមិនសល់លុយក៏បាន ផល់តំណាក្រៅតែគេលុយទៀត .

— បាទ ! មែនហើយម៉ែ ! បើមិនគេបានទិញពីរ៉ានពិសារ .

យូរក្រោយមកទៀតដល់ពេលបរិភោគអាហារ :

— អីយ៉ា ! ឆ្ងាញ់ណាស់ទេតើ ( ភមេស្ហលាន់មាត់សរសើរ ទាំងចាប់លើកក្បាលត្រីនោះផង ) នាងបានត្រីនេះពីណាមក ?

លុះភមេស្ហបរិភោគរួច ដើរចេញទៅ ត្រូវផល់ទៅអ៊ុយមេស្ហ, កុមារសប្បាយចិត្តនឹងបានអាហារឆ្ងាញ់ បរិភោគពាល់តែនាងកាមាលាឃាត់.

— ប៉ុណ្ណឹងបានហើយ ចាំល្ងាចសុំមស៊ីទៀត ម៉ែទុកឲ្យ .

ពត្រីកាលសន្សំមចុះមក នាក់ក៏ចូលផែឈប់សម្រាកដូចកាលសព្វដងវៀងមក ។ នាងកាមាលារៀបចំទីងចំអិនម្ហូបទៀតហើយស្រាប់តែភមេស្ហដើរចូលមក .

— កាមាលាអូន ! កុំធ្វើអ្វីទៀត បងខ្ជិតហ្វាយពីព្រឹកមិញពេក ឥឡូវនេះគ្មានឃ្លានសោះ .

នាងកាមាលា ក៏រៀបបំរុងតែអ៊ុយមេស្ហទៅ ។ ពត្រីនោះព្រះចន្ទ

រះឡើងភ្លឺត្រចះ ចោលរស្មីទៅលើផ្ទៃស្រែធំធេងស្ងាត់ ៗ នាងកាមាលា ចេញមកឈរនៅភ្នាក់ដៃកប៉ាល់ ក្បែរកៅអីកាមេស្ហ នាងលបគន់មើលទឹកមុខបុរស ក្រោមរស្មីព្រះចន្ទ, បុរសគ្មានចាប់អារម្មណ៍ដល់នាងបន្តិចសោះ គ្រាន់តែឃើញទឹកមុខបុរស នាងយល់ភ្លាមថា បុរសពុំមានជំពាក់អារម្មណ៍លើរូបនាងបន្តិចសោះទេ, នាងនឹកអាណិតខ្លួនកំព្រាស្រងូតចិត្ត ហើយចំថយលបៗ ចូលទៅក្នុងបន្ទប់ងងឹត ដែលនាងមើលទៅហាក់ដូចជាមាត់សត្វស័យមួយគួរខ្លាច នាងព្រឺក្បាលខ្លាក ប៉ុន្តែបើមិននៅទីនេះទេ តើមានកន្លែងដទៃឯណាទៀត ដែលគួរឱ្យនាងជ្រកបានដោយសុខុម .

នាងដើរចូលទៅ ប៉ះនឹងត្រកមេស្ហដែលព្យួរនៅក្បែរមាត់ទ្វារ ធ្លាក់ទៅលើហិបដែកតុកក៏ ធ្វើឱ្យភ្ញាក់កាមេស្ហដែលកំពុងតែស្លុងគំនិត អ្នកស្ទុះដើរមករកនាង :

— កាមាលាកឬ ? បងស្មានថាអូនគេងទៅហើយតើ អូនខ្លាចឬ ? បងមិននៅខាងក្រៅយូរទេ ហើយដល់បងចូលចាំបងទុកទ្វារចូលទៅបន្ទប់ចំហ កុំឱ្យអូនខ្លាច .

— ខ្ញុំគ្មានខ្លាចអ្វីទេ

ថាតែប៉ុណ្ណោះ នាងទាញទ្វារបន្ទប់បិទជ្រឹប ហើយផ្តួលខ្លួនទៅលើគ្រែយកក្រមាខ្ទប់មុខយំ ព្រោះនាងនឹកឃើញកំព្រាពេក , គ្មានបុរសជាទីសង្ឃឹម . . . គ្មានគ្រួសារ គ្មានផ្ទះសំបែង រស់នៅតែឯងបែបនេះ តើ

នាងនឹងអាចតស៊ូម្ដេចបាន . . . .

មនុស្សម្នាក់ក្នុងកប៉ាល់ចូលនិទ្រាស្ងាត់ឈឹងនាងគេងមិនលក់ ដោយវិតក្កកពេក ក៏ដើរចេញពីបន្ទប់ទៅអង្គុយខាងក្រៅ សំឡឹងមើលទៅលើច្រាំងឆ្ងាយ, យប់ជ្រៅណាស់ហើយ គ្មានមនុស្សម្នាណាដើរម្នាក់សោះ ព្រះចន្ទក៏សន្សឹមចុះបំបាំងខ្លួននឹងរនាំងព្រៃ ផ្លូវដើរដែលញែកតាមគុម្ពស្រូវក៏មើលមិនឃើញដោយអន្ធការ នាងនឹកសម័យឃើញស្រី ៗ ទូលក្អមទឹកដើរដង្ហែគ្នាទៅកាន់ផ្ទះសម្បែងគេរៀង ៗ ខ្លួន ទឹកដល់ត្រង់នេះនាងអួលដើមកចង់ស្រក់ទឹកភ្នែក " ចុះកំព្រាអ្វីតែរូបខ្ញុំ រកគ្រួសារគេផ្ទះសម្បែងនឹងគេគ្មាន ! "

នាងឮស្នូរជើងមនុស្សដើរស្រិប ៗ នាងភ្ញាក់ព្រើត " យី នាងមិនមែននៅតែឯងទេ " នាងងាកមើលក្រោយ

— ខ្ញុំតើម៉ែ, ( អ៊ុយមេស្ហនិយាយ )

— ម្ដេចក៏ឯងមិនដេក ( និយាយបានតែប៉ុណ្ណោះ ទឹកភ្នែកនាងហូរសស្រាក់ទប់ពុំបាន វិស័យដូចពពកទឹកដែលរសាត់តាមផ្ទៃអាកាសទៅប៉ះលើខ្យល់ត្រជាក់ ក៏ធ្លាក់ចុះជាភ្លៀងដោយទប់ទល់នឹងទម្ងន់អម្រែកខ្លួនពុំបាន យ៉ាងណាមិញ, ពាក្យអ៊ុយមេស្ហតែមួយម៉ាត់ក៏អាចធ្វើទឹកភ្នែកនាងកាមាលាឲ្យហូរបានដូច្នោះដែរ . . . .

កុមារកំព្រាឃើញម្ចាស់ស្រីវាយំ មិនដឹងរកពាក្យអ្វីនិយាយនឹង

នាង ចេះតែស្ងៀមមួយសន្ទុះ ទើបថា :

— ម៉ែ ! ប្រាក់ពីថ្ងៃមុននោះ នៅសល់ ៧ កាក់ទៀត ...

នាងបាត់យំទៅជាញញឹមទៅកាន់ក្មេង ..

— ទុកឲ្យស្រួលបួលទៅ រួចទៅដេកទៅ យប់ណាស់ហើយ ..

នារីក៏ដើរចូលបន្ទប់វិញដែរ ។

## វគ្គទី ២៨

ព្រលឹមឡើង នាងធ្វើការទាំងព្រាន់ក្នុងចិត្ត មើលទៅព្រះអាទិត្យ ក៏ដូចជាឥតរស្មី មើលទៅទឹកទន្លេហូរ ក៏ដូចជាខ្ជិលច្រអូស មើលទៅដើមឈើដែលទោរទន់មកលើទន្លេ ក៏ដូចជាអ្នកដំណើរនឿយណាយ រកកម្លាំងទឹងឈរឲ្យត្រង់ខ្លួនពុំបាន លុះនាងឃើញអ៊ុយមេស្ហដើរទៅជិត ប្រុងនឹងជួយធ្វើការនាង នាងទៅជាមួរម៉ៅស្រែកថា :

— ទៅឲ្យឆ្ងាយ ! កុំមករេងគាង ?

— ខ្ញុំមានធ្វើអីម៉ែ ខ្ញុំមកជួយកិនគ្រឿងទេតើ ?

មិនយូរប៉ុន្មាន ទឹកមុខស្លេកស្រពោនរបស់នាង ទាញសតិអារម្ភ ភមេស្ហកាម អ្នកទិស្សរយ៉ាងរួសរាន់ ក្រែងនាងឈឺ តែនាងគ្រវីក្បាលបដិសេធ ។

យុវជនយើងយល់ដល់ជម្រៅបញ្ហារវាងនារីនិងអ្នក ដែលកាន់តែ

តឹងឡើង ៗ រាល់តែថ្ងៃ ,អ្នកពិបាកចិត្តពេក ក៏នឹកថា "បើសិនជាខ្ញុំថ្លែងទុក្ខរបស់ខ្ញុំតាំងពីមុនទានប្រាប់នាងហិមណាលីនឹងឲ្យអស់សេចក្ដី ប្រហែលជានាងជួយដោះស្រាយរួច" គិតសព្វគ្រប់ហើយក៏ទាញក្រដាសមកសរសេរសំបុត្រ ៖ កំពុងតែសរសេរ អ្នកឮសំឡេងមនុស្សប្រុសនិយាយមកកាន់អ្នក អ្នកធាប់ហែកសំបុត្រចោលភ្លាម ងាករកមើលម្ចាស់សំឡេងតាំងឆ្ងល់ ៗ តាចាស់ម្នាក់ក្បាលឆក ពុកមាត់ស្កូវមួយៗ សួរអ្នកថា ៖

សុំទោសលោក ? លោកឈ្មោះអ្វី ? លោកជាពូជព្រាហ្មណ៍មែនឬទេ ហើយលោកនេះហើយឬ ដែលឈ្មោះកាមេស្ហហ៊ុប៊ូរ? ខ្ញុំសុំផ្ទាបសួរ សុំលោកកុំអន់ចិត្ត កុំលាក់ឈ្មោះលោកធ្វើអ្វី បើសិនជាលោកចង់ដឹងឈ្មោះខ្ញុំ , ឈ្មោះឪពុកម្ដាយ , ជីដូនជីតាខ្ញុំ ខ្ញុំអាចផ្ទាបលោកបានទាំងអស់ ៗ

កាមេស្ហសើច ហើយឆ្លើយទៅវិញ ៖

– ខ្ញុំគ្មានអន់ចិត្តអ្វី គ្រាន់តែរឿងប៉ុណ្ណឹងទេ លោកប្រាប់ឈ្មោះលោកឲ្យខ្ញុំស្គាល់ផងមើល លោកឈ្មោះអ្វី ?

– ត្រៃលក្ខ ចក្រពត្តិ តែអ្នកស្រុកនៅតាមដងទន្លេនេះ ហៅខ្ញុំតែ " លោកតា " ទេ , លោកគ្រូជាចាស់ , តាគេជាស្ដេចអធិកជនទៅឥណ្ឌូស្ថាននេះ ហើយខ្ញុំជាមារបស់ព្រះឥន្ទ្រ ៗ ខ្ញុំចង់សួរថា តើលោកអញ្ជើញទៅណាដែរហ្នឹង ?

— ខ្ញុំមិនទាន់សម្រេចថា ចុះនៅឯណា នៅឡើយទេ លោកមា ?

— រឿងចុះពីកប៉ាល់នោះ យើងមិនបាច់ប្រញាប់ក៏បានដែរ បើគេឡើង ទើបត្រូវតែឲ្យទាន់គេ ។

— បាទមែនហើយ , តែកាលដែលខ្ញុំចុះពីរថភ្លើង នៅគ្ហារលុនដូ ខ្ញុំឮស៊ីប្លេកប៉ាល់ បន្ទឺរន្ទើនៗ ខ្ញុំក៏រត់ឡើងភ្លាមមក រកគិតថាទៅណាមិនទាន់ ។

— ខ្ញុំកោតលោកដែរ ដែលធ្វើដូច្នេះកើត ព្រោះថាបើខ្ញុំវិញ ធ្វើដូច្នេះ មិនកើតទាល់តែសោះ ។ ព្រោះថាមុននឹងឡើងកប៉ាល់ ខ្ញុំត្រូវតែដឹងថា តើខ្ញុំទៅកន្លែងណាជាមុនសិន ទើបទៅកើត ។ ប្រពន្ធលោកមកតាមលោកដែរ ឬលោកអញ្ជើញមកតែឯងទេ ?

ប៉ុន្តែ លុះគាត់ឃើញការមេស្ហឹមអៀមបែបមិនចង់ឆ្លើយ គាត់ក៏និយាយបន្ថែម . . . .

— ខ្ញុំដឹងហើយ សុំទោស ខ្ញុំឃើញនាងរៀបចំបាយទឹកជូនលោក ខ្ញុំឃ្លានដែរ - ខ្ញុំបានតាំងប្រាប់នាងថា កុំឲ្យនាងញញើតខ្ញុំផង ។ យី ! នាងនេះ ចំជាស្រីមេផ្ទះចំណាប់ល្អណាស់លោក ម្យ៉ាងទៀត ដោយខ្ញុំគ្មានគ្នាមកជាមួយសោះ ខ្ញុំបាននិយាយលេងនឹងនាងថា : "ខ្ញុំចង់សំបរិភោគអាហារជាមួយនាងណាស់ មើលទៅម្ហូបនាងគួរឲ្យស្រក់ទឹកមាត់ នាងសើច , លោកអើយ តាំងពីកាលណាមក ខ្ញុំមិនដែលបានជួបជោគ

ភាសនាល្អ ដូចជនេះសោះ , ទេ ! លោកវល់ឬ ? ខ្ញុំមិនចង់ឲ្យខាន លោកទេ , ហើយបើលោកមិនយល់ទាស់ទេ ខ្ញុំសុំទៅជួយធ្វើការប្រពន្ធ លោកឯណោះ ដរាបណាខ្ញុំនៅទីនេះ ខ្ញុំមិនចង់ឲ្យប្រពន្ធលោកវិចដៃវិចជើងទេ, កុំអញ្ចើញក្រោកធ្វើអីលោក ខ្ញុំទៅខ្លួនខ្ញុំបានហើយ . . . ។

ថាហើយលោកមាក៏ដើរចូលទៅក្នុងនាងកាមាលាធ្មេញ . . . ។

— យីឈុយអីក៏ឈុយម្ល៉េះ! គ្រាន់តែជុំកុំនធ្លាញមុនទៅហើយ មិនបាច់ចាំក្នុងទេ ទៅលាងដៃទៅនាង ដល់ពេលបាយហើយ ចាំខ្ញុំបង្ហើយកិច្ចការឲ្យ កុំព្រួយអ្វីមួយ ខ្ញុំបេះ ព្រោះខ្ញុំធ្លាប់ធ្វើជាមួយប្រពន្ធខ្ញុំ. នាងសើច នាងមិនជឿខ្ញុំ ខ្ញុំមិនមែននិយាយលេងទេ ខ្ញុំបេះប្រាកដមែនណា ?

— បើពូបេះ បង្រៀនខ្ញុំផង ។

— បង្រៀនម្ដេចបាន បើខ្ញុំទើបនឹងស្គាល់នាងសោះ ពាល់តែនាងយកចិត្តខ្ញុំណាស់ ទើបខ្ញុំប្រាប់ , ប៉ុន្តែមិនអីទេ , ដូចនាងមិនចាំបាច់យកចិត្តខ្ញុំច្រើនទេ , ព្រោះខ្ញុំដូចជាចូលចិត្តនឹងនាងទៅហើយ អ្នកណាឈរនៅនោះនាង ? កេង្ហង មានទឹកមុខស្រស់ស្រាយគ្រាន់បើ ។

អ៊ុយមេស្ហុយរវៃខ្លួន ពិចមួយតែវាមិនសូវសប្បាយចិត្តនឹងអ្នកចំណូលថ្មីនេះប៉ុន្មានទេ, ព្រោះវាខ្លាចនាងកាមាលាស្រឡាញ់អ្នកថ្មីជាងវា ។

មាយើងចូលមកកាលណា ធ្វើឲ្យនាងកាមាលាមិនសូវហ៊ានហាង ការមេស្ហក៏កាន់ផ្លូវស្រាលខ្លួនបន្តិចដែរ ៗ ការមេស្ហដែលពីដំបូងឡើងធ្លាប់តែស្និទ្ធស្នាលនឹងនាង ហើយទៅជាប្រែចិត្តផ្ទុយអំពីមុនស្រឡះយ៉ាងនេះ ធ្វើឲ្យនាងកាមាលាពិបាកចិត្តក្រៃលែង ម្ល៉ោះហើយនាងខំរកមធ្យោបាយនឹងទាញអ្នកឲ្យត្រឡប់ដូចដើមវិញ ៗ

ថ្ងៃមួយ នៅពេលដែលការមេស្ហកំពុងតែគិតដោះស្រាយបញ្ហាបេះដូងរបស់គេ នាងកាមាលាទៅអើតនៅមាត់ទ្វារ ដើម្បីហៅលោកមាចក្របត្តិ ព្រោះវេលានោះនាងទំនេរ នាងរកគ្នានិយាយលេង ៗ គ្រាន់តែក្រឡេកឃើញនាងភ្លាម លោកមាលាន់មាត់ ៖

– យី ? មិនល្អទេណានាង !

នាងកាមាលាមិនយល់, លោកមានចង់ជាដូចម្តេច ក៏មើលមុខគាត់ ធ្វើភ្នែកឡឹងឡង់

– មាចង់និយាយពីស្បែកជើងនាងណ៎ា ? នៃការមេស្ហ ! ក្មួយឯងនេះហើយ ជាអ្នកដើមអាទ៍ ក្មួយដឹងជាផ្ទុយនឹងវិន័យសាសនារបស់យើងទេ ច្បាប់សាសនាបានចែងថា ជនណាដាក់ទ្រនាប់នៅបាតជើងខ្លួនដើម្បីដើរលើដីជននោះមើលងាយស្រុកទេសរបស់ខ្លួន ៗ ក្មួយជឿទេ គេថាប្រសិនជាកាលណោះ ព្រះរាមលោកមិនបង្ខំឲ្យព្រះនាងសីតាពាក់ស្បែកជើងទេ ប្រហែលជាព្រះលក្ខណ៍មិនព្រាត់ប្រាសអំពីព្រះអង្គទេ

ក្នុងរយៈពេល ១៤ ឆ្នាំ ដែលព្រះអង្គត្រេចរង្គត់ក្នុងព្រៃភ្នំក្រំថ្ម ៗ ! នាងសើច នាងមិនជឿក៏ហាទៅ, ខ្ញុំមិនឆ្ងល់ទេ ព្រោះថាចំពោះមនុស្សដែលរត់ទៀងកប៉ាល់ ហើយមិនដឹងថា : តើខ្ញុំត្រូវចុះទៅចំណតណានោះ យ៉ាងម្ដេចក៏បានដែរ -

— បើអ៊ីចឹងលោកមា ជួយសម្រេចតែម្ដងទៅ, តើយើងត្រូវចុះត្រង់ណា ( កាមេស្ហឆ្លើយ )

— ចុះនៅក្ហាស៊ីបូរីទៅ ឬ យ៉ាងម្ដេចនាង ស្រុកនេះជាស្រុករបស់ខ្ញុំ ស្រាបហើយសម្បូណ៌ផ្កាកូឡាបល្អៗណាស់ ។

កាមេស្ហងាកមើលមុខនាងកាមាលា នារីងក់ក្បាលស្របយោបល់..

លោកតូចក្របត្ដិនាំអ៊ុយមេស្ហទៅអង្គុយលេង ក្នុងបន្ទប់ជាមួយនឹងនាងកាមាលា ឯនាក់ក៏ចេះតែបន្ដដំណើរជាធម្មតាទៅ យូរៗ សំណើចស្រួយរបស់នាងកាមាលាហើរមកប៉ះត្រចៀកកាមេស្ហម្ដង ។

(នៅមានត)

# ប្រមូលចំនុកបុរាណខ្មែរ

យើងដឹងហើយថា ប្រជាជាតិខ្មែរ ធ្លាប់មានអារ្យធម៌ពីព្រេងនាយ ដែលឆ្ងាយណាស់មកហើយ គឺតាំងពីសតវត្សដំបូង នៃគ្រិស្តសករាជ ។ ក្នុងអារ្យធម៌នោះ សិល្បៈជាមែកធាងមួយធំណាស់ ហើយមានប្រសិទ្ធភាព ជាងគេក្នុងសន្តានចិត្តអ្នកស្រុក ។ ដូច្នេះ សិល្បៈ បានបែកចេញជាផ្នែក ច្រើនណាស់ទៅទៀត ដូចជាភ្លេង, បទចម្រៀង, ចំនុកច្រៀង, ក្បាច់រាំ, អលង្ការ ។ ល ។

វេលានេះ យើងសូមល្បងធ្វើការប្រមូលក្រង "ចំនុកបុរាណ" របស់ខ្មែរយើងយកមកផ្សាយជាទិដ្ឋានុគតិ សម្រាប់យុវជនកុលបុត្រខ្មែរទាំងអស់ បានឃើញជាក់ថា បំណេះវិជ្ជា សន្តានចិត្ត ការរស់នៅ សម្ពស្សវោហារ របស់បុព្វបុរសខ្មែរ មានដល់កម្រិតណា បើយើងពិនិត្យនៅក្នុងពាក្យកាព្យ ជាចំនុកច្រៀងទាំងនេះ ។ ចំនុកដែលចុះផ្សាយតទៅនេះ យើងប្រមូល បានមកពីទិសជនបទនានាក្នុងព្រះរាជាណាចក្រ ។

ហេតុនេះ យើងសូមអំពាវនាវចំពោះអ្នកអានទូទៅ សូមមេត្តាជួយ ផ្ញើចំនុកច្រៀងបុរាណខ្មែរយើង ដែលអស់លោក-អ្នកបានចេះចាំ ទោះច្រើនក្តី តិចក្តី សូម្បីតែ ២-៣ បន្ទាត់ក៏ដោយ ឲ្យតែផ្ញើមកយើងនឹងចុះផ្សាយបន្តទៅ ដោយចុះនាមអ្នកផ្តល់ឯកសារនេះទុកជាតាងផង ។

មិនតែប៉ុណ្ណោះ យើងនឹងយកឯកសារនេះតម្កល់ទុកក្នុងការិយាល័យទំនៀមទម្លាប់សម្រាប់ជាឯកសាររបស់ជាតិ ទុកជាកេរ្តិ៍វែងឆ្ងាយ ៗ

ជាបឋមនេះ យើងចុះផ្សាយទំនុកខ្លះ ដែលប្រមូលបានពីអ្នកដែលធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ និងស្រង់ចេញពីសៀវភៅចាស់ ៗ ដែលមានតម្កល់នៅពុទ្ធសាសនបណ្ឌិត្យ ដែលបោះពុម្ពតាំងពី គ.ស. ១៩២៩ មកដល់ ១៩៤៩ ។ នៅលេខក្រោយ ១ ទៀត យើងនឹងចុះផ្សាយត ៗ គ្នា នូវទំនុកដែលយើងបានទទួលពីអ្នកអានខ្លះ ពីឯកសារទំនៀមទម្លាប់ខ្លះ ត ៗ ទៅ ៖

## ទំនុកផ្ដោះផ្គងស្រី - ប្រុស

ប. ឱម្ចប់ដួងអើយ ដែលបងអង្គុយ
បងអត់ងងុយ ចាំស្រីរៃ ៗ
ចិត្តបងតែងចាំ ភ្នែកបងរំពៃ
ចាំស្រីរៃ ចុះមកជួបបង ៗ
ស. មួយយប់មួយថ្ងៃ បានបីកម្រង
រៃចាំបង ទម្រាំខែលិច ៗ
ស្រះមាចរាខាំ សង្ហាររាទិច

| | | |
|---|---|---|
| ទម្រាំខែលិច | ដាច់ខ្យល់បងហើយ | ។ |
| ប. ថ្ងៃអើយអ្នកថ្ងៃ | ថ្ងៃអើយអ្នកថ្ងៃ | |
| ខែក្តីដូចថ្ងៃ | នរណាឲ្យថ្ងៃមក | ។ |
| ស. កាំភ្លើងតាំងថែង | ដាវវែងតាំងប្រេក | |
| នរណាឲ្យថ្ងៃមក | មិនដឹងខ្លួនស្លាប់ | ។ |

នេះសម្រាប់ប្រុសច្រៀងផ្តើម បើស្រីផ្តើមវិញ ជាដូច្នេះ៖

| | | |
|---|---|---|
| ស. ឱម្ចប់ដួងអើយ | ដែលប្អូនធ្លាប់ជ្រក | |
| តាំប្រុសពន្លក | ព្រលឹងដើមថ្ងៃ | ។ |
| ចិត្តប្អូនតែងចាំ | ភ្នែកប្អូនរំពៃ | |
| ចាំអ្នកប្រុសថ្ងៃ | ថាមកជួបប្អូន | ។ |
| ប. បងចិតបងខ្ទោះ | មិនទាន់គ្រប់ខ្លួន | |
| បងចិត្តចាំប្អូន | ទម្រាំខែលិច | ។ |
| ស. ស្រមោចកខាំ | សង្ឃារក់ទិច | |
| ទម្រាំខែលិច | ដាច់ខ្យល់ប្អូនហើយ | ។ |
| ប. ថ្ងៃអើយស្រីថ្ងៃ | ថ្ងៃអើយស្រីថ្ងៃ | |
| ខែក្តីដូចថ្ងៃ | នរណាឲ្យថ្ងៃមក | ។ |
| ផ្កាចាំផ្លូវកែង | ម៉ែចាំស្អាត់ប្រេក | |

ម៉េចក៏ថ្ងៃមក    ទៅពេលថ្ងារនេះ ។

(ចំនុកនេះបានមកពី សហ. ព្រួប - ភុម)

ប.    ស្មើរអើយស្រីស្មើរ    ស្មើរអើយស្រីស្មើរ
បងរៀបដំណើរ    បានអ៊ីឲ្យបង ។
បានស្លាមួយមាត់    កន្ទ្រងមួយផង
បានអ៊ីឲ្យបង    បងទៅទន្លេ ។

ស.    អ្នកទៅទូកអ្នក    ឬទៅទូកគេ
អ្នកទៅទន្លេ    ប្រយ័ត្នជើងដៃ ។
មូសវាខាំយប់    សុចវាខាំថ្ងៃ
ប្រយ័ត្នជើងដៃ    ក្រែងខ្យល់រលក ។
ព្រោះខ្យល់រលក    បោកបែកផ្កាក្រែង
អ្នកប្រុសកំប្លែង    ស្តាប់ពាក្យប្អូនផ្តាំ ។
ប្អូនផ្តាំទៅអ្នក    អ្នកថាមិនទើង
គ្រឡាចមានជើង    ប្អូនមិនទើងយកប្តី ។

ស.    អ្នកជិះដំរី    ប្អូនស្រីជិះទូក
ធ្ងន់ពាមមាត់ជ្រូក    ឆ្នាំងបាយមួយគ្នា ។
អង្ករមួយក្តាប់    ដុតជាក្រឡាន

ខ្លាចស៊ីមិនបាន    គៀកកន្ទាយំ ៗ

ប. ចន្ទអើយស្រីចន្ទ    ចន្ទអើយស្រីចន្ទ

រំកាយប្រាំជាន់    ហៅចន្ទស៊ីស្លា ៗ

កំពោរអប់ស្ងួន    ក្រមួនអប់ផ្កា

ហៅចន្ទស៊ីស្លា    ចន្ទអើយកុំខ្លាច ៗ

ដំរីបង់មួយ    ដញ្ជោចចិញ្ចោច

ចន្ទអើយកុំខ្លាច    ដំរីបង់ទេ ៗ

ក្រសាំងទាបអើយ    ទាបអ្វីម្ល៉េះទេ

បងនៅស្រុកគេ    រកស្លាស៊ីគ្មាន ៗ

កាលនៅស្រុកបង    ស៊ីស្លទដើងពាន

រកស្លាស៊ីគ្មាន    ហៅស្រុកកំសត់ ៗ

(ស្រង់ពីប្រក្រតិទិនកម្ពុជា ឆ្នាំ ១៩៤៥)

សរើយសស្អាត    សអើយសស្អាត

លាងដៃកប់បាត្រ    នាងប្រាថ្នាអ្វី ៗ

ចង់បានកូនប្រុស    ទាមក្បាលដំរី

បើបានកូនស្រី    ស៊ុរេងដាំមុខ ៗ

ផ្គរលាន់ឯត្បូង ត្រយូងចេកក្តិប
លើកគ្នាសាមសិប ដណ្តឹងកូនគេ
ឪពុកថាឲ្យ ម្តាយថាទេ
លើកកូនឲ្យគេ ចង់ស៊ីក្បាលជ្រូក ។

ដំរីធ្ងន់ភ្លុក ក្របុកធ្ងន់ផ្ទៃ
យកគេធ្វើម៉ែ មិនដូចម៉ែខ្លួន ។

ម៉ុំអើយស្រីម៉ុំ ស្រីលេងបាយខុំ
ស្រីម៉ុំឃ្លាងបង ឃ្លាងអស់តាំងគេ
គេឃ្លាងម្តង ៗ ស្រីម៉ុំឃ្លាងបង
ឃ្លាងហើយឃ្លាងទៀត ។

ស្រីតូចទ្រទាប់ ធំឡើងឲ្យឆាប់
ឲ្យទាន់ឆ្នាំបង ស៊ីបាយផឹកទឹក
មួយថ្ងៃប្រាំដង ឲ្យទាន់ឆ្នាំបង
ពិសាខឆ្នាំក្រោយ ។

អាំអើយស្រីអាំ ព្រះពុទ្ធលោកផ្តាំ

ថាអាំដោយបង បងដាំពោធិមួយ
មិនទាន់បានឆ្លង បើអាំដោយបង
ឆ្លងពោធិពីរទាក់ ។

(ស្រង់ពីប្រតិទិនកម្ពុជា ឆ្នាំ ១៩៤៦)

# ល្បើកអក

## [ក]

( ចម្លងពីសាស្ត្រាស្លឹករឹត )

ពាក្យ ៧

ត្រាចត្រៀករលៀករលាយលោត កែវកោតកោងកាងមាក់ប្រាងផាប់
មាក់ប្រេងផ្ទុះផិតដើមទម្លាប់ ទន្ទាលូតប្រសព្វសន្ទឹកគ្នា ៗ
ថ្ងថ្ងាន់លំពាន់ទំពូងពោន ស្វាស្វាបត្រនុនសោកសែងព្រា
ព្រីងព្រំខ្នឹងខ្មួតឪជ្រឹងល្វា ពុទ្រាខ្នុរណាំងក្រសាំងខ្វិត ៗ
ស្រគំស្រកាក្ដាមក្ដុលក្ដួច ទ្រមូចទ្រមូងដូចស្រឡិត
ស្រឡៅតាត្រាវប្របប្រកិត គគិតគគីរស្បូកីលាយ ៗ
ស្តីស្តៅរក្តុស្តុរត្រមុលមៀន ទូរេនគូលែនប៉ែនដក់ពាយ
ដកពពង្រពេគកងពយ វល្លកយវល្លួរើកផ្អើកត្រដិត ៗ
វល្លិ៍ពាសដាសដោយដើមក្នុំក្នុង ប្រទាក់ខ្វាត់ខ្វែងប្រក់ប្រកិត
សន្ទឹកលូតលាស់ស្រស់ត្នានស្និត ធោមស្និទ្ធមិត្តមូលនឹងប្អូនពី ៗ
ទីនេះសុសសាយសប្បាយគ្រាន់ នឹងជិះនឹងជាន់ស្និទ្ធស្នេហា
បម្រើនកម្លាំងខ្លាំងក្លៀវក្លា ដោយសារព្រៃព្រឹក្សស្លឹកត្រជាក់ ៗ
នុះនួបុប្ផាចម្ប៉ារែក ប្អូនត្រេកស្រមៃដូចក្តីនឹក

កាលថ្ងៃអាស្រ័យនៅរួមរ័ក្យ    មិត្តភក្តិនឹងខ្ញុំជុំមិនបាត់ ។
អកទំយំគិតអាណិតខ្លួន    ព្រួយប្រួនស្ទើរប្រេះថ្លើមប្រមាត់
សព្វាប់សុបសៅនៅស្ងប់ស្ងាត់    មើលទីដទៃទៅរកស៊ី ។
ត្រយងកេងកងកុកក្រោងក្រែង    ក្អែកក្អាតត្មាតខ្វែងក្ងាផាន់ញី
ទុងទោមប្រវែកគតីកបីរ    ពីរៗសន្ទឹមទទឹមគ្នា ។
ចៀបចាបលលកលលេលេង    ទន្ទេងទន្ទឹមទឹងគ្ងប់
នោះនៃប្រខ្សែទោមទទា    ក្រសាស-កស្លាំងប្រដៀវ ។
ក្មានក្មាកប៉ោលះតាកទុង    សំកុងសំកុកលើឈើក្រៀវ
សេកសត្វសារិកាហាហើរខៀវ    កញ្ជ្រៀវប្រចឹកប្រឡែងគ្នា ។
ចន្ទុបស៊ិតចៅតាវ៉ើសត្វ    ហើរកាត់ទាំមករកគ្ងប់
កាកព្វប្រសព្វស្កប់ស្កល់ស្កា    រកោរកស៊ីទាំងពីរនាក់ ។
មេអកមើលយល់ខ្វល់ក្នុងចិត្ត    ថ្ងៃតិតត្រុងត្រួតតែងអាក់
រលឹកនឹកឮបងរួមរ័ក្យ    មិត្តភក្តិកាកព្វប្រសព្វគ្នា ។
ថ្ងូញយំសង្រេងកន្ទេងនឹក    ករង្រៃក្ដួចក្ដុកក្ដួសអង្គា
ក្ដាត់ជើងកើចចាប់មែកពុទ្រា    ដូលផ្ការជង្រាំងស្រទាងខ្ទាក ។
ក្ដាក់ប្រាណបានប្រឹងជើងខ្លួនជាក់    ជាធ្លាក់ជ្ញោះក្រេះស្លុះក្រោក
ហើរទៀងឈើធំទីរយោគ    ៖សោយសោកសល់សែនណែនឱក ។
ខ្សែតខ្សែតខ្សែកខ្សែលរអេះឧសរ    ទុញតុះទៀងរញ្ញចំនួញថា

ឱថ្ងៃថ្មើមចិត្តមិត្តសង្សារ ទៅឯណាបាត់ពេកចម្លែកម៉្លេះ ៗ
ប្អូនតែងតាមអ្នកស្រាក់ស្រូតរក អ្នកប្រុសពន្លកល្អចំណោះ
ប្រឹងហើយប្រឹងហត់មាត់ប៉ផ្អេះ តឹងទ្រូងស្ទើរប្រេះរលេះថ្លើម ៗ
ប្រុសអើយសត្វគេដទៃទៀត ចំទឹមចង្អៀតឈើមួយដើម
ដុំកូនស្រុះស្រួលជ្រួលជ្រៀវជ្រើម ប្រឡែងដណ្ដើមចំណីគ្នា ៗ
ខ្លះបៀតបៀរបានប្រាណប្របជិត ស្នាលស្និទ្ធដោយបែបសេពគប់
ប្អូនយល់ខ្វល់ចិត្តគិតប្រុសក្លា អន្ដាព្រួញព្រឹស្ទើរដាច់ខ្យល់ ៗ
មិនដឹងថ្ងៃណាទឹងបានស្បើយ កម្មអើយកម្មអ្វីតាមមកផ្ដល់
មកឃ្លាតខ្លួនប្រុសឲ្យឆ្ងាយឆ្ងល់ ឲ្យឆ្ងាយកាយគលកើតទុក្ខា ៗ
អកទំបន្តិចលេចឃើញទុង ហើរស្ទុងមកទំទៀបអាត្មា
អកក្រាបទន្ទាបកបសិរសា សួរថាលោកមាអាណិតក្មួយ ៗ
ក្មួយមានទុក្ខធ្ងន់ពន់ពេកក្រៃ ស្ទើរក្ស័យជីវិតពីព្រោះព្រួយ
ព្រោះប្រាណកំព្រាតែក្បាលមួយ ត្បិតក្មួយលោកមាលាទៅបាត់ ៗ
សន្យាថាទៅតែបីថ្ងៃ ប្រាស្រ័យសួរក្មូនកំព្រាក្ដាត់
ទិត្យនៅព្រៃភ្នំទ្រទំស្ងាត់ ខ្ញុំឆ្ងល់ទឹងបាត់មិនជួកាល ៗ
ខ្ញុំមកតាមរកគ្រប់កន្លែង បឹងស្ទឹងខ្វាត់ខ្វែងព្រៃព្រឹក្សសាល
ស៊ើបសួរសុសសព្វគ្រប់អម្បាល ដែលស្គាល់ស្និទ្ធស្នាលគ្មានប្រទះ ៗ
ឥឡូវលោកមាសូមប្រោសប្រាណ ប្រោសប្រាប់ឲ្យបានដឹងការខ្វះ

លោកមាមេត្តាថាឲ្យច្បាស់ ខ្ញុំទឹងរូតរះទៅតាមផាន ៗ
ខ្ញុំងង៉ើយក្ដយអើយមាសព្វថ្ងៃ អាស្រ័យទីនេះនៅនាឋាន
ហាក់ជាចន្ទោះសោះមិនបាន ឃើញប្រាណអកលោហារហើរមក ៗ
ឬក្រែងឯងអាត់តែមុជទឹក ចិត្តនឹកសិនសមទំតែរក
ត្រីសាច់ឲ្យបានមិនហ៊ានជ្រក ជូនមកចន្ទោះទងក្អែកមា ៗ
អកស្តាប់ខ្ញុំប្រាប់ថាមិនយល់ រងំចាល់ទុក្ខធំអស់អង្គា
ដាក់ក្បាលញ្ញកបក្រាបលុតលា ខ្ញុំហើរមីមាតាមទៀតទៅ ៗ
សង្វាតសង្វេតឯកកាយា ចូលក្នុងព្រឹក្សាព្រឹក្សាន្តជ្រៅ
ខ្ញុំញថាខណាក្អែកប្រុសនោះ អ្នកទៅទីណាអ្នកថ្លៃអើយ ៗ
ប្អូនគេជ្រែកគ្មានចន្ទោះ គៀនគោះគុម្ពោតពុំយល់ស្នៀយ
បឹងព្រៃស្ទឹងសព្វគ្រប់ទិសហើយ ប្រុសអើយថ្លៃណាទីងជួបជួន ៗ
អកយំសង្វេងសម្លេងស្អ អនិច្ចាអកខំត្រាំទ្រមខ្លួន
ទ្រមខ្វាំងកាំងខ្វាចឃ្វាតប្រុសស្ងួន ទុក្ខធ្ងន់ថែមថប់ចំប្រប់ប្រាណ ៗ
កាងស្វាបជាបស្ងុតន្ទួតញាក់ ដូចគេចម្លាក់ដល់ដែនដាន
ដល់ដីអស់ស្រីសែនខាន ទណាក់ធរណីត្រីក្បាល ៗ
ទន់គោះជ្រោជ្រប់សន្ទប់ស្មូន្យ លង់លុះដឹងខ្លួនក្រោកដោះដាល
ទំះហើរទំលើព្រឹក្សាសាល កើតការលក់សត់សោកកើតថ្មី ៗ
គ្រានោះមែនមានសត្វតាដក់ ហាចហាក់ហោះបករកចាប់ត្រី

បានផលយន់យល់សត្វអកស្រី　សោកប្តីហែបពេបឥតស្បើយ ៗ
តាជក់ហក់ចុះមោះមកទំ　សួរថាក្រមុំមាសតាអើយ
មានហេតុកេទអ្វីណាស្រីអើយ　ចៅអើយប្រាប់តាឲ្យដឹងជាន ៗ
គ្រានោះបក្សីអកស្រីសត្វ　ប្រណិបតន៍ថ្លាស់ឆ្លើយស័ព្ទសងសារ
ថាឱលោកតាសូមប្រោសប្រោណ　សូមតាទស្តាប់ខ្ញុំជម្រាបតា ៗ
សង្សារតែមួយជាត្រួយចិត្ត　ផ្ទាប់ស្និទ្ធស្នេហ៍ស្នាលជាធម្មតា
ប្រែព្រាត់ប្រាសព្រាកចាកឋាន　ប្រាប់ថាទៅរកសួរកូនចៅ ៗ
សន្យាថាឆាប់មកទេកូវ　ឥឡូវបាត់យូរគួរឲ្យក្តៅ
ក្តុកក្តួលរំជួលចិត្តមួយម៉ៅ　ទ្រូងចៅស្ទើរធ្លាយភ្លាយស្ទើរធ្លាក់ ៗ
លោកតាជាចាស់ច្បាស់សេចក្តី　ជាស្រីកល់កាយកាមភាគភក់
ដូចជាតណ្ហាឡើងគ្មានអាក់　សស្រាក់ហៀរហូរពោរពាសថ្នល់ ៗ
ដូចខ្ញុំក្រមុំយ៉ាងប៉ុណ្ណោះ　មិនចេះហៅឲ្យបានផ្អែតផ្អល់
ចំណីឃ្លាយត្រីផ្ទឹមមិនដល់　ស្វិតស្វល់ចោលនៅចៅមិនថា ៗ
សង្សារសង្ស័យជាងជីវិត　មិនគិតស្ទើស្លាប់តាមវាសនា
គេកាប់គេដោតដូចម្តេចម្តា　ដោះខ្ចាវមាសមិនមានក្រែង ៗ
បាត់អស់របស់ទ្រព្យគ្រប់ប្រការ　ចិន្តាកាកាតមិនស្តាយស្តែង
ឯបាត់សង្សារដូចខ្ញុំឯង　រមែងមានទុក្ខពុំសុខស្បើយ ៗ
តាជក់បានស្តាប់គ្រប់ប្រការ　ឆ្លើយថាចៅស្រីស្តីត្រូវហើយ

វិស័យសង្ការមាសតាអើយ　　ទៅអើយទៅថាតាពូលចិត្ត　ៗ
ដូចជារូបតាដកដល់　　កាយកល់ស្ដមពេកស្បែកជ្រីវស្វិត
ជើងដៃសរសៃរញ្ញូរចរែត　　ល្ហេវល្ហិតកម្លាំងកាំងស្អាតេ　ៗ
ដូចេះម៉េះមេចគង់មានចិត្ត　　ស្នេហាស្និទ្ធអាល័យរូបកង្ស្រី
ល្អលួះត្រយ័ចង់បេតី　　មេត្រីត្រេកត្រង់ការកាមគុណ　ៗ
ស្រដីឡកលយឲ្យផ្ដើសផ្ដាស　　ប្រឡះប្រឡើសលើសលៀនស៊ុន
វង្វេងដោយនាមនាំខុសទុន　　ខ្លួនចាស់កម្រួនកម្រើកចិត្ត　ៗ
សោបសេលខ្លួលខ្លាំងណាស់　　ខ្លួនចាស់កំព្រឹងក្អឹងក្អេចគិត
ទឹកស្អុនថាប្រាណនៅមានឫទ្ធិ　　ដល់បានជិតលោញ្ញូគង្គ្រញូថយ　ៗ
អេះអុះអាបឡាបស្ទាបតែដៃ　　មៃដាយថាអារ៉េតេផ្ទើប៉យ
គេស្ដោះមកផ្ទើយហើយក្រោកក្លួយ　　ឯងអៀនស្រមយស្រមេះមុខ　ៗ
គេគេចបាត់ទៅនៅទឹកស្ដាយ　　កង្កាយផ្អែតផ្អួលខ្លួលកើតទុក្ខ
ជ្រងោចខ្លីរនៅប្រងិក　　រិតក្ដៅខានមិនក្បានចិត្ត　ៗ
ខ្លួនប្រាណមិនបានកឹតថា　　ប្រាថ្នាឲ្យបានតែដៃជិត
ដៃដលប៉ះពាល់ប្រកៀកកិត　　ទើបបានស្បើយស្បែតឥតទុក្ខា　ៗ
ខ្លួនតាចាស់ព្រឹទ្ធិគិតពើកបង់　　បំណង់បើនាងនៅរូបា
ក្មេងសោះទាន់អស់ពីកាលណា　　កំពុងខ្លាំងក្លារបាសក្អែត　ៗ
កម្រៃតពាល់ដល់ដោយដៃ　　វិស័យខ្លួនក្មេងគ្មានទោសហេតុ

ឈាមនៅកវេងថ្លាអណ្តែត　　ទឹងឲ្យផ្អុលផ្អែតម្តេចមាសតា ៗ
នុះចៅសម្លាញ់អញអាណិត　　ព្រោះត្បិតនាងឯងក្មេងណាសា
កំពុងពេញពាលស្រុបាលក្តា　　តណ្ហាកម្លាំងបន្តិចផង ៗ
តានៅទីនេះជាយូរហើយ　　ចៅអើយគ្មានឃើញសល់ជាមួង
មិនដែលអកណាទឹងហើរចួង　　តែសង់ហាមយំពុំមានឡើយ ៗ
ចៅទៅសួរគេដទៃសួន　　ក្រែងជួនគេឃើញណានាងអើយ
អាណិតចៅតាអីម៉្លេះហើយ　　ចៅអើយទៅចុះដូចបណ្តេញ ៗ
បក្សីស្រីអកស្តាប់តាជក់　　លោហាក់ហៀរហើរលេលើចេញ
ទទះបក្សាលឿនស្ទុងស្ទេញ　　ទ្រូងម្នេញពេញទុក្ខពុំសុខចិត្ត ៗ
ចំហើរបានដល់យល់ទីទួល　　ព្រៃស្រួលស្រោងស្រស់លាស់ប្រកិត
ប្រគងទងទាក់ហាក់ប្របជិត　　អកគិតថាទព្រៃនេះហើយ ៗ
ល្អពេកបម្លែកនឹងព្រៃបឹង　　ព្រលឹងប្រុសនៅនេះដឹងអើយ
ប្អូនហៅនោម ធ្ងាមិនព្រងើយ　　ប្ដួយខឹងហើយប្ដូហ្មាអ្នក ៗ
បើខឹងម្តេចម្តាមេត្តាធ្ងើយ　　ប្រុសអើយអាណិតចិត្តប្អូនស្ត្រ
ប្អូនស្មានថាបាននៅរួមរ័ក្ស　　រួមរូបវរល័ក្ខណ៍ដល់អស់ជន្ម ៗ
មិនដឹងមកប្រាសនិរាសគ្នា　　ប្អូនមហាចំបែងតែងទុក្ខធ្ងន់
ទុក្ខយើងព្រាត់ប្រាសប្តីប្រពន្ធ　　ខ្លាំងលន់លើសទុក្ខគ្រប់ប្រការ ៗ
ទុក្ខមួយព្រួយចិត្តត្បិតអត់ឃ្លាន　　ទុក្ខពីរទឹងគ្មានស្បៀងអាហា

ទុក្ខបីនឹងគេធ្វើទោសា　　ទុក្ខបួនការយារកើតព្យាធិ ៗ

ទុក្ខប្រាំនឹងប្រាសទ្រព្យសម្បត្តិ　　ទុក្ខប្រាំមួយនឹងសត្វបង់ហើយ

ទុក្ខប្រាំពីរនឹងលង់ក្នុងវារី　　ទុក្ខប្រាំបីអគ្គីឆេះពេលពល ៗ

ទុក្ខប្រាំបួននឹងខ្លួនធ្វើឲ្យក្តី　　មិនមានប្រណីដោយពុតពាល

ទុក្ខដប់គេស្អប់ធ្វើង្គាល　　ផ្ញុញផ្ញាលគិតកាលសម្លាប់កាយ ៗ

ទុក្ខតពីនេះច្រើនសណ្ឋាន　　ពុំបានទុក្ខស្មើប្រាសសហាយ

ប្រាសឪពុកទុក្ខតិចជាងប្រាសម្តាយ　　ប្រាសកូនមិនស្តាយដូចប្រាសប្តី ៗ

រីទុក្ខនឹងប្រាសប្តីប្រពន្ធ　　ធំលន់ធ្ងន់លើសទុក្ខអ៊ីៗ

អត់ឃ្លានគ្មានបាយដូចម្តេចក្តី　　ប្អូនស្រីគ្មានថប់គ្រប់ប្រការ ៗ

ថប់តែប្រុសប្រាសទិពប្រាណ　　ពុំបានមូលមិត្តស្និទ្ធស្នេហា

មិនដឹងប្រុសទៅទីឋានណា　　កន្ធានថប់ធ្ងួនមួនមិនះស្បើយ ៗ

អកយំបណ្តើរហើរបណ្តែត　　ស្តាប់ហេតុក្រែងបីយំធ្ងន់ធ្ងើយ

ព្រះពាយបក់បោកមករំភើយ　　រហើយកាកាយខ្លាយក្លិនផ្កា ៗ

ក្រអូបឈ្ងុយឈ្ងប់ត្រឡប់ហួង　　ផាត់ត្រង់ផាត់ចូលបំនាសា

មេអករំជួលអួលឱភា　　ទួញថាឱប្រុសសំឡាញ់ប្អូន ៗ

ព្រះពាយផាត់ផើយរំភើយផាយ　　ត្រសាយពពកមកពពួន

ចង្កុំក្លិនផ្កាភាដូន　　ផាត់ផាប់អង្គប្អូនក្រអូបសាយ ៗ

ប្អូនផ្អកលើកទឹករលែក　　ក្បិតបែកពីប្រុសប្រាសទៅឆ្ងាយ

កាលនៅនៃបនិត្យផ្ដិតផ្ដេកកាយ ក្លិនក្លាយជាប់ខ្លួនប្អូនមិនបាត់ ៗ
ក្លិនអ្នកប្រៀបហាក់ដូចក្លិនផ្កា រាគាបក់បោកពពូនសាត់
ប្រៀបដូចអ្នកប្រុសអ្នកប្រាសបាត់ ដូចខ្យល់ផាត់ពពកជ្រកព្រៃផ្សៃ ៗ
សុរិយ៍នទន់ទេរបែរបស្ចិម សន្ទឹមលិចបាត់ស្មើថ្ងៃ
បក្សីសេក្ខអកជ្រកអាស្រ័យ នៅព្រៃដើមស្រល់ខ្ទុលក្នុងកាយ ៗ
រៀបកប់ទំនួញទួញថែថា ឱណាអ្នកប្រុសអ្នកប្រាសឆ្ងាយ
ប្អូននៅកំព្រាជាមេម៉ាយ កាខអើយប៉ៃណាម៉ែហ៊ានហ្នា៎ ៗ
អគ្រាគ្រស្រងាត់សត្វអកយំ ទូរគមឯកោគួរអនិច្ចា
ជួនថប់ទឹងចិត្តគិតបង្ក្រ ស្អកស្អាសម្លេងរងំស្គមខ្លួន ៗ
ផាសទុំអកយំស្ទូរគ្រលួច ព្រឺព្រួចរងាររងាប់ជួន
ជាទុក្ខចំប្រប់ថប់ព្រួយព្រួន ព្រួយប្រាណមាំមួនមិនល្ហៃល្ហើយ ៗ
ទួញយំ ៗ យប់មិនឈប់ដេក ទឹកភ្នែកតក់ស្រក់ឥតស្បើយ
ថ្ងៃងថាពុំងាប្រុសប្អូនអើយ ប្ដីអើយរងាពន់ពេកណាស់ ៗ
ប្អូនធ្លាប់កៀតកិតជិតអង្គា រងាស្រាកស្រន់អន់បាត់ខ្លះ
បានស្ដាប់អ្នកប្រុសខ្ញុំសក្រែលក្រាស់ ត្រាស្ទុះពកំងរបាំងខ្យល់ ៗ
តទ្រូវអ្នកទៅបាត់សុងសូន្យ ចោលប្អូនម្នាក់ឯងតែងកន្វល់
ហោលហ[illegible]តេងតាងគុញតប់ប្រមល់ សែនធ្ងល់សល់ឆ្ងាយកាយនោមស្ទុ ៗ
អកយំយ្លូរលន់លុះព្រឹកព្រាង ភ្ញីស្វាងស្រទ្បូះរះរៀងបុទ្ធិ

សត្វសត្វប្រវាត់ហើរប្រកិត    ប្រកិនដោយបនកនគូរ
អកយល់ទល់ទុក្ខមុខក្រៀមផ្អុស    ទុក្ខម្នោតោមនស្សសែនកំព្រា
កំព្រោះម្នាក់ឯងវែងវេទនា    អង្គារន្ទត់ស្មុតស្មារតី ៗ
ខះខំតម្រង់អង្គកាយកល    គិតដល់បក្សាជាស្វាមី
ប្រឹងហោះហើរផ្ទោះខ្ពស់ឡើងខ្ពី    បក្សាសត្វសឹងរឹងរេក ៗ
គន់គយដោយសត្វព្រៃព្រឹក្សា    បក្សាទ្រះទៅជ្រៀតជ្រក
ចំប្រប់សត្វដោយជ្រោយឈ្លូងញក    ងេកងករករក់វិវេចិត្ត ៗ
អកហើរពីព្រឹកព្រះសុរិយា    លុះគ្រាព្រលប់យប់ងងឹត
បានដល់ព្រៃក្នុងទំនៅទិត្យ    ទៀបជិតទ្រូងនៃអកប្តី ៗ
អកទំសំកុកង៉ុកក្បាលជ្រប់    សញ្ចប់នៅលើដើមស្រឡី
ទឹកភ្នែកតតក់ស្រក់ដល់ដី    អកស្រីរយោគសោកគ្មានឈប់ៗ
គ្រានោះមានសត្វសារិកា    នៅដើមបង្គៅជាទីមូប់
យល់អកចម្លែកស្រែកយំយប់    សញ្ចាប់សញ្ចឹងទឹកសង្ស័យ ៗ
ព្រួសត្វរៀបរាប់រឿងរកប្តី    បក្សីសារិកាអាណិតក្រៃ
និយាយប្រាប់ប្តីសីថាហៃ    អ្នកថ្ងៃអ្នកស្តាប់ស័ព្ទអកយំ ៗ
រាប់រៀបទំនួញម្លួញរកប្តី    ចិត្តស្រីរូបគេហើយរូបខ្ញុំ
អកនេះប្រាកដ្ឋអកក្នុំ    ដែលទំនៅទីគគីរខ្ពស់ ៗ

បានជាហៅនាមថាគូអកក្កំ ត្បិតខ្ញុំដឹងរឿងកាលគាត់រស់
ពីកាលដែលខ្ញុំមានផ្ទៃពោះ អ្នកប្រុសមិននៅទៅរកស៊ី ៗ
អ្នកឲ្យខ្ញុំនៅចាំសំបុក ផ្ញើទុកនៅនៃព្រៃគីរ
គ្រានោះអកក្កំទាំងឈ្មោលញី កូនពីរនៅតូចៈទើបដុះក្រាស ៗ
អកពីរអត់ឃ្លាននូវអាហារ ដោយសាររបឹងរីងខ្លាំងណាស់
ទឹកបឹងត្រពាំងគោករីងខះ ទឹកស្រះទឹកស្រែតែដូចគ្នា ៗ
អកអត់ចំណីប្តីប្រពន្ធ ស្គមលទណាស់ពេកពីរអង្គ
អកប្តីស្រីដ៏ទឹងភរិយា ឲ្យគ្នានៅក្រាបចាំសំបុក ៗ
រក្សាកូនតូចទាំងពីរមិញ ខ្លួនចេញទៅរកត្រីស៊ីចុក
អកញីគ្នាអរតកតក្ក រីកមុខញញឹមសង្ឃឹមប្តី ៗ
គ្នាផ្តាំថាទៅកុំនៅយូរ គិតគូរឲ្យខំរកតែត្រី
សន្យាថាទៅតែថ្ងៃបី អកស្រីផ្តាំសព្វគ្រប់ប្រការ ៗ
អកប្រុសស្ទុះហើរលើទៅ មិនដឹងគេចទៅទិសបានណា
អកស្រីយំក្រៃប្រែកខ្ទេខ្ទា ហើរហោះចោលកូនគិតតាមប្តី ៗ
ទៅចោលកូនបាត់មានសត្វក្អែក សង្វាតៈហើរហោះផ្ទោះមកខ្ចី
ចឹកស៊ីកូនអកជាចំណី ចោលឆ្អឹងមកដីហើយហើរទៅ ៗ
លុះយូរបន្តិចលេចមេអក ហើរមកដល់ទីលើលំនៅ

ជាទុក្ខមើលមុខជាំជាំខ្មៅ ទៅរករកកូនសូន្យពុំយល់ ។
ព្រៃតែទំនួញទួញពីប្ដី មានស្រីអកបឹងរួមណ្ដាល
ពោលកូនប្រពន្ធពុំវិល អំពល់អំពីទីលំនៅ ។
ហើយទួញរកកូនទាំងពីរបាត់ ក្ដៅក្ដាត់បោកខ្លួនធ្លាក់ចុះទៅ
ដល់ដីសន្ធប់សុបសូន្យសៅ ដោយក្ដៅទឹងប្ដីមានស្រីទៀត ។
មួយក្ដៅខឹងកូនសូន្យបង់បាត់ អកសត្វផ្ដាច់ជន្មស្លាប់បង់វៀត
គំណាថ្ងៃតពីនោះទៀត ឃើញឈ្មោលពោលបៀតហើរមកដល់ ។
ទំលើសំបុកមុខមិនរក ធ្វើក្អកក្អឹះៗគិតខ្វាយខ្វល់
សម្បុរស្មុគស្មាំងទាំងកាយកល់ ទំនងខ្វល់កង្វល់ចិត្តត្បិតមានពីរ ។
ព្រួញទួញរៀបរាប់គ្រប់ប្រការ យំថាអកអូនអកញី
ខឹងម្ដេចចាំកូនសូន្យដល់ពោលទី មាសមេកាត់ចិត្តពោលបោះបង់ ។
អកឈ្មោលរំពោតឈ្ងោកមើលដី ឃើញស្រីអកស្លាប់ក្រៀមក្រញង់
ឃើញកូនទាំងពីរក៏ស្លាប់បង់ ហើរត្រង់ចុះទៅដល់ដែនដី ។
កាន់ស្លាបក្រសោបឱបខ្លោចកូន សន្ធប់ស៊ុងសូន្យទៅទៀតខ្ចី
ដំណាលកាលលោះទៅរកត្រី ពុំបានក្វេបស្រុកសំបុកនៅ ។
រៀបរាប់សព្វសុសស្រុះឡើងហើរ លះលើទម្លាក់ខ្លួនស្លាប់ទៅ

ប្រពន្ធចុងពោលទុកឲ្យព្រៅ ឆោមឆ្មៅល្មមចាំយកជាយ៉ាង ៗ
សារិកាឈ្មោលឮប្រពន្ធថា ផ្សៀងទុទកាមាកែគេបផាង
វេលាសាសព្វបក្សាការ ក្អេងក្អាងបរបាថានាងអើយ ៗ
នាងឯងកុំប្លែងថាដូច្នោះ ខ្លោចប្រុសគម្រក់អន់ឥតត្រើយ
ស្វះស្វែងថាឯងគ្រាន់បើហើយ ដើមឡើយអ្នកឯងទៅរកត្រី ៗ
យកមកចិញ្ចឹមប្រពន្ធកូន បាត់សូន្យមិនឃើញបានមានអ្វី
ទៅផ្ទួបចម្រុះតែនឹងស្រី សេចក្តីវេរគ្នាផ្ដាំកេរ ៗ
ក្អួចអស់សំដីខ្ជីក្រឡះ បានចំពោលបាស់មិនទឹកនា
ចិត្តជាសម្ផធន់ពន់វេលា ហ៊ានធ្វើឲ្យគ្នាបែរបង្ខាត ៗ
ខ្លោចអាគម្រក់អ្នកទីទួល មិនគួរឲ្យយកជាក្បួនខ្នាត
សមតែសម្លដីចំណីគ្នាត ទើបសមមារយាទបុករូបរាំ ៗ
មេណារាំដោយអាដែងនោះ ចំពោះមេនោះស្រីសាធារណ៍
សូវធ្វើសំផឹងវិញក៏ជា បានប្រាក់ដួលស្ពាក់ឲ្យមើល ៗ
នាងឯងកុំឲ្យអញយកយ៉ាង រឿងរ៉ាវទោសអញ្ញាមិនព្រើល
ហើរពោលកូនទៅទៅដេរ ជួបបែរងើលងងឹងមក ៗ
មួយអត់មួយឃ្លានពន្ធលើគ្នា ក្លឹកក្អួចការង៉ាងើបក្បាលជ្រក
មិនបានគិតគួរស្រួលស្រីបរក ជាការសម្ពេហ៍យកជាគួគាប់ ៗ

ចេះឃើញតែប្រុសនោះមិនថា ប្ដីសីនណាក្ដក់ប៉ោះជាប់
ស្រីនោះផ្ទួប្ដោះគេមិនពប់ អញស្អប់ស្នាណាដល់និញ្ញូខ ។
កុំឲ្យឃើញយល់យ៉ាងដូច្នោះ ជាតិនេះជាតិក្រោយកុំឲ្យមាន
ឃើញយល់អំពល់ចិត្តវិញ្ញាណ បើគ្មានស្ងួព្រៅនៅទទេ ។
នាងឯងយកអញទៅប្រដូច មេខ្វូចនេះហើយតិចអញដេរ
យ៉ាងអញមិនចេះវេះវៀចវេរ វិះវេរកកល់តែដូច្នោះ ។
អ្នកណាក្បេពចិត្តយ៉ាងអញ នេះពេញជាក់ជាតិជាហៅប្រុស
ស្រអាំស្រអុកទុក្ខចិត្តពុះ មិនខុសខ្វូចទេកុំថៃថប់ ។

គ្រានោះបក្សីស្រីអកស្ដាប់ ពួសត្វសារិកាផ្កាសត្វសព្វ
ឈឺចិត្តឆ្អិតឆ្អល់ខ្វល់ហ្វឹងឡប់ ចំប្រប់ប្រាណប្រឹងរំពឹងគិត ។
ថាដើសារិកាថាអម្បាញ ដៀលអញឯងស្មោះចំពោះពិត
ទុះហេតុតែកម្មទាំងនិត ប្រព្រឹត្តឲ្យខុសប្រុសមើលងាយ ។
ដើគេប្រាកដប្រកាន់ចិត្ត ស្នេហ៍សិទ្ធគិតក្រែងលែងព្រាត់ព្រាយ
ស្មានតែចាំនេរដូចនិយាយ បង់កាយទទេគេខ្វូចសោះ ។
បើបានដឹងដានដូចសារិកា កាលណាទឹងក្ដួយដោយដល់ម៉្ញោះ
ប្រាកដស្ងួតអត់ឲ្យក្រៀមក្រោះ ស្រះណោះទឹកពោះដេកឲ្យងាប់ ។
បើត្រាំពុំបានមានមែកឈើ សស្អុលរុករើកុំឲ្យធ្លាប់

កុំឲ្យឆ្ងោយដោយគេឥតគំនាប់ ឥតគំនិតគិតគាប់ឲ្យគេថា ៗ
មេអកអន់ចិត្តឥតទុកដាក់ អៀនអាក់ក្ដុកក្ដួលអួលឧរា
ទឹកខ្មាសសំដីនៃសារិកា ឈឺផ្សាផ្សាយផ្សព្វចំប្រប់ប្រាណ ៗ
ព្រះចន្ទរៀងរះស្រឡះមក ពពកព្រះពាយផាយផាត់ប្រាន
មេអកតានតឹងរឹងរំខាន ពុំបានឈប់ដេកក្អែករំពៃ ៗ
រកមើលគតីរទើអកក្អំ តែងទំសំណាក់នៅនាព្រៃ
ដោយពាក្យសារិកាថានោះនៃ អកស្រីឃើញពិតឥតបង្អា ៗ
គិតថាសារិកាស្ដីប្រាកដ ទឹងរត់រិះព្រះសុរិយា
ពុំបិទខ្មាសអស់សត្វសារិកា គេថាមុខគួរឲ្យឈឺណាស់ ៗ
ចង់ទៅឥឡូវទាន់យប់ស្ងាត់ ហើយកាត់ទៅឲ្យបានឃើញច្បាស់
បើពិតដូចពាក្យទឹងប្រែប្រាស ក្រឡាស់កៃដកគំនិតថ្មី ៗ
អកគិតដូច្នោះស្ទុះហើរទៅ សំដៅគតីរតាមសម្ដី
សារិកានិយាយប្រាយប្រាប់ប្ដី អកស្រីដល់ដួចក្ដួចចិន្ដា ៗ
ចូលចំទ្រនំនៃអកប្ដី បក្សីយល់ជាក់ជាក់កាយា
ទំព្រោកល្ហោកមើលសព្វប្រការ ដោយសារពន្លឺព្រះចន្ទថែង ៗ
យង់យល់សម្បុកទុកទើរកូន ស្ងាត់ស្ងួនឲ្យគ្មានយល់ហៅកន្ទេង
គិតថាគតីរទើនេះឯង ពុំប្លែងប្លែកពីពាក្យសារិកា ៗ

យល់ពិតប្រាកដជាទ្រទំ អកក្ដុំជាសាច់សង្សារ
តាំងមែនជាទីអកឯណា គិតថាដូចព្រោះស្ទុះហើរទៅ ៗ
ចរចុះលុះដល់គល់គគីរ អកញីបានយល់ខ្មោចប្ដីនៅ
ស្ដាប់គរលើគ្នាក្នុងស្មៅព្រៅ នឹកក្ដៅក្ដាត់ក្ដួលអួលក្នុងចិត្ត ៗ
ស្ដីថាប្រាជ្ញាអ្នកឯងនេះ ដឹងយ៉ាងម៉េះៗអញមិនស្បិត
រវល់អំពល់ឲ្យបង់ចិត្ត ដើស្ដាយគំនិតគិតឲ្យខុស ៗ
អញគិតថាចិត្តជាដូចមាត់ ថាអីប្រាកដដូចអស់ប្រុស
បើដឹងពុតពាលពីកាលនោះ មិនឲ្យចូលចុះទេអាពាំ ៗ
ណ្ហើយចុះស្មុញ្ញោបានជាជ្ងោយ ថ្ងស់ធ្លាក់ខ្លួនដោយឥតប្រាជ្ញា
ធ្ងុរធោតលលោតដោយតណ្ហា បង្ការបង្កអស់ទៅហើយ ៗ
ទឹងកែយកល្អក៏មិនបាន គ្រប់ប្រាណគេស្គាល់មិនសល់ឡើយ
ចង់ស្លាប់ឥឡូវទៅជាត្រើយ ថាហើយស្ទុះហើរលើវេហាស៍ ៗ
ធៀងធាបទន្លាបចំដើមបេង សរទ្រង់សទ្រៃក្រៃមហិមា
អកស្រើស្រែដីខ្ញុំសូមលា ប្ដឹងអស់ទេវានៅសព្វស្ថាន ៗ
ឋានទេវាជាទីពួចក្ខុ សូមអ្នកអាសូរសូមប្រោសប្រាណ
ជួយចាំជាតិខ្ញុំជាតិរច្ឆាន ចុកប្រាណដោយប្រុសខុសយ៉ះហា ៗ
បង់កេរ្ដិ៍ព្រោះគេមានប្រាជ្ញា បង់ការគេទុកជាស្រីពោរ
ស្រះចិតទុកដូចជាចេញ្ចាល មិនះបាដូចចិនថាមិនល្អ ៗ

សុខអីប៉ុណ្ណោះខុសទៅហើយ លោកអើយនេះលោកទេពនិករ
មេត្តាប្រោះព្រំដោយស្មោះសរ ស្តាប់ខ្ញុំអង្វរសូមសច្ចា ។
ខ្ញុំកើតជាតិនេះប្ដោះទៅហើយ ម្ចាស់ហើយទឹងរស់ក៏ឥតការ
សូមស្លាប់ចាប់ជាតិដោយសញ្ញា ប្រាថ្នាកុំឲ្យជួបឥឡូវ ។
កើតជាតិនានាជារូបអ្វី សេចក្តីដែលទឹកកើតអាស្រូវ
កុំឲ្យឃើញយល់អម្ពល់ត្រូវ រៀងទៅដរាបដល់និព្វាន ។
ឲ្យរស់បក្សីជាប្រីសត្វ ចូរប្រុងប្រយ័ត្នស្តាប់ពាតិមាង
ចាំទុកទៅមុខកុំពារពាន ស្មោកស្មានគំនិតគិតយ៉ាងខ្ញុំ ។

(នៅមានត)

—~~~—

# វប្បធម៌សំស្ក្រឹតអំពីបុរាណ

ព្រះមហាវីរិយបណ្ឌិតោ ប៉ាង - ខាត់ រៀបរៀង

(ស្រង់ចេញពីទស្សនាវដ្ដីពុទ្ធិកសិក្សាឆ្នាំ ១៩៥៨)

ក្នុងអត្ថបទមុន ខ្ញុំបានទាញយកប្រវត្តិសាស្ត្រខ្មែរពីបុរាណជាបទសង្ខិតន័យ តាមសេចក្ដីសិលាចារឹកទាំងឡាយដែលអ្នកប្រាជ្ញបានរកឃើញមក ពោលខ្លះសម្រាប់ប្រដាប់ប្រាជ្ញា លោកអ្នកអានទុកជាការផ្ដើមសករាជមួយទៀត ដើម្បីជាជំនួយជួយឲ្យយល់វប្បធម៌សំស្ក្រឹតក្នុងចក្រអក្សរសាស្ត្រនីមួយៗ ។ ក្នុងសម័យចេនឡានេះ អត្ថបទក្នុងសិលាចារឹកទាំងឡាយខ្លះ យើងអាចទុកជាការផ្ដើមចក្រអក្សរសាស្ត្រមួយបាន ហើយសិលាចារឹកដែលយើងគួរយកជាវត្ថុធាតុសម្រាប់ពិចារណាមាន ៥ គឺ សិលាចារឹកវត្តលួងកៅ ១ សិលាចារឹកហាន់ជ័យ ១ សិលាចារឹកអង្គជំនិក ១ សិលាចារឹកវត្តព្រៃវៀរ ១ សិលាចារឹកក្រុមសម្បូណ៌ព្រៃគុក ១ ។

យើងមើលសិលាចារឹកវត្តលួងកៅហើយ សឹមមើលសិលាចារឹកដទៃៗតាមលំដាប់សករាជទៀត ។ សិលាចារឹកវត្តលួងកៅជាសាសនាព្រាហ្មណ៍នៅទីវត្តលួងកៅជាទីបរិវេណចម្បាសក្ដិ ជាសិលាចារឹកចាស់មួយជំនាន់សម័យនគរភ្នំ តែមានបែបបទផ្សេងពីគ្នា មិនមានកាលបរិច្ឆេទទេ ហើយលក្ខណៈអក្សរនាំឲ្យយល់ថានៅក្នុងគ្រឹស្តសតវត្សទី ៥ ទំនងជារបស់ខ្មែរ តែអ្នកប្រាជ្ញខ្លះយល់ថាជារបស់ចាមពីបុរាណ, និយាយពីព្រះរាជាមួយព្រះ

អគ្គ ព្រះនាមទេវានីកៈ សោយរាជ្យនៅក្រុងជាទីបរិវេណចម្ប៉ាសក្តិ នៅគ្រិស្តសតវត្សទី ៥ ជាទ្រង់មកពីប្រទេសឆ្ងាយតាមសេចក្តីត្រូវការទេវតានៅលិង្គបព៌តជាលិង-កៀ-ប៉ូ-ប៉ូ របស់ចិន ដើម្បីប្រសិទ្ធិកំពង់បុណ្យធំ (មហាតិថិៈ) ក្នុងទីនេះ ។ ដើម្បីពិចារណាព្រះនាមថា "ទេវានីកៈ" ដែលជាប្រធានសព្វក្នុងគម្ពីរសិលាចារឹកនេះ មានការចាំបាច់ត្រូវនិយាយពីមូលហេតុផ្សេង ៗ ដែលទាក់ទងនឹងរឿងនេះផង ទំងខានពុំបាន ព្រោះនឹងបានជាពន្ធុក្រោលបង្គុមើល ព្រឹត្តិការណ៍ដែលនាំឲ្យកើតជាព្រះរាជអាណាចក្រខ្មែរឡើងក្នុងកាលនោះគឺ ៖

១– តាមសន្និស្សន៍នៃអ្នកប្រាជ្ញខ្លះយល់ថា ក្នុងគ្រិស្តសតវត្សទី ៨ ទីទំនាបទន្លេមេគង្គត្រង់ខាងលើជួរខាង គួរទុកជាទីឋានបិតនៅក្រោមអំណាចនៃប្រទេសចម្ប៉ា ឯទីវាលខាងត្បូងក្នុងដែនកែកនិងទីទំនាបទន្លេមេគង្គត្រង់ខាងក្រោមជួរខាង បិតនៅក្រោមអំណាចក្សត្រវង្សកម្ពុជៈ ហើយកាលនោះទំនងជានៅក្នុងចំណោះប្រទេសនគរភ្នំផង លុះដល់មកចុងគ្រិស្តសតវត្ស ទី៥ ក្នុងរជ្ជកាលព្រះបាទទេវានីកៈ (ហ្វាន់-ចេង-ចេង នៃប្រទេសចម្ប៉ា?) (តាមសេចក្តីក្នុងសិលាចារឹកលួងកៅ) ឬក៏ព្រះរាជាជាលំដាប់តមក ព្រះរាជាវង្សកម្ពុជៈ គឺព្រះបាទស្រុតវរ្ម័ននិងព្រេង្គវរ្ម័ន បានពង្រីកអាណាចក្រព្រះអង្គទៅដល់តម្បន់ខាងជើងក្នុងដែនកែកៈ បំបនកម្មលើលិង្គបព៌តនូវគិរលិង្គនាមភគេ្រត្មៈ ជាអាទិទេពនៃជាតិប្រទេសចម្ប៉ា សំគាល់ឲ្យឃើញថាទំនងជាទ្រង់

មានជ័យជំនះឈ្នះចាម ហើយត្រួតត្រាប្រទេសចម្ប៉ាសក្តិ ។ សេចក្តីត្រង់នេះ មានទំនងដូចជាយើងបានដឹងតាមពង្សាវតារយើងថា "ព្រះថោងជាបឋមក្សត្រ បានធ្វើសង្គ្រាមនឹងព្រះបាទអស្សរេចយ្យរាជជាស្តេចចាមហើយមានជ័យជំនះរឿងនេះទេដឹង?។ ចំណេរកាលមក ទើបព្រះរាជានៃរាជវង្សកម្ពុជៈទី ៤ និងទី ៦ គឺ ព្រះបាទភវវរ្ម័ន និងចិត្រសេនាមហេន្ទ្រវរ្ម័នជាព្រះរាជាមានអាគតដ្ឋានមកពីប្រទេសនគរភ្នំ បានពង្រីកអាណាចក្រឲ្យធំទូលាយទៅទៀតគឺវាយយកភូមិភាគខាងត្បូងខ្ពង់រាបនគររាជ (នគររាជសីមា ប្រទេសសៀមសព្វថ្ងៃនេះ) ព្រមទាំងទីទំនាបភាគកណ្តាលនៃទន្លេមេគង្គរហូតទៅដល់ស្ទឹងព្រៃមូល (សៀមថាណាំមូន) ស្រេចហើយទ្រង់ត្រឡប់មកវាយយកប្រទេសនគរភ្នំវិញ ។ កាលនោះ ព្រះរាជានគរភ្នំព្រមទាំងរាជបរិពារស្តេចថយចេញពីក្រុងវ្យាធបុរៈ (បាភ្នំ) ទៅគង់នៅនរវរនគរ (ចិនថា ណាហ្វូ-ណា) គឺអង្គរបូរីសព្វថ្ងៃនេះ ។ ព្រះបាទភវវរ្ម័នវាយដណ្តើមយកប្រទេសនគរភ្នំក្នុងគ្រានេះ ពុំទាន់បានសម្រេចដូចព្រះរាជបំណងព្រះអង្គទេ មកដល់រាជ្យព្រះបាទឦសានវរ្ម័ន ជាព្រះរាជបុត្រនៃព្រះបាទចិត្រសេនាមហេន្ទ្រវរ្ម័ន ទើបសម្រេច ។ ព្រះបាទឦសានវរ្ម័នស្តេចគង់នៅក្រុងឦសានបុរៈ (នៅជិតស្រុកអម្ពិលរលំ ចំនួន ៣០ គ.ម. ខាងទិសពាយ័ព្យក្រុងកំពង់ធំ) ជារាជធានីនៃព្រះអតីតរាជានោះ ហើយតមកទើបស្តេច

មកតាំងរាជធានីថ្មី នៅឦសានបុរៈ (សម្បូណ៌ព្រៃគុក ចម្ងាយចំនួនជា ៤០ គ.ម. ទៅខាងកើតក្រុងកវបុរៈ) ។

២ - រឿង "ចេនឡា" ក្នុងនិពន្ធចិន ។ រឿងនេះអ្នកប្រាជ្ញខាងបុរាណវិទ្យា គេតក្កិរឿងឆ្ងល់ហើយបានរកមូលហេតុរឿងនេះមកយូរ ហើយឆ្ងល់ថា ចេនឡាជាពាក្យខ្មែរចិនត្រាប់តាមមិនច្បាស់ ឬមួយជាពាក្យចិន លុះមកដល់ឥឡូវនេះនៅតែមិនទាន់បានលទ្ធផលប្រពៃឡើយ បើពាក្យនេះជាពាក្យខ្មែរ ចិនត្រាប់តាមមិនច្បាស់ តើចិនចង់ត្រាប់ពាក្យខ្មែរថាម៉េច ? ចំនងជាថាត្រាប់តាមពាក្យខ្មែរ តែយើងរកមិនទាន់ឃើញ ដូចជាពាក្យថាកម្ពុជានេះក៏អាចនឹងក្លាយទៅជាចេនឡាបានដែរ ចំនងដូចពាក្យហ្វូណន (Fou-nan) ជាពាក្យខ្មែរ ចិនត្រាប់ពាក្យខ្មែរថា "ភ្នំ" មិនច្បាស់ត្រឡប់ជាថាហ្វូណនវិញ ព្រោះមានសិលាចារឹកខ្មែរបុរាណបញ្ជាក់ថាក្រុងភ្នំ ឬក្រុងភ្នំ ជាសំស្រ្កឹតបវ៌តភូបាល "ស្ដេចភ្នំ" ។ ការរកពាក្យចេនឡា ថាជាពាក្យផងខ្មែរឬថាជាពាក្យផងចិន នៅមិនទាន់ជ្រះស្រឡះ តែលោកបានរកឃើញទីក្រុងដែលឈ្មោះថាចេនឡា ។ អ្នកប្រាជ្ញបុរាណវិទ្យារកឃើញហើយឆ្លើយថាទីបរិវេណក្រុងចម្ប៉ាសក្ដិ និងប្រាសាទបុរាណវត្តភូ (ប្រទេសលាវភាគក្រោម) នៅជើងភ្នំមួយដ៏មានកំពូលទ្រមួយដុំធំកាងទៅដូចគិរលិង្គ ដែលមានសិលាចារឹកច្រើនកន្លែងចារទុកថា "លិង្គបវ៌ត" និពន្ធថា លិង-កៀប៉ូ-ប៉ូ (Lin-Kia po-po) នៅលើលិង្គបវ៌តនេះ មានប្រាសាទមួយ

កម្ពុជតំលៃលិង្គនាមថា "កម្រេតុរ:,, និពន្ធចិនថាប៉ូ-តូ-លិ (Po-to-li) ហើយ ដែលសិលាចារឹកខ្មែរបុរាណសម័យនគរឲ្យនាមាភិធេយ្យថាកម្ពុជទេស: "ប្រទេសនៃព្រះរាជបុត្រនៃវង្សក្រិកម្ពុ,, នេះហើយជាមជ្ឈមណ្ឌលបុរាណនៃប្រទេសដែលនិពន្ធចិនហៅថា "ចេនឡា ,, ។

៣– ក្នុងការពិចារណាសិលាចារឹកវត្តល្អងកៅ លោកសឺដេសសរសេរថា "ទីបរិវេណចម្ប្រាសក្តិនេះហើយដែលចប់មក្សត្រនៃកម្ពុជ: មានព្រះបាទស្រុតវរ្ម័នទិងព្រះបាទស្រេស្ឋវរ្ម័នជាដើម (ខាងសូរ្យវង្ស) សោយរាជ្យក្រោមអធិរាជភាពនៃប្រទេសនគរភ្នំ នៅក្នុងកំឡុងគ្រិស្តសតវត្សទី ៦ មានព្រះរាជធីតាមួយព្រះអង្គក្នុងវង្សនេះ (វង្សក្រិកម្ពុ ឬ ខាងសូរ្យវង្ស) នាមក្រិកម្ពុរាជលក្ស្មី បានទៅជាទេពីនៃព្រះរាជកុមារមួយអង្គ ត្រូវជាព្រះរាជនត្តានៃព្រះបាទរុទ្រវរ្ម័ន (ខាងសោមវង្ស) ដែលជាអវសានរាជាក្នុងមហាប្រទេសនគរភ្នំ ។ អាស្រ័យដោយការសម្ពន្ធព្រះរាជវង្សទាំងពីរដូចពោលមកនេះ ព្រះរាជកុមារ ដែលមានអាគតដ្ឋានមកពីប្រទេសនគរភ្នំ (ខាងសោមវង្ស) បានឡើងសោយរាជ្យជាព្រះនរបតីជាធំលើវង្សក្រិកម្ពុ(ខាងសូរ្យវង្ស)ឡើង ព្រះនាមថា ភវវរ្ម័ន ។ ក្នុងកាលគមកព្រះបាទភវវរ្ម័ន មានព្រះអនុជព្រះនាមចិត្រសេនា (មហេន្ទ្រវរ្ម័ន) ជាសេនាបតីជំនាញខាងយុទ្ធវិធី លើកសេហ៍ពលទៅវាយ យកប្រទេសនគរភ្នំដូចបានពោលមកហើយខាងលើ ។ មូលហេតុដូចម្តេច

បានជាទ្រង់ទៅវាយយកនគរភ្នំ ? ឯកសារផ្សេងៗ (និពន្ធបទនិងសិលា-ចារឹក ) បានឲ្យយើងដឹងថាព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន ប្រហែលជាទ្រង់មានព្រះរាជបុត្រ ២ ព្រះអង្គ មួយអង្គព្រះនាមគុណវរ្ម័ន ជាមកុដរាជកុមារព្រោះជាព្រះរាជបុត្រព្រះអគ្គមហេសីព្រះនាមមកុលប្រភាវតី (សិលាចារឹក-ដំបង់ដែក, ខេត្តតាកែវ) មួយព្រះអង្គទៀតព្រះនាមរុទ្រវរ្ម័ន ជាព្រះរាជបុត្រព្រះស្នំ កាលព្រះវររាជបិតាទិវង្គត គ.ស ៥១៤ ព្រះរាជកុមាររុទ្រវរ្ម័នទំនងជាធ្វើគតព្រះរាជកុមារគុណវរ្ម័នដែលជាព្រះរាជបុត្រធម្មានុរូប ហើយឡើងសោយរាជ្យ ទ្រង់ព្រះនាមរុទ្រវរ្ម័ន (សិលាចារឹកខទេព្យាទី) ក្នុងខណៈដែលព្រះបាទរុទ្រវរ្ម័នទិវង្គត (ឬមានការធ្វើគត) ទំនងជាព្រះវង្ស ខាងព្រះគុណវរ្ម័ន កាន់ព្រះពុទ្ធសាសនាមុតមាំដែងរាជ្យតសន្តតិវង្ស បានជាខណៈនោះព្រះបាទភវវរ្ម័ន កាន់សាសនាព្រាហ្មណ៍និកាយព្រះឥសូរ មុតមាំដែលជាព្រះរាជបុត្រព្រះវីរវរ្ម័ន ហើយត្រូវជាព្រះរាជនត្តា ព្រះបាទរុទ្រវរ្ម័នផងយកឱកាសនេះលើកទ័ពមកវាយដណ្ដើមសោយរាជ្យវិញ ។

សិលាចារឹកវត្តលង់កៅនេះ ជាថ្មមួយដុំបួនជ្រុងជាភាសាសំស្ក្រឹតគ្រប់ទាំងបួន អក្សរជំនាន់មុនរាជ្យព្រះបាទភវវរ្ម័ន ។ លក្ខណៈអក្សរមានទំនងដូចសិលាចារឹកព្រះរាជកុមារគុណវរ្ម័ន នៅប្រាសាទ ៥ ល្វែង ស្រុកទឹកថ្លា (វៀតណាមខាងត្បូង) ហើយរាប់បញ្ចូលទៅក្រុម អក្សរសម័យ

បណ្តាប្រទេសឥណ្ឌាទក្ខិណាបថគ្រិស្តសតវត្សទី ៥ មិនមែនក្រោយកាលបរិច្ឆេទនេះទេ ។

ប្រធានសព្វក្នុងសិលាចារឹក គឺព្រះបាទទេវានីកៈ (ទេវ ទេពតា ឬទិព្វ + អានីកៈ សេនា ឬស្នើ សេនាទេពតាឬស្នើទិ ) ជាមហារាជាធិរាជសោយរាជ្យក្នុងទីឋាននេះ ។ ដូច្នេះ កើតជាប្រស្នាទៀតថា ព្រះរាជាអង្គនេះជាវង្សណា ? នាមថា ទេវានីកៈនេះ មាននៅតែក្នុងគម្ពីរបុរាណៈ ជាបុព្វបុរសព្រះរាមនៅប្រទេសឥណ្ឌា មិនដែលឃើញមាននៅក្នុងវង្សណាមួយក្នុងសុវណ្ណភូមិនេះទេ ។ កាលដើមអ្នកប្រាជ្ញទុកដាក់ថា ព្រះរាជាអង្គនេះជាវង្សកម្ពុជៈ គឺវង្សកម្ពុមេរាដែលមានព្រះបាទស្រុតវរ្ម័ន និងស្រេឞ្ឋវរ្ម័នជាមូល ដោយហេតុថា សិលាចារឹកនេះនៅក្នុងបរិវេណជាមជ្ឈមណ្ឌលចេនឡា ។ ហើយគំនិតដែលផុសហុចមកមុនដំបូងនាំឲ្យយល់ថា ក្សត្រកម្ពុជៈដូច្នេះឯង តែសេចក្តីនៅក្នុងផ្ទៃសិលាចារឹកនាំឲ្យឃ្លាតចេញពីសម្មតិកម្មដើមទៅ ហើយនាំឲ្យយល់ថាជាក្សត្រប្រទេសចម្ប៉ាវិញ តែកិច្ចការទាំងនេះសុទ្ធតែនៅក្នុងសម្មតិកម្មទាំងអស់ យើងទុកឲ្យអ្នកប្រាជ្ញប្រវត្តិសាស្ត្រពិចារណារកសេចក្តីពិតទៅអនាគតចុះ ចំណែកយើងយើងត្រូវមើលចំពោះតែវប្បធម៌សំស្រ្កឹត ព្រោះសិលាចារឹកនេះ ជារបស់បុរាណចាស់មួយ ជាវប្បធម៌សំស្រ្កឹតសហកាលក្នុងនឹងប្រទេសនគរភ្នំ តែមានរបៀបផ្សេងពីគ្នាស្រឡះ ។ សិលាចារឹកនេះមិនឃើញមានឈ្មោះគរ-

និពន្ធទេ មុខគួរឲ្យស្តាយណាស់ ។

អត្ថបទសិលាចារឹកមួយបន្ទាត់ដើមក្នុងភាគទីមួយ កវីនិពន្ធតែងជាគាថាស្រគ្ធរា សេចក្ដីដូចជាមិនមែនជាបទស្តុតិសុទ្ធទេ គ្រាន់តែជាសេចក្ដីប្រកាស ពីកុសលវិធីតាមទំនៀមសាសនាព្រាហ្មណ៍បំពោះត្រៃទេពត្រិមូតិ ដូចមានពាក្យថា « ទ្រង់បានបំពេញកុសលវិធីចំពោះព្រះព្រហ្ម ព្រះឧបេន្ទ្រ (វិស្ណុ) ព្រះត្រៀគួរ (ព្រះឥសូរ) ដោយឲ្យកាៗផ្សេងគ្នា ទាំង ៣ ព្រះអង្គទេះនាំផ្ទៃក្រោមឲ្យចម្រើន កើតបានទៅជាមាយាមួយពាន់ ប្ដូរនាំផ្ទៃក្រោមនេះឲ្យលាញទៅវិញ ព្រមទាំងចម្លងសត្វនិករដែលលិចលង់ក្នុងសមុទ្រសាគរ ឲ្យឆ្លងផុតទៅដល់ត្រើយនាយពោលគឺទីបំផុតទុក្ខ " ។

បន្ទាត់ទី ៩ ក្នុងភាគទីមួយដដែលជាពាក្យរាយជាប់សេចក្ដីគារវហូតដល់បន្ទាត់ទី ១០ នៃភាគទីពីរ កវីនិពន្ធថ្លែងពីព្រះបាទទេវានិក:រីករាយព្រះទ័យចំពោះព្រះអាទិទេពដែលបានប្រោសប្រាណព្រះអង្គ ដែលមកពីប្រទេសឆ្ងាយថាបានតម្កល់ព្រះអង្គនៅក្នុងព្រះរាជានុភាព ដោយបារមីទេពតានៅលិង្គបតិតដូចសេចក្ដីថា "ព្រះរាជាជាព្រះមហារាជាធិរាជមានសិរី ព្រះនាមព្រះបាទទេវានិក: ទ្រង់រីកើបព្រះទ័យចំពោះសេចក្ដីអនុគ្រោះនៃព្រះអាទិ-ទេព គឺបិតាមហា (ព្រះព្រហ្ម) នារាយណ: (ព្រះវិស្ណុ) គង្ករ (ព្រះឥសូរ) ទ្រង់ប្រកបដោយមេត្តាធម៌ និងកុសលធម៌ដ៏ច្រើន ដែលកើតចេញមកពី

កុសលក្នុងអតីតជាតិទ្រង់តាំងនៅក្នុងធម៌ ប្រាជ្ញដូចជាព្រះបាទយុធិស្ឋិរៈ(១) ទ្រង់ជាទីពឹងនាក់ប្រជាជន ប្រាកដដូចជាព្រះឥន្ទ្រាធិរាជ ទ្រង់មានជ័យឈ្នះមារសត្រូវ ប្រាកដដូចជាព្រះបាទធនញ្ជ័យ (អជ៌ុន) ទ្រង់ធ្វើពិធីយជ្ញៈច្រើនប្រាកដដូចជាព្រះបាទឥន្ទ្រទ្យុម្ន(២) ទ្រង់បំពេញទានទឹងមហាទាន ប្រាកដដូចព្រះបាទឝិពិ(៣) ទ្រង់បានបំពេញភាគព្រះអង្គជាព្រាហ្មណ៍ ប្រាកដដូចព្រះភគាំទមហាបុរុ(៤) ទ្រង់ក្សាន្តវិទ្យាយ ប្រាកដដូចជាព្រះកនកបាណ្ឌុ(៥) ទ្រង់មានព្រះប្រាជ្ញាជ្រាលជ្រៅដូចមហាសមុទ្រ ទ្រង់មានព្រះទ័យនឹងធឹងដូចភ្នំព្រះសុមេរុ ទ្រង់ស្ដេចមកពីប្រទេសឆ្ងាយ ហើយតាំងនៅលើលិង្គបពិតដ៏មានបុណ្យដែលជនគោរពតាំងពីបុរាណកាល ទ្រង់មានព្រះបរមនាមប្រកបដោយព្យញ្ជនៈបួន ទេ · វា · នី · កៈ ទ្រង់មានជ័យច្រើនគ្រា ប្រាកដដូចព្រះវិជ័យ (អជ៌ុន) ទ្រង់បានចម្លងសត្វនិករឡើងផុតពីមហាសាគរឥតត្រើយគឺសង្សារ ដោយការបូជាព្រះអគ្គីដ៏ប្រសើរ និងដោយការព្រះរាជទានគោច្រើនពាន់ជាទាន ។

បន្ទាត់ទី ១១ ក្នុងភាគទីពីរឡើងដល់បន្ទាត់ទី ១៣ នៃភាគទីបួន ជា

---

១- ស្ដេចក្រោកបដោយធម៌ ជាអធិបតីលើក្សត្របាណ្ឌវៈ ក្នុងរឿងមហាភារត ។ ២- ព្រះរាជាច្រើនព្រះអង្គក្នុងរឿងព្រេង ។ ៣- ព្រះរាជាល្បីព្រះនាមថាមានមេត្តា គ្មានព្រះរាជាអង្គណាស្មើបាន ជាព្រះរាជបុត្រព្រះបាទឧសិនរ និងព្រះនាងមាធវី ក្នុងរឿងមហាភារតៈ និងជាតក ។ ៤- ព្រះនាមព្រះរាជា ព្រះមហាមុនីច្រើនអង្គនៅអតីតកាល ។ ៥- ព្រះនាមនេះ អក្សរក្នុងសិលាចារឹកមើលមិនច្បាស់ [illegible] ។

បទ ២១ ស្លោក  កវីនិពន្ធបង់ជាស្លោករៀបរាប់ពីកិច្ចការកុសល ខាងដើម រលុបរលាយអក្សរអស់ច្រើន ខាងចុងនៅសល់ខ្លះ ថ្លែងពីទ្រង់បានសាងកំពង់បុណ្យធំ (មហាតីថៈ) បានធ្វើពិធីស្នាន: (ពិធីមុជទឹក - ស្រោចទឹក) សំរាប់លាងបាបឲ្យបានចំរុងចំរើន ទីឋាននេះ តាំងឲ្យឈ្មោះថាកុរុក្សេត្រ: សម្រាប់បង្ហោះបុណ្យដល់ជនណា ដែលបានចូលទៅដល់ឲ្យប្រាកដ ដូចជាបានចូលទៅដល់កុរុក្សេត្រ:នៅប្រទេសឥណ្ឌា ដូចសេចក្ដីតទៅនេះ «ជននៅក្នុងមហាតីថៈ (កំពង់បុណ្យធំ) ដែលត្រូវតែស្នាប់ហើយបានធ្វើពិធីស្នាន: សូមឲ្យបានសម្រេចផល - សូមឲ្យបានសម្រេចផលប្រាកដដូចបានធ្វើនាប្រកាសតីថៈ (១) ទេវតាទាំងឡាយមានព្រះព្រហ្មព្រះឧបេន្ទ្រ (ព្រះវិស្ណុ) ព្រះឦស្វរ (ព្រះឥសូរ) ជាដើម ដែលបានទទួលយកយជ្ញ:នេះ សូមចំណាំឈ្មោះអ្នកបូជាកុំខាន - សូមអធិដ្ឋានទីនេះឲ្យឈ្មោះថាកុរុក្សេត្រ:(២) ប្រាកដដូចប្រទេសឥណ្ឌា—សូមសម្រេចផលក្នុងកុរុក្សេត្រ:នេះឲ្យដូចជាបានសម្រេចផលទិព្វនៅកុរុក្សេត្រ:ពីបុរាណ - ឬសីនាមកុរុតីបុរាណ បានបង្កើតបាននបណ្ដុះ ធម៌សម្រាប់ជនសប្បុរស ដូច្នេះមហាតីថ:ថ្មីនេះ អាចឲ្យបានផលច្រើន ហេតុនេះហើយ ទានជាឋាននេះ ហោ

---

១- ឈ្មោះទីឋានល្បីមួយនៅជ្រោះ គង្គា ប្រទេសឥណ្ឌា ។ ២- កុរុក្សេត្រនេះ លោកទុកជាឋានបណ្ដុះធម៌ ព្រោះលោកថា ធម៌នឹងអធម៌ (ចម្បាំងមហាភារត:) កើតនៅកុរុក្សេត្រនេះ ទីបំផុតធម៌ឈ្នះអធម៌ឃុំនឹងគួរកត់សំគាល់ថា បុរាណលោកចង់ឲ្យប្រទេសខ្មែរដូចប្រទេសឥណ្ឌា ឬដូចម្ដេច ? ។

ជាកុរុក្សេត្រៈ — សូមព្រះវសុ ហៅឈ្មោះអ្នកដែលគាត់ធ្វើអំពើអាក្រក់ក្នុងកុរុក្សេត្រៈនេះ ហើយប្រទានឲ្យបានគតិប្រសើរ — សូមឲ្យខ្ញុំបានទៅកាន់កុរុក្សេត្រៈ ហើយឲ្យបានទៅក្នុងកុរុក្សេត្រៈ ព្រោះអ្នកណាទៅក្នុងកុរុក្សេត្រៈ អ្នកនោះបានទៅកាន់ឋានសួគ៌ — ព្រៃនៃមិគ (ព្រៃមួយនៅជិតស្ទឹងគោមតី ឥណ្ឌា) ជាឋានបណ្ដុះបុណ្យមួយនៅលើផែនដីឯឋានបុស្ករៈ (បឹងមួយនៅ អជ្មេរ ឥណ្ឌា) ទុកជាឋានបណ្ដុះបុណ្យនៅឋានសួគ៌ កុរុក្សេត្រនេះជាឋានបណ្ដុះបុណ្យប្រសើរ សម្រាប់ជនទិនក្សេត្រគ្រាន់តែពុកិត្តិនាម ម្ដេចបានអានិសង្សដល់ទៅប្រាំពីរជួរត្រកូលទៅ ហើយចាំបាច់និយាយថ្វីដល់ជនដែលបានទៅកាន់ទីនេះដោយការពេះពឹងព្រះធម៌? — ជនដែលធ្វើអគ្គិមធៈ (បូជាសេះ) រាជបេយ (ឈ្មោះពិធីបុណ្យ) មួយរយ និងការឲ្យគោមួយពាន់ជាទានក្នុងទីឋាននេះដោយប្រពៃ មិនមែនឈ្មោះថាជាហេតុនៃផលទេ បើជនណាបានធ្វើពិស្នានៈនៅក្នុងកុរុក្សេត្រៈនេះ ជននោះទើបឈ្មោះថាបានផលដ៏ទៀងទាត់មែន — សូមជនទាំងឡាយនៅក្នុងកុរុក្សេត្រៈនេះបានសម្រេចផល ដូចព្រះសុគមិទាំងឡាយបានពោលហើយពីអតីតកាល — សូមផលដែលកើតពីពិធីៈមួយពាន់នៅក្នុងកុរុក្សេត្រៈនេះ បានសម្រេចដល់ជនទាំងឡាយដោយប្រពៃកុំខាន — ជនអ្នកមានបាប គ្រាន់តែបានចូលទៅកាន់មហាតីថៈនេះគាពនោះរួចបាបបាន ចាំបាច់និយាយថ្វីដល់ទៅជនដែលត្រេកអរបំពោះធម៌? ។

បីបន្ទាត់ចុងបំផុតនៃការទីបួនជាគាថាមាលិនី កវីថ្លែងស្តុតិចំពោះព្រះបាទទេវានីក: ជាទ្រង់ជាអ្នកបង្កើតកំពង់បុណ្យធំមួយនៅលើផែនដីនេះដូចតទៅនេះ "ព្រះមហារាជាធិរាជ មានព្រះសព្វាង្គកាយស្រោចស្រប់ហើយៈដោយភាពក្តៅផ្តុកពោលគឺកុសល មានព្រះពលយសកើតចេញពីព្រះហស្ត មានព្រះឧត្តមាង្គដ៏ប្រសើរប្រដាប់ដោយកម្រងផ្កា មានព្រះសុគន្ធពោលគឺមហាគ្រីដែរកបាទៈដោយកម្ម មានព្រះនាមាភិធេយ្យថាទេវានីក: បានបង្កើតកំពង់បុណ្យប្រសើរដ៏លើសមួយនៅផែនដីនេះ" ។

យើងបានមើលតាំងពីដើមដល់ចប់ហើយប្រាកដថា ព្រះបាទទេវានីក:ជាប្រធានសក្កសិលាចារឹកនេះ ទ្រង់ជាមាមក:សាសនាព្រាហ្មណ៍និកាយព្រះក្រឹស្ណ ដែលជាអវតារព្រះវិស្ណុក្នុងរឿងមហាភារត: ព្រោះទ្រង់បានបង្កើតកំពង់បុណ្យធំ (មហាតីថ:) ឲ្យនាមជាកុរុក្សេត្រ: នៅប្រទេសយើងពីបុរាណកាល ។ កវីអ្នកនិពន្ធកាព្យនេះក៏កាន់សាសនាព្រាហ្មណ៍ម៉ឺងម៉ាត់ មានការចេះដឹងសាសនាព្រាហ្មណ៍យ៉ាងទូលាយ ចេះតែងកាព្យបំពេញព្រះរាជប្រាថ្នាឲ្យសមតាមរាជបំណងឥតខ្ចោះ សម្តែងឲ្យឃើញថាកវីនេះមានស្នាដៃប្រសើរជាអ្នកដ៏ឯកមួយក្នុងកាលនោះ មានទឹកប៉ាក់កាមិនចាញ់ប្រៀបសិលាចារឹកទន្លេបាទីដែលជាសហកាលិកខ្លួនទេ ថ្វីត្បិតតែសិលាចារឹកទន្លេបាទីជាពុទ្ធសាសនា មួយខាងទន្លេក្តីជាពុទ្ធសាសនា មួយខាងទៀតជាសាសនាព្រាហ្មណ៍ ។ កវីនេះ ចេះតែងពាក្យ

ជាស្រឡួច ជាពាក្យពាយ ជាស្មោះ ជាទាល់ទី បញ្ជាក់ឲ្យឃើញច្បាស់ ថា លោកជាអ្នកប្រាជ្ញមានការចេះដឹងសំស្រ្កឹត ធម៌សាថិកាព្យ ជាន់ខ្ពស់ មួយរូប តែយើងស្តាយណាស់ ព្រោះមិនបានស្គាល់នាមលោក ។

ទីបំផុត ខ្ញុំនឹកថា យើងធ្លាប់តែក្រេបរសជាតិធម៌សាថិនឹងពាក្យពេចន៍ខាងពុទ្ធសាសនា ពេលនេះ យើងភ្លក់រសជាតិសាសនាព្រាហ្មណ៍ ទំនងជាប្រផាមមាត់សល់លោកទេដឹង ? មិនអីទេ យើងខំពិនិត្យពិចារណាមើលទៅចុះ ព្រោះធម៌សាថិក្នុងសាសនាព្រាហ្មណ៍ជាពន្លឺមួយដ៏សំខាន់ដល់យើងជាអ្នកកាន់ពុទ្ធសាសនាដែរ តែយើងមិនត្រូវក្រួបនាទីយើងថា យើងមើលតែរៀបធម៌សំស្រ្កឹត " ។ល ។

## អក្ខបទសិលាចារឹកវត្តល្អងគៅ

ព្រាស់ មាឃោសហស្រកញ្ញគតិទយចល់ ឃ្លៃស្រួតិនៃ្កការលេ
គប្ចត្យ្រ្ទិ ទិមគ្គ ការសលិលលិយោ ការយន្តិ ស្ត យេ ប
ព្រហ្មបេទ្រ្ទិគ្គពណ៌ សនិទិលមន្ទុធំ សត្ថភាពញ្ញ គេហមាធន ឬប្ញ
ខរុទ្ធៈ កុនសលវៃធីមំ យត្តកាក - ហេតុៈ ॥

ន់តៀរាយ៉ ត្រីតន្ត្រទោពាយណប់តាម ហោទិសវ៉ៃខាវប្រសាតាគិបក្តៈ

បូវេនិទាផ្ជិតគុកកុគសលទិមិត្តសម្មាវិតស្វិកម្មាតិមានុបកម្មោ យុធិដ្ឋេរ ឥវ-សទ្ធម្មិស្មិតោ [វិវុ] ធនរាតិវេ ប្រផៈបាលនេ ធនញ្ញយ ឥវ វិបុ-គណវិជយេ ឥន្ទ្រទ្យុម្ន ឥវ កុវិយដ្ឋវិធានេ គិរិវេ ទានេ មហាយនេ ភគភ់ន្ទហាបុរេ ព្រហ្មណ្យតានុបាវេ ព្រាហ្មណ្យភាវេ កនកបាណ្ឌ្យ ឥវ ទព្វាយរក្សណេ មហោទធិវេ គាម្ភីរយេ មេរុវ ស្ថៃយ្យេ បូវិមតេន ភគវតា គ្រឹលិង្គបរិតេនាសិទ្ធរទេគាទានីតាធិដ្ឋតោ មហាធិកវៃជ្រគ្គយេ វិតិបវិស្សប្បាប្បាទិក្ខរមង្គលនាមធេយោ ទុំបទនេកា-ទីតាភ់បុវិជយោ វិជយ ឥវ មហាកដាធិកដគ្រុមាញ្ញាទោវទីកៈអបារ-សំសារសាគកត្តរណាយ សវិសត្តានុទ្ទិត្យ មហាគិមខបុរេកម៌ សានេ-កគោសហស្រ ‖

យេ វសន្តិ មហាតីតេ គត្រ ច យេ មុត្តា ឧក:
ស្ថវិទិ យេ ច កុវិទ្ធិ តត្តលំ ប្រាប្នុវន្តុ តេ ‖
ឥគេ្យវមាទិប្រណីធិ- រាជគិនយតស្តុទ!
នាមតតំ កុរុគេរ្យគ្រ . . . . ប្យផលៃស្យមេម ‖
តវគ្រេភប កុរុគេរ្យគ្រេ រាស្មុទា សមុទិតា:
មហាទុស្តតកម្មាណំ នយន្តិ បរមាំ គតិម៑ ‖
កុរុគេរ្យគ្រគ្គិមិស្យាមិ កុរុគេរ្យគ្រេ វសាម្យហម៑

យេ វសន្តិ កុរុក្សេត្រេ តេ វសន្តិ ត្រិវិឞ្ដបេ ‖

តន្នាមកីត៌្តនេនាបិ តេន ហ្យ សប្តមំ កុលម៑

កិម្បុនយ៌េ តុ សេវន្តេ មនុជា ធម៌្មពុទ្ធយះ ‖

អឝ្វមេធសហស្រស្យ វាជបេយឝតស្យ ច

គវាំ ឝតសហស្រស្យ សម្យគ្ទត្តស្យ យត្ផលម៑ ‖

តត្ផលំ តុ កុរុក្សេត្រេ កុវ៌ន្តិ ស្នេនាទី ច

តត្រាប្យហេតុ ទុះប្រាបំ លភន្តេ តេ ធ្រុវំ ផលម៑ ‖

កុឝលផលជាតជាតសវ៌ង្គទេឝស៑

ស្វកុជពលធាឝស្រស្យគ្គាមបារ្តមាង្គះ

ទុរធិគតមហាគ្រីគន្ធកស្តិ៍តមគ្រ្យម៑

ជនយតិ កុវ៌ ទេវាទីក ឥត្យាប្តនាមា ‖

# សប្បុរិសធម៌ពាក្យកាព្យ

ពាក្យកាព្យនេះ កម្មវិធីសិក្សានៅមធ្យមភូមិ បានជ្រើសរើសយកសម្រាប់ សិស្សថ្នាក់ទី ៤ ទំនើប ដូច្នេះហើយបានជាយើងសូមស្រង់ យកបោះផ្សាយក្នុងទីនេះ ។

## អារម្ភកថា

រឿងសប្បុរិសធម៌នេះ ខ្ញុំបាទមានមនោគតិគិត ផ្តើមឡើងដោយឃើញថា ជាឧបការគុណដ៏ឧត្តម សម្រាប់ពុទ្ធបរិសទ្យដែលត្រូវការ ។

ប៉ុន្តែធម៌នេះ ចំពួកប្រាជ្ញជាន់ខ្ពស់ លោកបាន ប្រែពីបាលីធ្វើជា សេចក្តីអធិប្បាយ ជាធម្មទានក៏មាន តែនៅជាពាក្យសម្រាប់ចុះសៀវភៅ សម្រាប់ឲ្យមើលផ្ទាល់ក៏មាន នោះពុទ្ធបរិសទ្យទាំងឡាយសឹងបានជ្រាបខ្លះ ហើយ ។

ឥឡូវនេះ ខ្ញុំបាទតែងជាពាក្យកាព្យវិញដើម្បីជាការស្រួលសម្រាប់ ពុទ្ធបរិសទ្យចំពួកខ្លះ ដែលត្រូវការស្តាប់ពាក្យកាព្យ អាចឲ្យបំបាត់នូវ សេចក្តីធុញទ្រាន់ក្នុងការមើល ការស្តាប់បរិយាយពុទ្ធភាសិតនេះផង ។

អវសានវាទនេះ ខ្ញុំបាទសូមប្រណិប័តន៍ថា សប្បុរិសធម៌ ដែលខ្ញុំបាទ តែងនេះ ប្រហែលជាខាតខ្វះលើសលោះក្នុងបទណាមួយខ្លះ ។ ប៉ុន្តែខ្ញុំសង្ឃឹមថា មុខជានឹងទទួលសេចក្តីអភ័យអំពីពុទ្ធបរិសទ្យទាំង ឡាយពុំខាន ។

សាហាគ្គិតេរងាម

**ចាន-តេង**

# សប្បុរិសធម៌ពាក្យកាព្យ

## សូមពោលសូត្រពុទ្ធទាំងប្រោសទេមាន

ក្នុងបករណ៍អង្គុត្តរជាប្រធាន កែពាក្យអត្ថបដិភានវោហារ ។

នាមព្រះសូត្រសប្បុរិសធម្មោ គឺជាទាំងពុទ្ធវិចារណ៍ ប្រទានជា
ប្រយោជន៍យ៉ាងពិស្ដារ បរិហារសព្វសត្វឲ្យបានសុខ ។

មានចំនួនសត្តបទកំណត់ប្រាប់ បានសាស្ដាអធិប្បាយជា បែប
ទុក ឲ្យមនុស្សភ្ញាក់កំណើតដើតទៅមុខ ស្គាល់វិថីផ្លូវសុខសប្បុរស ។

និងសាធកលើករឿងឡើងជាភាគ សូមផ្ទៀងសោតប្រសាទស្ដាប់
ឲ្យអស់ ផ្ចង់សតិន្ទ្រិយ៍តាំងសោមនស្ស ខំលាស់ទោះចិត្តបាកកន្ធល់ ។

១– ធម្មញ្ញូ គឺដឹងកំណើតហេតុ គ្រប់ប្រភេទគឺហេតុបង្កើតផល
ទាំងផែនកពសព្វសត្វសេពឥតសល់ ដឹងមិនផល់ដោយខ្វាះដៅតែស្មាន ។
ហេតុនោះឬគឺកម្មដែលកសាង មានពីរយ៉ាងគួរយល់សម្ពុធាន កម្មភាពក្រក់
និងល្អប្រចាំប្រាណ ធ្វើប៉ុន្មានបានប៉ុណ្ណឹងកុំប្រឹងចូល ។ ចិត្តខិលខ្វួចផ្ដួច
ផ្ដើមថ្មើមថ្មោសកាច យ៉ាងនេះប្រាជ្ញប្រាប់ថាអកុសល អ្នកណាសាងអ្នក
នោះឯងសោយផល ជាប់សកលកាយវេទនដូចវេរកាន់ ។ ប្រព្រឹត្ត
ត្រឹមត្រង់ត្រូវផ្លូវសុចរិត នោះបណ្ឌិតហៅថាកុសលខន្ធ ត្រូវត្រង់គ្រាប់ត្រិះ
គិតឲ្យកើតធន្ន គង់ជួបសន្តិសុខសាធារ ។ យើងជាអ្នកស្វែងមគ្គឲ្យជាក់

ហេតុ មិនប្រកែកថាកម្មផលគឺខ្លួនវា ឥឡូវនេះលើកកម្មឡើងឧទាហរណ៍ ផ្ដើម
សន្ធរាងទៅតាមសំណាក់ ។ ស្ងួមការប្រើជាបេះបំណាន ជួយប្រោសប្រាណ
ពន្យល់ដល់ជនទៀត កុំធម្មកោគាតាមសំណាក់ ប្រោសប្រោសប្រោសខាត់
អាត្មាស្រ័យ ។

៤- កុសលអត្តតាភាជាធិផល គួរសំគាល់វាថាវិបច្ច័យ ព្រោះគួរហេតុ
ប្រភេទដើមនិស្ស័យ ជាបច្ច័យដូចឧសទិនអគ្គិ ។ ប្រៀបដូចធ្វើអំពើ
កម្មអាក្រក់ ផលខ្លួនល្អកក៏ដកកុសលឥន្ទ្រិយ អំពាលចិត្តឥតសុខទុក្ខពោរទ្រើ
គ្មានវិធីណាថយឲ្យស្រាកស្រាន្ត ។ បើធ្វើល្អផលល្អក៏ដូរកាយ ឲ្យ
សប្បាយសមបែបសេពសុខសាន្ត ក្រក់ខ្លាត់ខ្សត់ក៏ខ្លាយឆ្ងាយចាកប្រាណ
សុខសម្រាន្តរាល់ទិនមិនស្រាកស្រន់ ។ កាលសុខទុក្ខមកដល់ចូលប្រុង
ចិត្ត រំលឹកគិតរំពឹងដឹងឲ្យទាន់ ទាំងគេយើងក្នុងភពរាប់ម៉ឺនពាន់ ទុក្ខតែង
ជាន់សុខតាមជួយតែរាល់គ្នា ។ ត្រូវពិនិត្យសមុទ័យទោសទុច្ចរិត ដែល
បានបិទឥតក្ដិ គឺអវិជ្ជា បើជម្រះឲ្យជ្រះពីអគ្គា វេទនាគង់ស្ងប់រម្ងាប់កាយ ។
កាលចិត្តកាចកើតឡើងយើងលះចេញ ត្រូវបំពេញមេត្តាករុណាផ្សាយ
ទើបបានសេពសន្តិសុខសប្បាយ អន្ទ្រើនឆ្ងាយគេតោហៅផលល្អ ។ ស្គាល់
ធម៌ពីរនេះទេញជាស្គាល់ត្រូវ ព្រោះដងផ្លូវត្រូវកើតទ្រព្យរកក្រ ធម្មញ្ញូរដង
ជាដើម១ អត្ថញ្ញូ ហោកសង្គ្រុបថាចុង ។ ឯស្គាល់ដើមគឺស្គាល់ប្រធាន

ហេតុ កំណត់ខេត្តខណ្ឌគ្នាជាក្រៅក្នុង ការស្គាល់ផលត្រូវយល់ដល់ស្គាល់ចុង គតិក្នុងតួហេតុប្រភេទចាស់ ៗ

៣. ក្នុងអត្តញ្ញាណជាស្គាល់ខ្លួន ត្រូវបេះស្នួនស្ងប់ស្ងៀមចៀមកើតខាសប្រុងប្រយ័ត្នមារយាទជាតិពុទ្ធសាសន៍ មើលឲ្យច្បាស់ច្បាប់ធម៌ប្រដៅកាយ ៗ ឲ្យដឹងខ្លួនដោយជាតិត្រកូលកើត ពូជកំណើតក្រុងស្រែសែស្រឡាយ សម្បូណ៌ទ្រព្យសម្បត្តិឬខ្វះត់ចាយ កំណត់កាយឲ្យជាក់ជាធម្មតាៗ លុះកំណត់ដឹងជាតិដឹងកំណើត ដែលៈយើងកើតនៅក្នុងពូជពង្សណា ហើយដាក់ខ្លួនប្រាណប្រើកិរិយា ឲ្យសមតាមអត្តាជាការគួរ ៗ កុំធ្វើបែបខ្ពុកមាឌុចផ្អៀតព្រៃក វាកន្ទុកបួកចែវមិនត្រូវជួរ មួយគប្បីកំណត់ជាគួរ ឲ្យស្គាល់ខ្លួនក្បាលខ្លួនជាល្ងង់ខ្លាត ៗ បើដឹងខ្លួនថាខ្លួនជាមនុស្សល្ងង់ កុំទ្រនង់ទ្រទើសទ្រើសហួសខ្នាត លើផែនដីក្រអឺប្រាជ្ញឆ្លៀវឆ្លាត ត្រូវស្លូតយកជាគ្រូអាចារ្យ ៗ តែបន្ទំចិត្តខ្លួនខ្លាំងវាខ្លៅ អាចហ៊ានសៅស្ងួនឡសត្រូវទ្រព្យខ្ញុំសារ បើសម្បូណ៌សម្បត្តិយសបរិវារ កុំខុទ្យារិកព្រើលមើលងាយគេ ៗ បុកណាតោលថាបើឈើរលំ ដើរកន្ទុងតាំងគម្ពុំអំពេ បើមនុស្សជួលកុំអាលកន្ទុំងគេ ត្រូវគ្នាន់គោរមនុស្សដូចគ្នាដែរ ៗ បើយខ្លួនមិនទាន់បរិបូណ៌ច្រើន កុំព្រហើនហួសមាឌជាតិកូនខ្មែរ ចំណែកអ្នកអាយុច្រើនក៏ដែរ ត្រូវបង្វែសន្តានស្មានមើលមាឌ ៗ ឲ្យសមភូមិតាមភាពស្ថាបស្ថង់វ័យ ទើបប្រពៃពេញវង្សត្រកូលពង្សដ៏ជាតិ មាន

ចំណេះត្រូវចេះប្រើមារយាទ កុំឃ្លានឃ្លាតក្លាយទឹងស្រវឹងខ្លាំង ៗ គួរចម្រើនសីលធានទៀនអត្ថៈ ជាសារៈឧត្តមដល់រូបំ តែអត្តញ្ញាតាតាមអត្តំ ចប់ឯរំលោប់ស្ទះប៉ុណ្ណះចុះ ៗ

សរុបធម៌ជាសុភាសិត ប្រដៅចិត្តជនាទុជនៈនោះក្នុងទីបួនមានបទអត្ថសង្គ្រោះ លោកតាំងឈ្មោះហៅមត្តញ្ញុតា ៗ បានដល់ស្គាល់ប្រាកដបទសេចក្តី កិច្ចអ្វីៗឲ្យស្គាល់ប្រមាណថា ដូចការគេចិញ្ចឹមជីពរក្សា ការចេតនាធ្វើឲ្យមានគិឲ្យគួរ ៗ ស្វែងរកតាមបញ្ញាអាជីវ មិនលោភមោហហិនជាតិជួរ ឲ្យដឹងថាគួរបានឬមិនគួរ កុំសាញស្លួរធ្វេះបោកដោយទុច្ចរិត ៗ ជាតិមនុស្សលោភលោកលោភជញ្ជាបមាត់ ត្រូវតែភ្ញាក់ចូលក្លួតរកហេតុសិទ្ធ យកតែខាងបានទ្រព្យទើបគាប់ចិត្ត ទេះបណ្ឌិតបន្ទះជាខុសធម៌ ៗ របស់ដែលបានដោយផ្លូវអសត្យ គង់វិបត្តិកើតទុក្ខលំអក់ពណ៌ដល់ជីវិតជិតក្ស័យទើបភ័យញ័រ ទឹកដល់ធម៌មិនចាំកម្មពាក្រាស់ ៗ មួយគួរចេះប្រមាណមាត់បរិភោគ កុំកញ្ជ្រោកស៊ីជ្រុលពាល់ចាក់ច្រាស ល្មីងជាថ្នាំផ្អែមផ្អូមហើមពោះណាស់ ប្រាជ្ញប្រាប់ប្រកាសផ្លូវត្រូវប្រយ័ត្ន ៗ គួរជ្រើសរើសចំណីកុំទីខុស នូជារសពិសាភាពឈឺថ្កាត់ យ៉ាងផ្អកផ្អួរខ្លួរខ្ទោះពាសបញ្ញត្តិ ក្លក្បមួយមាត់ក្លាត់ខុសភាពុះផ្ទៃ ៗ មួយឲ្យចេះប្រយ័ត្នសម្បត្តិទ្រព្យ កុំទម្លាប់ចាយធំពុំប្រវៃ ប្រាកពប់សេនបែនបេមិនវែ គង់

មានភ័យដល់កាយស្លាយកម្លាំង ។ ឯការរកទ្រព្យធនជូនគំនិត ត្រូវព្រួយគិតប្រើកាយនឿយហត់ខ្លាំង ឃ្លាតប្រពន្ធឃ្លាតកូនខ្លួនស្គមស្គាំង សែងស្ពាយទាំងក្បាលហាលទាំងកាយ ។ មានស្រីខ្លះប្រុសខំរកគគ្រេង ខ្លួនល្អបលេងតែល្បែងតាមសប្បាយ គ្មានអាណិតគិតប្តីនឿយព្រួយកាយ តែប្រុសខ្លះផះចាយទ្រព្យដូចគ្នា ។ កាលបើមានឱកាសគួរល្មមទៅ ដើរសំដៅរកបនមិនរួញរា ចំពូកខ្លះស្រុះស្រួលបបួលគ្នា ព្រមទាំងបុត្រកិរិយាចរចូលវង់ ។ គួរសង្វេគពេកណាស់ទឹកឡើងហើយ មិនសមឡើយពួកយើងវង្វេងល្ងង់ ប្រឹងបង្ហិនធនធានគ្មានឲ្យគង់ ហាក់បម្រុងចង់តែឲ្យអស់ទៅ ។ ឈ្មោះថាទ្រព្យទ្រនាប់ដៃអ្នកចាយ ចិញ្ចឹមកាយកាលឃ្លានគ្មានខុសត្រូវ បើអ្នកមានគំនិតគិតកក់ជ្រៅ រើសតែផ្លូវឲ្យគុណចាយធនធាន ។ ដូចបញ្ចូនចូលហ៊ុនជួញលក់ដូរ គួរបង្វែរចាយចុះព្រោះចង់មាន បួនយ៉ាងនេះហៅចេះប្រើធនធាន បើសល់មានទៀតទុកបង្ការកាយ មួយឯស្រាអាកៀនញៀនបង្អៀរ គួរលះវៀរចំកៀសជៀសឲ្យឆ្ងាយ ទីងវិនាសសម្បត្តិទ្រព្យខ្ចាត់ខ្ចាយ ផ្លូវអបាយមុខទុក្ខអាត្មា ។ ទោះមានច្រើនបើកើនក្តួចលែលក ទ្រព្យដែលរកមកនោះគង់កាលណា ទ្រព្យមានតិចប្រមិចចាយហួសមាត្រា មិនប៉ុន្មានអាត្មាផ្សារប្រេងាង ។ សូមជាស់តឿនសតិជនប្រុសស្រី ដោយសេចក្តីសុចរិតឥតអួតអាង ពន្យល់ផ្លូវប៉ុណ្ណោះជាបែបយ៉ាង ទីងសូមអាងខ្ញុំតាមបរិយាយ ។ ខ្ញុំប្រាប់ថាកាល-

ញាតា ក្នុងអត្ថថាឲ្យស្គាល់កាលទាំងឡាយ មានសេចក្ដីរៀនកយទូលាយ ផ្ទាយ អធិប្បាយពីកាលយូរនិងឆាប់ ។ បើកាលមានអាសន្នបន្ទាន់បង់ កុំបង្អង់ឲ្យយូរគួរប្រញាប់ ទើបទាន់ចិត្តឥតទាស់ថ្ងស់ចំណាប់ បុកណាព្រាប់ ស្ទាប់បុះពីកេះពិត ។ ត្រូវថៃលកាលមុនក្រោយឲ្យជាក់ច្បាស់ កាលរហ័ស គួររហ័សឲ្យទាន់គិត បើកាលយូរគួរយូរផរគំនិត ចូរប្រព្រឹត្តឲ្យត្រូវផ្លូវ ប្រើការ ។ មានកាលិតប្រតិដ្ឋជាអដ្ឋ ថាកាលហានរូបជាខ្លឹមសារ អ្នក ហាត់ចិត្តគួរគិតគិតវិចារណា ស្ថានមើលការត្រូវតើងដឹងឲ្យទាន់ ។ ឯកិរិយា កាលនោះមាន៥ពីរយ៉ាង ជាតិកតាងតាំងទុកតាមលក្ខណ៍ គឺកាលចរកាល ប្រចាំបុរាណកាន់ ជាកំណាន់គ្រប់ទិសមិនខុសទេ ។ កាលប្រចាំចាត់ជា កាលរំលឹក គឺៈពេលព្រឹកថ្ងៃត្រង់សាយណ្ហ កន្សែងចេញទ្រាះនោះគឺវេ-លាចរវិញដេញផ្ទួសម័យ ។ កិច្ចណាគួរត្រូវធ្វើប្រចាំកាល ដូចចំអិន អាហារយើងអាស្រ័យ ត្រូវរកឿបស្រុកឲ្យទាន់ថ្ងៃ ចាត់សំងៃគោក្ខាតាម ការគួរ ។ លុះថ្ងៃតធ្លល់ស្កល់ស្កប់គិតកុំភ្លេច ត្រូវចាប់កិច្ចការធ្វើកុំខ្ជះខ្ជី បើហត់ពេកសំរាប់ឲ្យតែគួរ កុំផ្លាកផ្លេកភាក់ស្ងួតស្រមន់ខ្វង ។ លង់លុះទាល់ ដល់កាលពេលថ្ងៃត្រង់ សំមបង្អង់បង្អន់កិច្ចការផង រកអាហារបរិភោគ តាមបំណង បំបាត់ស្រេកឃ្លានផងផែលទៀយហត់ ។ ដល់បរិភោគ ស្រេចស្រាប់ចាប់ការធ្វើ ចូរទំរើល្បើល្បងប្រឹងរំណត់ យកកម្លាំង ច្បាំងការកុំគិតហត់ ស្ងួរទ្រាំរត់ដល់បច្ចុសម័យ ។ ហើយរួតទឹកងុស

កាយដែលស្មោគគ្រោក រូបរ៉ោគគោជនតាមវិស័យ យ៉ាងនេះហៅ
កិច្ចការប្រចាំថ្ងៃ ក្រៅពីនោះកែកៃជាការលេះ ៗ ដូចជាផ្ទះផ្លុកតែគ្រឿង
កខ្វក់ សម្រាមជក់គកគ្គាំងទាំងគំនរ គួរបោសប្រាសជុំសខាត់កុំទុកគរ
ប្រើមិនប្រើកែវរវល់រក ៗ ទ្រព្យមាសប្រាក់ទុកដាក់មានវត្ថុស្មើ ត្រូវការ
ប្រើមានព្រមតាមចិត្តភក្ត ណាមិនប្រើទើបតាំងដោយៈកៀនញក គន់មិន
ពាស់ខ្វះយើងរកយកបានងាយ ៗ ហើយមើលកាលហាត់កូនតាមក្បួន
ខាត ឲ្យធ្វើកោតកោងវៃមិនរៈយអៈយ ពន្យល់ផ្លូវត្រូវខុសឲ្យជ្រះព្រាយ ការ
វិនាសនិយាយឲ្យបួលចិត្ត ៗ ធម្មតាពត់ព្រឹក្សាលតៈរល្មើ ត្រូវពត់ពាល់
ពីខ្ចីទើបទន់ស្និទ្ធ ការហ្វឹកហាត់កូនះចាំឲ្យត្រូវចិត្ត គួរប្រៀនប្រដៅពីតូច
ទើបស្ទាត់ច្បាស់ ៗ ទីងបន្ទាយវែងទៅហួសផ្លូវកាព្យ នាំឲ្យសាបរេហារ
សាញខ្លាំងណាស់ បានលើកកាលទាំងពីរឡើងប្រកាស ឲ្យឃើញច្បាស់
ប៉ុណោះស្មេះនិពន្ធ ៗ

សូមតែតទប្រាំមួយដោយពាក្យថាបរិសុញ្ញតាអនុសន្ធិ ប្រែតាមយល់
ថាស្គាល់ប្រជុំជន គប្បីគន់គិតមើលឲ្យម៉ាំមួន ៗ មនុស្សល្អមែនគង់
មានអធ្យាស្រ័យ ក្នុងហឫទ័យរក្សាទុកជាក្បួន បួលត្រង់ណាបួលចុះបេះ
បៀមខ្លួន មិនឲ្យស្លូនស្លាក់ហួសជ្រុលសកាល ៗ ធម្មតាបង្កើតកំណើត
មនុស្ស មានជាន់ខ្ពស់ជាន់ទាបជាន់កណ្តាល មានទាំងប្រាជ្ញទាំងព្រើល
ទាំងខ្វះស្រោល ទាំងស្រួលចូលខ្លួនពេញឆាន់ ៗ មនុស្សគ្រប់ជាន់គួរ

សម្ពន្ធមេត្រីចិត្ត ចងជាមិត្តជាភក្តិសាមគ្គី តែឲ្យស្គាល់កិរិយាប្រពៃណី រើស
វិធីណាល្អប្រព្រឹត្តតាម ៗ មារយាទអធ្យាស្រ័យកាយវាចា គេគន់និយម
យ៉ាងណាក្នុងទីស្នាម ត្រូវសម្រួលផ្លូវដោយកុំឲ្យដាម ទើបសមតាមឋានៈ
ទុកដាក់អង្គ ៗ ទោះជាទាបក៏មិនភាបពីកំណើត ប្រើកិរិយាឲ្យទើតកុំបេះ
បង ត្រូវស្គាល់សព្វបញ្ញារឫស្សត្រង់ កណ្តាលវង្សចំណោមប្រជុំជន ៗ
សរម្ងប្រាប់សំរែកដូចក្អែកបួល មារយាទប្រាប់ត្រកូលចូលប្រើងគន់ អធ្យា
ស្រ័យសមគួរបុរសជន ផ្សាយចេញឯងឲ្យគន់ឃើញសទ្ធា ៗ ទោះរូប
គោមលោមពណ៌ល្អស្អាងស្អាត តែមារយាទខុសខ្នាតគេថាខ្មៅ ស្រឡាញ់
ខ្លួនស្ងួនកាយកុំឲ្យសៅ អាក្រក់ល្អក៏នៅតែលើខ្លួន ៗ ខ ប្រាំពីលក្បៀលខ្ចប់
បញ្ចប់ផ្តាច់ ព្រះសពេជ្រត្រាស់ទុកតាមចំនួន ប្រាសាទសុខារម្មណ៍ឲ្យ
មាំមួន កាលបើខ្លួនសេវនាសមាគម ៗ បទដើមគឺបុគ្គលញាតា មានអត្ថា-
ធិប្បាយដោយនិយម ប្រែថាស្គាល់ចរិតជនតូចធំ គួរសមាគមឬគេចមិន
សេពគប់ ៗ ឯមនុស្សនៅក្នុងក្រុងកម្ពុជខេត្ត មានប្រភេទពីរយ៉ាងការ
ប្រាជ្ញ គឺពាលកាចនឹងប្រាជ្ញប្រាប់ឲ្យគ្រប់ មិនទាន់គប់គាស់កាយផ្សាយ
ចេញឯង ៗ ឯសញ្ញាគឺជនពាលចណ្ឌាលទាប គ្មានសភាពរៀបរយគួរ
ឲ្យក្រែង មានវិស័យចិត្តសម័យជាអ្នកល្បែង ប្រើនសំដែងអាការកាច
គក់ម៉ក់ ៗ ជួរវិនាសរូបកាយអបាយមុខ ទទួលផ្ទុកគ្រប់យ៉ាងខាងអា
ក្រក់ កណ្តាគង្គាតបត់ករគរកុហក វៀចក្រង់កម្មុខងប់គ្រប់ប្រការ ៗ តែ

នៅស្ងៀមចិត្តអធិដ្ឋានបារមីយាងទៅជាគជយជាតិពូជពង្សវង្សាវតារ គួរតែជៀស
ជៀសកាយឆ្ងាយទុកចារ ហើយជាឧបការគុណដល់កាយ ។ ឯបណ្ឌិត
គ្រង់គិតមិនបេះខុស ជនស្រីប្រុសគ្រងគ្រាប់គង់សប្បាយ ទីងដុំឡើងកើត
ឈ្មោះខ្ពស់ផែនឆ្ងាយ បានសុខចិត្តសុខកាយគ្រប់ប្រការ ។ គោលគំល្អ
ធ្វើគំល្អិតគិតគំត្រូវ សំដៅផ្លូវសន្តិសុខសង្គ្រាម ពង់វិថីកាឡៃមិត្តាចារ សាង
តែការបុណ្យទានគានខោះខោរ ។ ត្រឹមប៉ុណ្ណោះណែនាំឲ្យឃើញហេតុ
គ្រៀងសកើតជាតិមនុស្សជាប្តី ក្នុងលោកនេះទឹកគប់គប្បីសួរ ឃើញ-
សមគួរល្អពិតសមគ្គិតអង្គ ។ ធម៌ខនេះជាច្បាប់សម្រាប់ប្រើ ឲ្យសប្បុរស-
រើសើរកផ្លូវត្រង់ ក្នុងវៀងសន្ធរមិត្តចិត្តចំណង់ ឲ្យផ្លូវផងយឺនយូរអង្វែង
គប្បី ។ បុគ្គលដែលគប់គប្បីមើលមុខចិត្ត ឲ្យឃើញពិតតាមក្ដីការប្រាប់
អាក្រក់ល្អសខ្មៅបានដាច់ មិនខុសច្បាប់បណ្ឌិតដូចសម្ដែង ។ ម៉ែ-
មនុស្សពាលតែពោលយល់ប្រកែក ឲ្យឃើញហេតុឧបាយដែលក្លាយក្លែង
គួរប្រាប់អត្ថសព្រះពុទ្ធថ្លែង កុំអែងសង្ស័យអាល័យធ្លាក់ ។ គប់ជនល្អ
ឥតល្អប្រសើរនេះ ពេចឲ្យកើតសុភមង្គលគិតទួផល គប់ជនអាក្រក់ចិត្តល្អក់
កន្ទក់ខ្វល់ ទុក្ខអាបផលសកលកាយពល់គ្នា ។ មនុស្សយើងនេះឧត្ដម-
ជាយកំណើត មិនមែនកើតមកក្លាយគឺខ្ចប់ជា លុះប្រែបល់ច្បូលជាប់ជាតិ-
តាណា ក្ដុចខឹងជាគានស្អិតចិត្តពស់ពោត ។ បុគ្គលាពិបាទបាទក្នុងអត្ថ
ផ្កាគោកុមសុសែក [illegible] ចិត្ត-

ក៏ស្អាតបរិសុទ្ធឥតហោរហៅ ៗ លុះខ្យល់បក់ឆក់បាត់សាត់តាកទី ក៏ព្រាត់ពី សម្បុកបែកគ្នាទៅ សេកមួយនោះជ្រុះធ្លាក់លើលំនៅ ព្រះតាបសរើស- ទៅថែរក្សា ៗ សេកមួយទៀតក៏តផាត់សាត់ទៅដល់ ទីមណ្ឌលសំ- ណាក់ពួកចោរ ចោររើសទៅចិញ្ចឹមដោយមេត្តា ឬមរក្សាឥតល្ហែថែទាំ- ទុក ៗ សេកដែលនៅសំណាក់ព្រះតាបស ចិត្តសប្បុរសរកផលខ្វល់- ចង់សុខ សាងសទ្ធស្រុចរិតបំផុទទុក្ខ នោះតាំងមុខតាមមគ្គលោកអ្នក- ប្រាជ្ញ ៗ សេកដែលនៅទីធំចោរចិត្តកាក្រក់ រៀនតែឆក់និងលួចប្លន់ស្យា គាថ ចេះខឹលខ្វួចខ្សឹបៈចារក់ណាច ក្លាត់តទ្វារៈចត់ភគិតជីវិតក្សយ ៗ ប្ញូរម៉ែលប្រុះតែផាត់សត្វគិព្ទាន ចំណាលបំនងខានខ្វួចធំសុរ្យយ ប៉ើងប្- ប្រាជ្ញ ១ ក្រៀនព្រះធម៌ថ្លៃ គង្សាស្រ័យប្រែតាមសម្ពាយនោះហោង ៗ

---

សៀវភៅ សប្បុរិសធម៌ ពាក្យកាព្យ នេះ

មានជាវនៅពុទ្ធសាសនបណ្ឌិត្យ ជាកូនសៀវភៅមួយដោយឡែក

## ផ្នែកកំណត់-ប្រវត្តិការណ៍

# ចុតហ្មាយសហជីវិនរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ

នៅពេលដែលចូលកាន់ដំណែងថ្មី សហជីវិន ឌី-ឡូច រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ បានធ្វើចុតហ្មាយមួយ ថ្វាយសម្តេចព្រះសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស និង សម្តេចព្រះធម្មវង្សា ព្រមទាំងព្រះសង្ឃ រាជាគណៈ ថានានុក្រម និង ព្រះសង្ឃ-ពុទ្ធបរិស័ទទាំងអស់ក្នុងព្រះរាជាណាចក្រ មានសេចក្តីដូចតទៅ ៖

ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ
លេខ ៨០៩ កធ

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ នៅថ្ងៃទី ២០ ខែ សីហា ១៩៦៩

សូមព្រះតេជះ តម្កល់លើត្បូង !

សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ

សម្តេចព្រះសង្ឃរាជ ថ្នាក់ទី ១

សូមទ្រង់ជ្រាប ។

សូមនមស្ការចំពោះសម្តេចព្រះសង្ឃនាយក

សូមនមស្ការសម្តេចព្រះពោធិវង្ស សម្តេចព្រះធម្មវង្សាធិបតី

សូមទានប្រាប ៗ

សូមនមស្ការ ព្រះតេជព្រះគុណ ព្រះសង្ឃ រាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការ ព្រមទាំងព្រះសង្ឃទាំងពីរគណៈ

ក្នុងព្រះរាជាណាចក្រ ៗ

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ទើបនឹងមានភ័ព្វវាសនា បានទទួលតំណែងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ និងសាសនសិក្សាធិការ ក្នុងរាជរដ្ឋាភិបាលថ្មី ៗ

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា មានបីតិរីករាយណាស់ ដោយបានគាល់បម្រើសម្តេចជាអម្ចាស់ និងព្រះតេជព្រះគុណផ្ទាល់ ជាភ័ព្វសំណាងឲ្យបានបម្រើព្រះពុទ្ធសាសនា ដ៏ជាសាសនារបស់រដ្ឋផង និងជាគោលនយោបាយជាតិដ៏ប្រសើរ ដែលសម្តេចឪជាអម្ចាស់ជាទីគោរព និងស្នេហា ព្រះអង្គទ្រង់ត្រួសត្រាយឡើង ហៅថា "សង្គមនិយមព្រះពុទ្ធសាសនា" ផង ៗ មិនតែប៉ុណ្ណោះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា បានទទួលព្រះរាជតម្រាស់ផ្ទាល់ចេញពីសម្តេចឪ ព្រះប្រមុខរដ្ឋ អំពីឯកឧត្តមនាយករដ្ឋមន្ត្រី និង ព្រះបញ្ញានៃអ្នកអង្គម្ចាស់ ឧបនាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកក្រសួងមហាផ្ទៃ និងការសម្របសម្រួលនៃកិច្ចការសាសនា ទ្រង់បានផ្ដុកផ្ដាក់ឲ្យ

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខិតខំបម្រើល្អងធូលី អង្គសម្តេចជាអម្ចាស់ និងព្រះតេជព្រះគុណគ្រប់ព្រះអង្គ ។ ព្រះរាជបន្ទូលបណ្តាំនេះស្របនឹងគំនិតផ្ទាល់ដែលទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា តាំងចិត្តយ៉ាងមាំថា នឹងខិតខំបំពេញរាល់កម្មបម្រើកិច្ចការព្រះពុទ្ធសាសនា ឲ្យបានពេញសមត្ថភាពគ្រប់ពេលវេលា ដើម្បីជាប្រយោជន៍ដល់ប្រទេសជាតិ ឯករាជ្យ និង អព្យាក្រឹតផង ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ជឿជាក់ថាភារៈដ៏ធ្ងន់ទាំងនេះ នឹងប្រព្រឹត្តទៅបានល្អប្រសើរនោះ អាស្រ័យដោយព្រះរាជូបត្ថម្ភ ដ៏ថ្លៃថ្លា សេចក្តីឧបត្ថម្ភ អំពីសំណាក់ល្អងធូលី សម្តេចជាម្ចាស់ និង ព្រះតេជព្រះគុណគ្រប់ព្រះអង្គជានិច្ចផង ។ ហេតុនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមបួលមកលំឱនកាយថ្វាយខ្លួន ចំពោះល្អងធូលីសម្តេចជាម្ចាស់ និងព្រះតេជព្រះគុណគ្រប់ព្រះអង្គ ទ្រង់មេត្តា- សូមទានមេត្តាប្រោសប្រទាននូវឱវាទនិងសេចក្តីណែនាំផ្សេងៗ សម្រាប់យកមកប្រតិបត្តិឲ្យបានល្អប្រសើរក្នុងមុខការបម្រើព្រះពុទ្ធសាសនា នៅគ្រប់ពេលវេលាដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ សព្វព្រះទ័យ ។

ជាអវសាន ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមលំអុតលំឱនកាយបង្គំសួងចំពោះតេជានុភាពនៃព្រះត្រ័យរតន៍ សូមមេត្តាជួយជ្រោមជ្រែងរក្សាភិបាលសម្តេចជាអម្ចាស់ និងព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមទ្រង់

បាន និង បានប្រកបដោយសេចក្ដីសុខចម្រើន និងព្រះជន្មាយុវែងឆ្ងាយ ដើម្បីជាពំនាក់អាស្រ័យនៃពុទ្ធមាមកជនជាតិខ្មែរតរៀងទៅ ។

មួយទៀត សូមថ្លែងសេចក្ដីគោរព និង ប្រគេន-ជូនពរសព្ទសាធុ-ការចំពោះព្រះភិក្ខុ សាមណេរ-ឧបាសក-ឧបាសិកា ជាពុទ្ធបរិស័ទទាំងអស់ក្នុងព្រះពុទ្ធាណាចក្រ ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ

និង សាសនសិក្សាធិការ

ហត្ថលេខា : ជី·ឡុង

ចម្លងជូន :

— ខុទ្ទកាល័យសម្ដេចព្រះប្រមុខរដ្ឋ
— ទីស្ដីការនាយករដ្ឋមន្ត្រី
— ទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
— គ្រប់សាលាក្រុង-សាលាខេត្ត-អនុខេត្ត